## ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

## វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ
# ការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន នៅសាលាមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តតាកែវ

## The Implementation of Teacher Professional Standard at Lower Secondary School in Takeo Province

**ដោយ**/by
**ឈួន ស្រីនិត**
**CHHUON SREYNITH**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩**
**ឯកទេស ៖ ការគ្រប់គ្រងអប់រំ**
**ឆ្នាំសិក្សា ២០២០-២០២២**

**ក្រសួងអប់រំ យុវជន និងកីឡា**

Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

# និក្ខេបបទ

# ការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន នៅសាលាមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តតាកែវ

## The Implementation of Teacher Professional Standard at Lower Secondary School in Takeo Province

**ដោយ**/by

**ឈួន ស្រីនិត**

**CHHUON SREYNITH**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**
**ឯកទេស៖ គ្រប់គ្រងអប់រំ**

| | | |
|---|---|---|
| **គ្រូដឹកនាំ** | ៖ | **ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** |
| **គ្រូដឹកនាំរង** | ៖ | **ឯកឧត្តមបណ្ឌិត ងៀ សុផន** |

**ឆ្នាំសិក្សា ២០២០-២០២២**

**វិទ្យាស្ថានជាតិអប់រំ ភ្នំពេញ កម្ពុជា**

**National Institute of Education (NIE)**
**Phnom Penh, Kingdom of Cambodia**

# សេចក្ដីប្រកាសអះអាងរបស់បេក្ខជន

នាងខ្ញុំសូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**ការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន នៅសាលាមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តតាកែវ**"សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់នាងខ្ញុំទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សា សម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬនៅសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ លើសពីនេះទៅទៀត ស្នាដៃនេះពុំមានសេចក្ដីដកស្រង់ ឬខ្លឹមសារណាមួយយកមកប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារឡើយ។ និក្ខេបបទស្រាវជ្រាវនេះពិតជាស្រាវជ្រាវនិងចងក្រងដោយនាងខ្ញុំផ្ទាល់ប្រាកដមែន។

ថ្ងៃអាទិត្យ ១៣កើត ខែកត្ដិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ២០២២

**ហត្ថលេខាបេក្ខជន**



**ឈួន ស្រីនិត**

# លិខិតបញ្ជាក់

បណ្ឌិត **សៀង សុវណ្ណា** ជាគ្រូដឹកនាំ
បណ្ឌិត **ងៀ សុផន** ជាគ្រូដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា៖

លោកស្រី **ឈួន ស្រីនិត** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តតាកែវ" ប្រាកដមែន។

ថ្ងៃ អាទិត្យ ១៣កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០២២

| | |
|---|---|
| ........................................................ | ........................................................ |
| បណ្ឌិត **សៀង សុវណ្ណា** | បណ្ឌិត **ងៀ សុផន** |
| គ្រូដឹកនាំ | គ្រូដឹកនាំរង |

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៧០២៥...អយក.ខុកន

(ការសម្ងាត់)

## លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំង ជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ ទី៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ឧទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | ឧទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម | យក់ ង៉ុយ | ឧទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម | លាង សេងហាក់ | ឧទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម | ម៉ក់ ង៉យ | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | សមាជិក |
| ៧-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-ឯកឧត្តមបណ្ឌិត | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ១០-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ហេង គ្រេង | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ១៥-លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១៦-លោកបណ្ឌិត | អ៊ែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ១៧-លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈិញ ស៊ីថា | អ្នកឯកទេសអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | នី វង្ខា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

កន្លែងទទួល៖
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ រដ្ឋអ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៧០២២ អយក.ទ៤ន

(ការសម្ងាត់)

## លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោកបណ្ឌិត | ឡាយ សុវិជ្ជា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ៥-លោកបណ្ឌិត | សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | លី គីមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៨-លោកបណ្ឌិត | ឈិញ នីដា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៩-លោកបណ្ឌិត | អុំ ចាន់ចំណាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | កាង ស៊ីងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | លឹម ភ៌ន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | មឿន លិនណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោកស្រីបណ្ឌិត | ឡឹយ សុគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោក | ប៉ុ ប៊ុន្នួន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | សឿ សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០.លោក | ថាច់ សន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១.លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២.លោកស្រី | សេង សច្ចា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣.លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤.លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥.លោកស្រី | ឯម សុភាលក្ស្មី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

កន្លែងទទួល៖

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ រដែអ

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

ពន្យល់ណែនាំដល់នាងខ្ញុំគ្រប់ជំហាន ទើបធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់នាងខ្ញុំ ទទួលបានជោគជ័យ នាពេលនេះ។

នាងខ្ញុំ សូមថ្លែងអំណរគុណចំពោះមិត្តរួមថ្នាក់និងរួមជំនាន់ទី៩ទាំងអស់ ដែលតែងតែផ្ដល់ជាកម្លាំងចិត្តដល់នាងខ្ញុំ តាមរយៈការចែករំលែកចំណេះដឹង បទពិសោធន៍ និងព័ត៌មានទាំងឡាយដល់នាងខ្ញុំ ដើម្បីឱ្យការស្រាវជ្រាវរបស់នាងខ្ញុំមានភាពងាយស្រួល។

នាងខ្ញុំ ក៏សូមថ្លែងអំណរគុណផងដែរ ចំពោះថ្នាក់ដឹកនាំ មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ ថ្នាក់ដឹកនាំការិយាល័យជំនាញនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ គណៈគ្រប់គ្រងវិទ្យាល័យ និងអនុវិទ្យាល័យគោលដៅទាំង១២ និងលោកគ្រូ-អ្នកគ្រូទាំងអស់ ដែលបានចូលរួម ជួយសម្របសម្រួល និងសហការ ក្នុងដំណើរការចុះប្រមូលទិន្នន័យ ដែលបានធ្វើឱ្យការសិក្សាស្រាវជ្រាវនេះ ទទួលជោគជ័យ។

ជាទីបញ្ចប់ នាងខ្ញុំ សូមគោរពជូនពរចំពោះអ្នកទាំងអស់គ្នា សូមជួបប្រទះតែសេចក្ដីសុខចម្រើន និងទទួលបាននូវពុទ្ធពរទាំង៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

`

# មាតិកាចំណងជើង

**សេចក្តីប្រកាសអះអាងរបស់បេក្ខជន** ........ i
**លិខិតបញ្ជាក់** ........ ii
**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ........ iii
........ v
**សេចក្តីថ្លែងអំណរគុណ** ........ vi
**បញ្ជីតារាង** ........ xi
**បញ្ជីតារាងអក្សរកាត់** ........ xii
Abstract ........ xv
........ 1
**ជំពូកទី១ សេចក្តីផ្តើម** ........ 2
១. ១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ 2
១. ២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 4
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ 6
១.៥ សំណួរស្រាវជ្រាវ ........ 7
១.៦ ដែនកំណត់នៃការស្រាវជ្រាវ ........ 7
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 8
**ជំពូក២៖ រំលឹកទ្រឹស្តី** ........ 10
២.១ និយមន័យពាក្យគន្លឹះ ........ 10
២.១.១ បញ្ញតិស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ........ 10
ក.និយមន័យស្តង់ដា ........ 10
ខ.និយមន័យវិជ្ជាជីវៈ ........ 10
គ.និយមន័យស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ........ 11
២.២.១ ការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសមួយចំនួន ........ 19
ក.ការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសអង់គ្លេស ........ 19
ខ.ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសអូស្រ្តាលី ........ 20
គ.  ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសន័រវ៉េ ........ 21

ឃ.ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសម៉ារីលែន (Maryland) ....... 21
ង.ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសថៃ ....... 22
២.២.២ បញ្ហាប្រឈមរបស់សាលារៀន ....... 28
២.២.២.១ បញ្ហាប្រឈមមួយចំនួនរបស់គ្រូបង្រៀន នៅតាមបណ្តាប្រទេសមួយចំនួន ....... 28
២.៣.២ បញ្ហាប្រឈមមួយចំនួនរបស់គ្រូនៅកម្ពុជា ....... 30
ក.បញ្ហាប្រឈមទៅលើគុណភាពគ្រូបង្រៀន ....... 30
ខ.បញ្ហាប្រឈមអំពីគុណភាពសិស្សប្រឡងចូលធ្វើគ្រូបង្រៀន ....... 31
២.៤ មូលហេតុដែលនាំឱ្យមានស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ....... 35
២.៤.១ ការបង្កើតស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសមួយចំនួន ....... 35
២.៤ ការកកើតស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជា ....... 37
២.៤.៣ ការប្រៀបធៀបស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ....... 38
២.៥ ក្របខណ្ឌទស្សនាទាន ....... 45
**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ** ....... 48
៣.១. ភាគសំណាកនៃការស្រាវជ្រាវ ....... 48
៣.២. ឧបករណ៍ស្រាវជ្រាវ ....... 50
៣.២.១ ការបង្កើតខ្លឹមសារ ....... 50
៣.២.២ ទម្រង់កម្រងសំណួរ ....... 50
៣.៣ នីតិវិធី និងដំណើរការប្រមូលទិន្នន័យ ....... 50
៣.៤. ការវិភាគទិន្នន័យ ....... 52
៣.៤.១ កម្រិតចង្អុលបង្ហាញ ....... 53
៣.៤.២ ដំណាក់កាលនៃការវិភាគទិន្នន័យ ....... 54
៣.៤.៣ ការបកស្រាយទិន្នន័យ ....... 54
៣.៤.៤ ការវិភាគទិន្នន័យលើកម្រងសំណួរ ....... 54
៣.៥ ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ ....... 55
**ជំពូក៤៖ លទ្ធផលស្រាវជ្រាវ និងការពិភាក្សា** ....... 57
៤.១.លទ្ធផលស្រាវជ្រាវ ....... 57

៤.១.២.ការប្រៀបធៀបតាមតំបន់លើ ការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន នៅសាលាមធ្យមសិក្សា បឋមភូមិក្នុងខេត្តតាកែវ ......66
៤.១.៣. ការវិភាគការអនុវត្តតាមតំបន់ លើការអនុវត្តស្តង់ដាវិជ្ជាជីវៈរបស់គ្រូ បង្រៀន នៅសាលាមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តតាកែវ......68
ក.តំបន់ទីប្រជុំជន......68
៤.២ ការពិភាក្សា......73
៤.៣ ដំណោះស្រាយ ......78
**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ......80
៥.១ សេចក្តីសន្និដ្ឋាន ......80
៥.២ សំណូមពរ ......83
៥.២.១ សំណូមពរសម្រាប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ......83
៥.២.២ សំណូមពរសម្រាប់អ្នកស្រាវជ្រាវបន្ត......84
...... 91
**ឧបសម្ព័ន្ធ**...... 92
ឧបសម្ព័ន្ធ១៖ កម្រងសំណួរ ......92
ឧបសម្ព័ន២៖ លិខិតឧទ្ទេសនាម គ្រូណែនាំគោល និងគ្រូណែនាំរង សម្រាប់ការសរសេរនិក្ខេបបទ......98
ឧបសម្ព័ន្ធ៣៖ លិខិតអនុញ្ញាតចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សា ...101
ឧបសម្ព័ន្ធ៤៖ លិខិតអនុញ្ញាតរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ......102
ឧបសម្ព័ន្ធ៥៖ លិខិតបង្គាប់ការគណៈកម្មការការពារនិក្ខេបបទបញ្ចប់ ......103

# បញ្ជីតារាង

តារាង ទី១. ចំណេះដឹងវិជ្ជាជីវៈ.....64
តារាង ទី២ ការប្រតិបត្តិវិជ្ជាជីវៈ.....67
តារាង ទី៣ ការសិក្សាវិជ្ជាជីវៈ.....69
តារាង ទី៤ សីលធម៌វិជ្ជាជីវៈ.....71
តារាង ទី៥ លទ្ធផលរួមការអនុវត្តរបស់សមាសភាគទាំង៤.....71
តារាង ទី៦ ការអនុវត្តន៍ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនក្នុងខេត្តតាកែវ.....72
តារាង ទី៧ ការប្រៀបធៀបសមាសភាគចំណេះដឹងវិជ្ជាជីវៈក្នុងតំបន់ទាំង៣.....77
តារាង ទី៨ ការប្រៀបធៀបសមាសភាគការប្រតិបត្តិវិជ្ជាជីវៈក្នុងតំបន់ទាំង៣.....78
តារាង ទី៩ ការប្រៀបធៀបសមាសភាគការសិក្សាវិជ្ជាជីវៈក្នុងតំបន់ទាំង៣.....79
តារាង ទី១០ ការប្រៀបធៀបសមាសភាគសីលធម៌វិជ្ជាជីវៈក្នុងតំបន់ទាំង៣.....79
តារាង ទី១១ ការប្រៀបធៀបការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនក្នុងតំបន់ទីប្រជុំជន.....81
តារាង ទី១២ ការប្រៀបធៀបការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនក្នុងតំបន់ជនបទ.....82
តារាង ទី១៣ ការប្រៀបធៀបការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនក្នុងតំបន់ដាច់ស្រយាល.....83

# បញ្ជីតារាងអក្សរកាត់

| | | |
|---|---|---|
| EFA | Education for All ការអប់រំសម្រាប់ទាំងអស់គ្នា |
| ESP | Educational Stategic Plan ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| ICT | Information Communication Technology បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ |
| MoEYS | Ministry of Education Youth and Sport ក្រសួងអប់រំ យុវជន និង កីឡា |
| UNICEF | United Nation Children’s Fund មូលនិធិសហប្រជាជាតិសម្រាប់កុមារ |
| UNESCO | United Nations Education, Scientific and Culture Organization អង្គការអប់រំវិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ |
| WB | World Bank ធនាគារពិភពលោក |
| TTD | Teacher Training Center នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| TPS | Teacher Professional Standard ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន |
| AITSL | Australian Institute for Teaching and School Leadership វិទ្យាស្ថានអូស្រ្តាលី សម្រាប់ការបង្រៀន និង គ្រប់គ្រងសាលារៀន |

# មូលន័យសង្ខេប

គ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ តាមរយៈការផលិតធនធានមនុស្សក្នុងសង្គម។ ហេតុដូច្នេះ ក្នុងការលើកកម្ពស់នូវគុណភាពអប់រំ ក្រសួង អប់រំ យុវជន និងកីឡា បានបង្កើតស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀននេះឡើងតាំងពីឆ្នាំ ២០១០ សម្រាប់ជាត្រីវិស័យដល់គ្រូបង្រៀនគ្រប់លំដាប់ថ្នាក់ ដោយចាត់ទុកថាស្តង់ដារនេះ ជាកម្រិតអប្បរមាដែលគ្រូអាចអនុវត្តបានទាំងអស់គ្នា។ ទោះបីជាយ៉ាងណាក៏ដោយ ចាប់តាំងពីឯកសារនេះបានចាប់បដិសន្ធិឡើង ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនមួយនេះ ហាក់បីដូចជាពុំមានវត្តមានក្នុងការប្រើប្រាស់ឱ្យបានទូលំទូលាយ និងពុំធ្លាប់ត្រូវបានវាយតម្លៃពីស្ថាប័នណាមួយឡើយ។ ដោយសារឃើញនូវភាពអសកម្មរបស់ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ការសិក្សានេះ ចង់ពិនិត្យមើលការអនុវត្តរបស់គ្រូបង្រៀនបច្ចុប្បន្ន រកឱ្យឃើញនូវបញ្ហាប្រឈមមួយចំនួនក្នុងការប្រតិបត្តិតាមស្តង់ដារនេះ និងស្វែងរកដំណោះស្រាយ។ ការសិក្សាស្រាវជ្រាវនេះសិក្សាតាមបែបបរិមាណវិស័យ (Quantitative)។ ទិន្នន័យត្រូវបានប្រមូលក្នុងដំណាក់កាលតែមួយគឺតាមរយៈការបំពេញកម្រងសំណួរ ដើម្បីទទួលបាននូវព័ត៌មានស៊ីជម្រៅលើដំណើរការអនុវត្តជាក់ស្តែងរបស់ពួកគាត់ បញ្ហាប្រឈម និងដំណោះស្រាយមួយចំនួនចំពោះស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនមួយនេះ។ លទ្ធផលបានបង្ហាញថា ក្នុងការប្រតិបត្តិជាក់ស្តែង មានភាពខុសគ្នាចំពោះសមាសភាគទាំងបួនក្នុងស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ក្នុងនេះ សមាសភាគមួយរបស់ស្តង់ដារវិជ្ជាជីវៈ គឺគ្រូបង្រៀនអនុវត្តបានកម្រិតទាបជាងគេ។ សីលធម៌វិជ្ជាជីវៈ ត្រូវបានបង្ហាញថា ទទួលបានចំណាត់ថ្នាក់ទាបជាងគេ ដោយទិន្នន័យទទួលបានពីគ្រូបង្រៀនជាសំណាកគម្រូទាំងអស់ ខណៈពេលដែលការប្រតិបត្តិវិជ្ជាជីវៈទទួលបានចំណាត់ថ្នាក់ទី៣ និងការសិក្សាវិជ្ជាជីវៈទទួលបានចំណាត់ថ្នាក់លេខ ២ ហើយសមាសភាគចំណេះដឹងវិជ្ជាជីវៈ ទទួលបានចំណាត់ថ្នាក់ល្អជាងគេ។ ក្នុងការសិក្សានេះ បញ្ហាប្រឈមមួយចំនួនត្រូវបានរកឃើញ និង សំណូមពរត្រូវបានចងក្រងជូនចំពោះក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ គ្រឹះស្ថានសិក្សា ដៃគូអភិវឌ្ឍ អ្នកអប់រំ និងអ្នកស្រាវជ្រាវទាំងអស់ ដើម្បីជាព័ត៌មាន និងធ្វើការសិក្សាស្រាវជ្រាវបន្ត ក្នុងការលើកកម្ពស់ការអនុវត្តរបស់គ្រូបង្រៀនឱ្យ

ស្របតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងធានាបាននូវគុណភាពអប់រំ។ បញ្ហាប្រឈមត្រូវបានរកឃើញរួមមាន លោកគ្រូ -អ្នកគ្រូមិនសូវយល់ដឹងពីគោលនយោបាយអប់រំ ក៏ដូចជាកំណែទម្រង់វិស័យអប់រំនាពេលបច្ចុប្បន្ន ។ម្យ៉ាងវិញទៀត លោកគ្រូ-អ្នកគ្រូ មិនសូវបានផ្តល់ការតាមដានការសិក្សារបស់សិស្ស ក៏ដូចជា មិនសូវបានយកចិត្តទុកដាក់ក្នុងការថែរក្សាសិស្សឱ្យបានល្អនៅឡើយទេ។ ការចូលរួមរបស់ឪពុកម្តាយ និងសហគមន៍នៅមានកម្រិត ខ្វះការលើកទឹកចិត្តពីអ្នកពាក់ព័ន្ធ ខ្វះខាតនូវសម្ភារៈឧបទេសសម្រាប់បង្រៀន និងរៀន ឯកសារស្រាវជ្រាវបន្ថែម បណ្ណាល័យ និងកន្លែងសិក្សាស្រាវជ្រាវសម្រាប់គ្រូប្រកបដោយបច្ចេកវិទ្យាទំនើប ។ ក្រោយពីរកឃើញ នូបបញ្ហា ប្រឈមខាងលើ ដំណោះស្រាយក៏ត្រូវបានរក ឃើញរួមមាន នាយកសាលាគួរតែជំរុញលោកគ្រូ-អ្នកគ្រូព្យាយាមសិក្សាស្រាវជ្រាវបន្ថែមឱ្យបាន ច្រើនដើម្បីពង្រីកចំណេះដឹង ប្រើប្រាស់វិធីបង្រៀន ប្លែកៗឱ្យបានច្រើន ចំណែកឯក្រសួងវិញ ត្រូវបង្កើតសិក្ខាសាលាដែលទាក់ទងនឹងចំណេះដឹង ថ្មីៗដើម្បីយកមកផ្ទេរដល់សិស្សផ្តល់គ្រូ ICT ម្នាក់ សម្រាប់សាលារៀននីមួយៗសម្រាប់បង្រៀន ដល់លោកគ្រូ- អ្នកគ្រូដែលខ្សោយមុខវិជ្ជានេះ។

# Abstract

Teachers play an active role in developing the nation through building up human resources in the society. Hence, in enhancing the education quality, Ministry of Education Youth and Sport (MoEYS) established the teacher professional standards in 2010 as a compass to give directions to all levels of teachers so that a minimum standard in teaching profession can be achieved. However, since its creation, the teacher professional standards seem to be silent in implementing and no evaluation has been made. Because of this inactiveness of the standards implementation, the current research revisits implementing practices ,challanges of professional teacher standards and the solutions . In doing so, this study employs quantitative methods. The data were collected in only one stage, by giving out questionnaires to participants to dig out the insightful information on success and challenges in carrying out the teacher professional standards. The results showed that the real implementation of teacher standards varied among the four dimensions, leaving some components lowly implemented. professional ethicwas reported lowly possessed by the sample teachers, while the professional practice and professional study ranked the third and second respectively. Most teachers reported that they had high professional study . A number of barriers were found and recommendations were made to the Ministry of Education Youth and Sport accordingly in order to push the teachers up to meet professional teacher standards and ensure the quality of education in Cambodia. Challenges were found to include teachers' lack of understanding of education policies as well as current education reforms. Not much attention has been paid to taking good care of students yet.community involvement is limited, lack of motivation, and lack of teaching material, library learning place with teachnological equibment for teacher._After discovering the above challenges, solutions were also found, including school principals should encourage teachers to try to do more research to expand knowledge, use more different teaching methods, while the Ministry must create Workshops related to new knowledge to transfer to students provide an ICT teacher for each school to teach teachers who are weak in this subject.

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១ សេចក្តីផ្តើម

## ១. ១ លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងបរិបទថ្មីនៃការសិក្សារបស់ប្រទេសនីមួយៗ ការអប់រំត្រូវបានចាត់ទុកជាវិស័យដ៏មានសារៈសំខាន់ណាស់សម្រាប់ប្រទេសជាតិ។ ជាក់ស្តែង ប្រទេសកម្ពុជាក៏ជាប្រទេសមួយដែលយកចិត្តទុកដាក់លើវិស័យអប់រំ ដើម្បីជំរុញការអភិវឌ្ឍប្រទេសជាតិឱ្យមានសេដ្ឋកិច្ចរីកចម្រើន។ ក្រោមក្របខណ្ឌផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និង កីឡា បានដាក់ចេញផែនការយុទ្ធសាស្រ្តវិស័យអប់រំ)ESP) ២០១៩ - ២០២៣ ជាមួយនឹងមហិច្ឆតាអភិវឌ្ឍន៍ធនធានមនុស្ស សម្រាប់ប្រែក្លាយប្រទេសកម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍ត្រឹមឆ្នាំ២០៥០។ ដូច្នេះ ការផលិតធនធានមនុស្សប្រកបដោយគុណភាពសម្រាប់ប្រទេសជាតិ គឺជារឿងចាំបាច់បំផុតដែលរាជរដ្ឋាភិបាលត្រូវផ្តោតលើការអប់រំ។

ដើម្បីសម្រេចបាននូវគោលដៅទាំងនេះ មានកត្តាពាក់ព័ន្ធជាច្រើន ក្នុងនោះគ្រូបង្រៀនគឺជាកត្តាចម្បង និងជាមូលដ្ឋានសម្រាប់ការលើកកម្ពស់គុណភាពអប់រំ តាមរយៈការបង្រៀន និងរៀន ។

ឆ្លើយតបទៅនឹងតម្រូវការវិស័យអប់រំ គ្រូបង្រៀនគឺជាផ្នែកមួយដ៏សំខាន់ក្នុងការជួយសិស្សអាចរៀនសូត្រប្រកបដោយប្រសិទ្ធភាព ក៏ដូចជាពង្រឹងគុណភាពនៃការអប់រំឱ្យមានលក្ខណៈប្រសើរឡើង។ ប្រការនេះហើយដែលទាមទារឱ្យគ្រូបង្រៀនត្រូវអភិវឌ្ឍវិជ្ជាជីវៈ ដើម្បីមានសមត្ថភាពធ្វើឱ្យការរៀនសូត្រ ក្នុងសាលារៀន អាចដំណើរការបានប្រកបដោយប្រសិទ្ធភាព ។

ការអប់រំ មានគោលដៅលើកកម្ពស់សេដ្ឋកិច្ចជាតិ តាមរយៈការអភិវឌ្ឍលើគ្រប់វិស័យ។ ដោយឡែក រាល់ការអប់រំមិនមែនសុទ្ធតែជានាបានទាំងបរិមាណ និងគុណភាពនោះទេ ពិសេសចំពោះប្រទេសកំពុងអភិវឌ្ឍន៍។ គុណភាពអប់រំ សំដៅដល់សុខភាពរបស់សិស្សទាំងផ្លូវកាយ និងផ្លូវចិត្ត ក្រោមការបង្ហាត់បង្រៀនរបស់គ្រូដែលមានគរុកោសល្យត្រឹមត្រូវ មានកម្មវិធីសិក្សាច្បាស់លាស់ និងមានការដឹកនាំគ្រប់គ្រងរបស់នាយកសាលាប្រកបដោយសមត្ថភាព (UNESCO ,2005) ។

ដូច្នេះ វិស័យអប់រំដែលមានការរីកចម្រើន និងមានប្រសិទ្ធភាពទាមទារជាចាំបាច់នូវកម្រិតសមត្ថភាពរបស់គ្រូបង្រៀន ដែលក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងយកចិត្តទុកដាក់ និងធ្វើការបំប៉នជាប្រចាំ។ គុណភាពអប់រំគឺជាបញ្ហាចម្បង ដែលមនុស្សគ្រប់រូបក្នុងសង្គមត្រូវយកចិត្តទុកដាក់ និងចូលរួមដោះស្រាយ ពិសេសអ្នកអប់រំគ្រប់ស្រទាប់វណ្ណៈ ដើម្បីលើកស្ទួយនូវកំណើនសេដ្ឋកិច្ចជាតិ និងយុត្តិធម៌សង្គម។ បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងអនុវត្តនូវយុទ្ធសាស្ត្រចតុកោណរបស់ខ្លួនដោយផ្តោតការយកចិត្តទុកដាក់ទៅលើគុណភាពអប់រំ និងការអភិវឌ្ឍធនធានមនុស្ស ដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ប្រទេសជាតិ ក៏ដូចជាការប្រគួតប្រជែងក្នុងតំបន់ និងសកលលោក។

យោងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ ក្រសួងអប់រំ យុវជន និងកីឡាមានទស្សនៈវិស័យ ក្នុងការកែទម្រង់ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបឋម និងគ្រូបង្រៀនកម្រិតមូលដ្ឋានពីការបណ្តុះបណ្តាលរយៈពេលពីរឆ្នាំទៅជាការបណ្តុះបណ្តាលរយៈពេលបួនឆ្នាំវិញ ចាប់ពីឆ្នាំ២០២០ )MoEYS, 2014) ។ កំណែទម្រង់នេះបានឆ្លុះបញ្ចាំងឱ្យឃើញថា កម្រិតនៃការបណ្តុះបណ្តាលគ្រូបង្រៀនបច្ចុប្បន្នពុំទាន់ធានានូវគុណភាពឱ្យគ្រូបង្រៀនបានល្អប្រសើរនៅឡើយទេ ដោយក្រសួងមានគោលបំណងលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងសង្គមសម័យទំនើប។

ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន គឺជាតម្រូវការដ៏ចាំបាច់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយប្រសិទ្ធភាពនិងគុណភាព ឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍ប្រទេសជាតិ។ ក្នុងនោះនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការរបស់ក្រសួងអប់រំ យុវជន និងកីឡា ជានាយកដ្ឋានជំនាញទទួលបន្ទុកការបណ្តុះបណ្តាលដំបូង និងការបណ្តុះបណ្តាលបន្ត ដល់គ្រូបង្រៀនមត្តេយ្យសិក្សានៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម គ្រូបង្រៀនកម្រិតបឋមសិក្សានៅសាលាគរុកោសល្យ និងវិក្រឹតការរាជធានីខេត្តទាំង១៦និងវិទ្យាស្ថានគរុកោសល្យទាំងពីរ២ និងគ្រូបង្រៀនកម្រិតមូលដ្ឋាននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៤និងវិទ្យាស្ថានគរុកោសល្យពីរ។

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ មានគោលការណ៍ច្បាស់លាស់ក្នុងការផលិតនិងអភិវឌ្ឍន៍ ធនធានមនុស្ស ប្រកបដោយគុណភាព និងជំនាញពិតប្រាកដ ដើម្បីឆ្លើយតបនឹងតម្រូវការវិស័យអប់រំនៅ កម្ពុជា តាមរយៈបេសកកម្មចំនួនបីគឺ ៖

- ផ្តល់គ្រូបង្រៀនប្រកបដោយគុណភាពឆ្លើយតបទៅនឹងតម្រូវការរបស់សាលារៀនចំណេះទូទៅ
- ពង្រឹងគុណភាពនៃការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន
- ពិនិត្យ តាមដាន និងវាយតម្លៃវិជ្ជាជីវៈគ្រូបង្រៀន (MoEYS,2011,p.10)

ថ្មីៗនេះ នៅក្នុងគោលនយោបាយគ្រូបង្រៀន ក្រសួងអប់រំ យុវជន និងកីឡា មានគោលបំណង" អភិវឌ្ឍន៍គ្រូបង្រៀនឱ្យមានគុណភាព សមត្ថភាព និងស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងផ្តល់លក្ខខណ្ឌចាំបាច់ ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តសិទ្ធ" (MoEYS, 2013a, p.2)។ លើសពីនេះទៀត ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់នូវគោលដៅទៅមុខទៀត ដោយរកមធ្យោបាយ ទាក់ទាញអ្នកមានសមត្ថភាព ឱ្យចូលមកបម្រើការងារជាគ្រូបង្រៀន ធានានូវការបណ្តុះបណ្តាលដំបូង )In-Service Training ) ឱ្យបានពេញលេញបន្តអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារឱ្យបានជាប្រចាំ និងផ្តល់ជូននូវលក្ខខណ្ឌឱ្យបានសមរម្យពេលបំពេញការងារ ឱ្យមានគុណភាព និងប្រសិទ្ធភាពខ្ពស់ (MoEYS,2013a)។ ទោះបីជាយ៉ាងណា យើងឃើញថាការអប់រំបច្ចុប្បន្នបានល្អប្រសើរមួយកម្រិតធំ ពិសេសលើផ្នែកបរិមាណ ប៉ុន្តែចំពោះផ្នែកគុណភាពវិញ ពុំទាន់ឆ្លើយតបនឹងគោលដៅចង់បានរបស់ក្រសួងឡើយ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

គ្រូបង្រៀន គឺជាកត្តាគន្លឹះក្នុងការលើកកម្ពស់គុណភាពអប់រំ ប្រកបដោយប្រសិទ្ធភាព។ ការយកចិត្តទុកដាក់ខ្ពស់ ក្នុងការផ្តល់សេវាអប់រំប្រកបដោយគុណភាព គឺជាការទទួលខុសត្រូវរបស់គ្រូបង្រៀនចំពោះសង្គមជាតិទាំងមូល។ គុណភាពរបស់សិស្សបញ្ចប់ថ្នាក់ទី១២ត្រូវលើកកម្ពស់និងផ្តល់នូវចំណេះដឹងពាក់ព័ន្ធដទៃទៀតសម្រាប់ការអប់រំបច្ចេកទេសវិជ្ជាជីវៈ និងឧត្តមសិក្សា។

ដើម្បីឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតនូវផែនការយុទ្ធសាស្ត្រវិស័យអប់រំជាបន្តបន្ទាប់ ដោយមានគោលនយោបាយជាច្រើនគាំទ្រ។ គោលនយោបាយទាំងនោះរួមមាន៖ គោលនយោបាយសាលាកុមារមេត្រី គោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា និងគោលនយោបាយគ្រូបង្រៀន...។ល។ ជាងនេះទៅទៀត ក្រសួងបាន និងកំពុងរៀបចំផែនការអនុវត្តសកម្មភាពគោលនយោបាយគ្រូបង្រៀន និងបន្តអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ២០១៩-២០២៣ ពីផែនការយុទ្ធសាស្ត្រចាស់ឆ្នាំ២០១៤-២០១៨។ ក្នុងផែនការយុទ្ធសាស្ត្រថ្មីនេះ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់នូវគោលនយោបាយធំៗចំនួន២គឺ៖

- ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា
- ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនបានចែងថាគ្រូបង្រៀនគ្រប់កម្រិត ត្រូវមានគុណវុឌ្ឍិយ៉ាងទាបបំផុតបរិញ្ញាបត្រអប់រំ (ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការឆ្នាំ២០១០)។

ទោះជាយ៉ាងណា ក្នុងទិវារំឭកគុណគ្រូបង្រៀនឆ្នាំ២០១៣ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ដោយផ្តោតទៅលើគុណភាពអប់រំនៅកម្ពុជា គឺមិនទាន់អាចទទួលយកបាននៅឡើយ (Hang,2013) ហើយក្នុងទិវា Cam TESOL ប្រចាំឆ្នាំលើកទី១០ នៅ វិទ្យាស្ថានភាសាបរទេស គាត់ក៏បានលើកឡើងផងដែរនូវកំណែទម្រង់៨ចំណុច ដើម្បីលើកកម្ពស់គុណ ភាពវិស័យអប់រំ ដែលក្នុងនោះចំណុចអាទិភាពទី១ គឺការលើកកម្ពស់គុណភាពនៃការបង្រៀន និងរៀន (Hang,2014)។ ដូច្នេះ មានន័យថា ការបង្រៀន និងរៀន របស់គ្រូនិងសិស្សនាពេលបច្ចុប្បន្នពុំទាន់មានគុណភាពល្អដែលអាចធានាបាននូវធនធានមនុស្សឆ្លើយតបទៅនឹងតម្រូវការសង្គមនៅឡើយ។ សរុបមកបញ្ហាគុណភាព មិនមែនមានតែនៅប្រទេសកម្ពុជាប៉ុណ្ណោះទេ គឺគ្រប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនកំពុងជួបប្រទះនូវបញ្ហានេះ ជាពិសេសបញ្ហាដែលពាក់ព័ន្ធនឹងគុណភាពគ្រូបង្រៀនដែលមិនទាន់សមស្របទៅនឹងស្តង់ដាវិជ្ជាជីវៈ (WB,2008)។ ផ្ទុយទៅវិញ ប្រទេសកម្ពុជាបានយកចិត្តទុកដាក់ចំពោះគុណ

ភាពគ្រូបង្រៀន ដោយបានបោះពុម្ពនិងផ្សព្វផ្សាយនូវស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនតាំងពីឆ្នាំ២០១០ និងបានបោះពុម្ពលើកទីពីរនៅឆ្នាំ២០១១ ដែលក្នុងសៀវភៅស្តង់ដានោះ មានគោលបំណងជំរុញការអនុវត្តរបស់គ្រូបង្រៀន មិនថាគ្រូបង្រៀននៅសាលាចំណេះទូទៅ និងគ្រូឧទ្ទេសនៅសាលាគរុកោសល្យ ឬមជ្ឈមណ្ឌលគរុកោសល្យភូមិភាគនោះទេ ត្រូវតែយកចិត្តទុកដាក់ខិតខំបំពេញឱ្យបាននូវស្តង់ដាវិជ្ជាជីវៈនេះ។ ក្នុងការអនុវត្តជាក់ស្តែង យើងសង្កេតឃើញថា ស្តង់ដាដែលបានផ្សព្វផ្សាយឱ្យប្រើប្រាស់ដោយក្រសួងអប់រំ យុវជន និងកីឡាហាក់បីដូចជាពុំមានប្រសិទ្ធភាព និងទទួលការស្វាគមន៍ ឬចាប់អារម្មណ៍ពីសំណាក់គ្រូបង្រៀនសោះឡើយ។ មានន័យថា ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមួយនេះ ក្រោយពីបោះពុម្ពទាំងពីរលើកនិងផ្សព្វផ្សាយឱ្យប្រើប្រាស់កន្លងមក ហាក់បីដូចជាពុំមានវត្តមាន និងប្រើប្រាស់ឱ្យបានទូលំទូលាយនៅតាមសាលា រៀនដូចការរំពឹងទុករបស់ក្រសួង។ ចំណែកថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ដូចជាមន្ទីរអប់រំ យុវជន និងកីឡា រាជធានី/ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ និងនាយកសាលារៀនក៏ពុំមានការចុះ វាយតម្លៃគុណភាពគ្រូបង្រៀនដោយផ្អែកលើស្តង់ដាវិជ្ជាជីវៈដែលមានស្រាប់នេះដែរ។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណង៖

- សិក្សាពីស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់បុគ្គលិកបង្រៀន ធៀបនឹងស្តង់ដាវិជ្ជាជីវៈដែលមានស្រាប់។
- កំណត់បានពីបញ្ហាប្រឈម និងដំណោះស្រាយនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈរបស់គ្រូបង្រៀននៅគ្រឹះស្ថានសិក្សាសាធារណៈឱ្យកាន់តែល្អប្រសើរឡើង។

## ១.៤ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ លើប្រធានបទ **ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តតាកែវ** មានសារៈសំខាន់ណាស់សម្រាប់ផ្តល់ជាចូល ក្នុងការបង្កើតយុទ្ធសាស្រ្តលើកកម្ពស់ការបំពេញភារកិច្ចរបស់គ្រូបង្រៀន ឱ្យស្របតាមក្រមសីលធម៌វិជ្ជាជីវៈ ប្រកបដោយការ

ទទួលខុសត្រូវខ្ពស់ចំពោះជោគវាសនារបស់សិស្ស។ ការសិក្សាពីកម្រិតនៃការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន និងលទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាបឋមភូមិ ផ្តល់ជាយោបល់កែលម្អលើចំណុចខ្វះខាតក្នុងការបំពេញភារកិច្ចប្រចាំថ្ងៃរបស់លោកគ្រូ អ្នកគ្រូ ព្រមទាំងចែករំលែកព័ត៌មាន និងបទពិសោធន៍ល្អៗដែលបានរកឃើញពីការសិក្សាស្រាវជ្រាវដល់គ្រឹះស្ថានសិក្សានានានៅកម្រិតសិក្សាដទៃទៀត ។

ការរកឃើញពីស្ថានភាពជាក់ស្តែង នៃការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈក្នុងការបំពេញភារកិច្ចរបស់គ្រូបង្រៀន អាចជួយដល់អ្នកស្រាវជ្រាវ សំយោគបានមូលហេតុផ្សេងៗ ដើម្បីធ្វើការលើកឡើងជាសំណូមពរដល់ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងភាគីពាក់ព័ន្ធ ដើម្បីដាក់ចេញជាយុទ្ធសាស្ត្រ ក្នុងការកែលម្អដល់ការបំពេញភារកិច្ចរបស់គ្រូបង្រៀននៅតាមសាលាមធ្យមសិក្សាបឋមភូមិឱ្យកាន់តែប្រសើរជាងមុន។

## ១.៥ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងស្រាវជ្រាវក្នុងចំណុចទី១.៣ខាងលើ ការសិក្សាស្រាវជ្រាវនេះមានសំណួរស្រាវជ្រាវចំនួនពីរដូចខាងក្រោម៖

១.តើគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវបានអនុវត្តស្តង់ដាវិជ្ជាជីវៈដល់កម្រិតណា?

២.តើចំណុចណាខ្លះក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន មានបញ្ហាប្រឈមជាងគេក្នុងការអនុវត្ត ហើយត្រូវមានដំណោះស្រាយយ៉ាងដូចម្តេច?

## ១.៦ ដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទ "**ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន នៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ**" ផ្តោតតែទៅលើគ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិចំនួនដប់ពីរស្ថិតក្នុងក្រុង/ស្រុកចំនួនបួនប៉ុណ្ណោះ រួមមាន៖ ក្រុងដូនកែវចំនួន៤សាលា ស្រុកបាទីចំនួន២សាលា ស្រុកសំរោងចំនួន២សាលា និងស្រុកអង្គរបូរីចំនួន៤សាលា ដោយផ្តោតតែទៅលើការបំពេញកម្រងសំណួរមួយ

មុខ មិនមានការសម្ភាស និងការសង្កេតថ្នាក់ឡើយ។ ចំណែកឯរយៈពេលក៏ខ្លី ដោយសារការស្រាវជ្រាវនេះស្ថិតនៅក្នុងដំណាក់កាលនៃការរីករាលដាលជំងឺកូវីដ១៩។ ចំពោះសំណាកវិញក៏មានចំនួនត្រឹមតែ១៥០នាក់ អាចមិនតំណាងឱ្យគ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិទាំងមូលក្នុងខេត្តតាកែវ បើទោះបីអ្នកស្រាវជ្រាវខិតខំជ្រើសរើសធ្វើជាតំណាងក៏ដោយ។ ដូច្នេះ អ្នកស្រាវជ្រាវក្រោយៗអាចពង្រីកវិសាលភាពសំណាកនិងតំបន់ផ្សេងទៀតបាន ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា៥ជំពូក។ ជំពូកទី១ (សេចក្តីផ្តើម) បង្ហាញពីសាវតារនៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ ព្រមទាំងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។ ជំពូកទី២ (រំលឹកទ្រឹស្តី) អ្នកស្រាវជ្រាវលើកឡើងនូវទ្រឹស្តីចាស់ៗ ពីអ្នកសិក្សាស្រាវជ្រាវមុនៗ ហើយមានខ្លឹមសារទាក់ទងនឹងចំណុចទាំងអស់ដែលបានចោទឡើងក្នុងចំណោទបញ្ហា ដើម្បីលើកយកមកបង្ហាញ និងការពារអំណះអំណាងនៅក្នុងនិក្ខេបបទសម្រាប់ការស្រាវជ្រាវនិងការបង្កើតស្នាដៃថ្មី។ ជំពូកទី៣ (វិធីសាស្ត្រស្រាវជ្រាវ) បង្ហាញពីគម្រោងវិភាគឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រវិភាគទិន្នន័យ និងវិធីសាស្ត្រស្រាវជ្រាវដែលបញ្ជាក់ពីវិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីសាស្ត្រជ្រើសរើសគម្រូ និងប្រភេទគម្រូ។ ជំពូកទី៤ (លទ្ធផលនិងការពិភាក្សា) អ្នកស្រាវជ្រាវនឹងលើកយកទិន្នន័យដែលប្រមូលបានមកវិភាគនិងបកស្រាយ ដើម្បីរកឱ្យឃើញនូវចំណុចទាំងអស់ដែលបានចោទសួរក្នុងចំណោទបញ្ហា។ ជំពូកទី៥ (សេចក្តីសន្និដ្ឋាននិងសំណូមពរ) អ្នកស្រាវជ្រាវនឹងធ្វើការសន្និដ្ឋានលើគ្រប់ចំណុចដែលបានវិភាគខាងលើ ហើយផ្តល់ជាយោបល់ ធ្វើសំណូមពរទៅលើចំណុចមួយចំនួនដែលត្រូវកែលម្អ ដើម្បីជាការចូលរួមចំណែក ក្នុងការអភិវឌ្ឍគ្រឹះស្ថានសិក្សាសាធារណៈ នៅកម្រិតមធ្យមសិក្សាបឋមភូមិ ឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូក២៖ រំលឹកទ្រឹស្តី

## ២.១ និយមន័យពាក្យគន្លឹះ

### ២.១.១ បញ្ញត្តិស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

**ក.និយមន័យស្តង់ដា**

ពិតហើយថា ការកំណត់បរិមាណនិងគុណភាពផលិតផលមួយ វាអាស្រ័យមួយផ្នែកធំទៅលើបុគ្គល ឬមនុស្សមួយក្រុមដែលគេកំណត់យកជាស្តង់ដា។ អ្នកខ្លះប្រើពាក្យស្តង់ដា សម្រាប់កំណត់បរិមាណ។ ឧទាហរណ៍ ធ្វើការប្រាំពីរម៉ោងក្នុងមួយថ្ងៃជាស្តង់ដាមួយ។ ឯអ្នកខ្លះទៀត ប្រើពាក្យស្តង់ដាសម្រាប់កំណត់នូវគុណភាព។ ឧទាហរណ៍ គ្រូបង្រៀនមានគុណភាពលុះត្រាតែមានចំណេះដឹងលើមុខវិជ្ជាឯកទេស និងមានទេពកោសល្យក្នុងការបង្រៀន (MoEYS, 2011,p.3) ។

ម្យ៉ាងទៀត ស្តង់ដា គឺជាពាក្យកម្ចីមកពីភាសាបារាំង Standard ដែលមានន័យថានិយាម ឬបទដ្ឋាន។ ឧទាហរណ៍ ការសិក្សានេះគ្មានស្តង់ដា មានន័យថាការសិក្សានេះមិនស្របតាមនិយាម ឬក្បួនខ្នាតទូទៅរបស់ប្រទេសជាច្រើន។ អាចថាគុណភាពអន់ជាង របៀបបង្រៀនមិនច្បាស់លាស់ ឬម្យ៉ាងទៀត ការដឹកនាំគ្មានស្តង់ដាមានន័យថាការដឹកនាំ គ្មានគោរពតាមក្បួនខ្នាតអ្វីទាំងអស់ ឬអាចនិយាយបែបផ្សេងថា ដឹកនាំតាមរបៀបរញ៉េររញ៉ៃ ឬតាមអារម្មណ៍។ ដូច្នេះ យើងអាចទាញសេចក្តីសន្និដ្ឋានបានថា ស្តង់ដាជាគម្រូ ជាការកម្រិត ឬជាការឯកភាពគ្នារបស់ក្រុមមនុស្ស ឬប្រទេសមួយ ថាមានភាពសមរម្យ និងអាចទទួលយកបាន សម្រាប់ក្រុមមនុស្ស ឬប្រទេសនោះ។

**ខ.និយមន័យវិជ្ជាជីវៈ**

នៅក្នុងវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត ពាក្យ «វិជ្ជាជីវៈ» មានន័យថា មុខតំណែង មុខការឬរបរ សម្រាប់ចិញ្ចឹមជីវិត។ ឧទាហរណ៍ វិជ្ជាជីវៈអ្នករាជការ វិជ្ជាជីវៈខាងកសិកម្ម វិជ្ជាជីវៈខាងការអប់រំជាដើម។ វិជ្ជាជីវៈខាងអប់រំ មានន័យថាជាវិជ្ជាជីវៈដែលមានតួនាទីសំខាន់បំផុត ទាក់ទងទៅនឹងដំណើរការនៃការបង្រៀននិងរៀន និងការលើកកម្ពស់ការសិក្សា ក្នុងចំណោមអ្នកសិក្សា តាមវិធីបង្រៀនផ្សេងៗ បូកផ្សំជា មួយការទទួលខុសត្រូវខ្ពស់ចំពោះការងាររដ្ឋបាល ក្នុងស្ថាប័នអប់រំសាធារណៈ និងឯកជន សម្រាប់

ការអប់រំកុមារ ការអប់រំកម្រិតមូលដ្ឋាន និងការអប់រំឧត្តមសិក្សា។ ជាងនេះទៅទៀត វិជ្ជាជីវៈត្រូវតែគាំទ្រ និងអនុវត្តនូវសកម្មភាពទាក់ទងនឹងដំណើរការបង្រៀននិងរៀនដែលផ្តល់ការពិនិត្យតាមដានការងាររដ្ឋបាល និងការចូលរួមរបស់ភ្នាក់ងារអប់រំផ្សេងៗទៀត "(Sermsak,2005,p.1)"។

**គ.និយមន័យស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន**

ការកំណត់ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនពីប្រទេសមួយទៅប្រទេសមួយ ផ្អែកលើកត្តាជាច្រើន ដូចជាកត្តាបច្ចេកវិទ្យា សេដ្ឋកិច្ច សង្គម វប្បធម៌។ ដោយឡែកស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជា យើងបានកំណត់យកសមាសភាគធំៗបួនគឺ ចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ ហើយបានជ្រើសរើសសមត្ថភាពមួយចំនួនដែលក្រសួងចាត់ទុកថាជាសមត្ថភាពអប្បបរមា និងមានជំនឿជឿជាក់ថា គ្រូបង្រៀនទាំងអស់មានសមត្ថភាពដល់ស្តង់ដាអប្បបរមានេះ (MoEYS,2011)។

ម្យ៉ាងទៀតការកំណត់បញ្ញត្តិ ឬឱ្យនិយមន័យមានច្រើន។ ចំពោះស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនកម្ពុជាបានឱ្យនិយមន័យដោយកំណត់នូវចំណុចធំៗចំនួនបីគឺ៖

- ជាសេចក្តីអធិប្បាយសង្ខេប និងច្បាស់លាស់នូវទិដ្ឋភាពទាំងឡាយណាដែលគ្រូបង្រៀន ត្រូវយល់ដឹងនិងធ្វើ
- ជាការបញ្ជាក់ប្រាប់ពីអំពើ ឬសកម្មភាពរបស់គ្រូបង្រៀនដែលអាចអនុវត្តបាន ហើយមានឥទ្ធិពលទៅលើសិស្ស
- ជាឧបករណ៍សម្រាប់វាស់សមត្ថភាពស្តែងចេញរបស់គ្រូបង្រៀន (MoEYS,2011,p.6)។

## ២.១.២ សិទ្ធិ និងឋានៈរបស់គ្រូបង្រៀន

### ២.១.២.១ សិទ្ធិរបស់គ្រូបង្រៀន

គ្រូបង្រៀនមានករណីកិច្ចដ៏ធំធេងក្នុងការលើកកម្ពស់នូវយុត្តិធម៌សង្គម ឱ្យស្របទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក្នុងមាត្រាទី៦៥ ដែលបានចែងថា "រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះ បានទៅដល់ប្រជាពលរដ្ឋគ្រប់រូប។ រដ្ឋយកចិត្តទុកដាក់លើ

វិស័យអប់រំកាយ និងកីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប" (MoEYS,2010,p.2) ។ ដូច្នេះ គ្រូបង្រៀនត្រូវមានភារកិច្ចសំខាន់ក្នុងការផ្ទេរចំណេះដឹងដល់សិស្ស ដោយ "គ្រូបង្រៀនត្រូវយកចិត្តទុកដាក់ក្នុងការពន្យល់ ការបកស្រាយ និងសម្របសម្រួលដល់អ្នកសិក្សា នូវចំណេះដឹងនានា ស្របតាមមុខវិជ្ជា ឬឯកទេសរបស់ខ្លួន"(MoEYS,2008,p.9) ។ ជាការចាំបាច់ គ្រូបង្រៀនត្រូវផ្តល់លទ្ធភាពក្នុងការសម្របនូវកម្មវិធីសិក្សាឱ្យស្របនឹងបរិបទសិក្សារបស់សិស្ស ធ្វើដូច្នេះពួកគាត់អាចចូលរួមយ៉ាងសកម្មក្នុងការកែលម្អកម្មវិធីសិក្សា (Johns, 2002)។

ជាងនេះទៅទៀត រដ្ឋបានផ្តល់នូវការអភិវឌ្ឍចំណេះដឹងដល់ពលរដ្ឋទូទាំងប្រទេសដែលមានចែងក្នុងមាត្រាទី៦៦ នៃច្បាប់រដ្ឋធម្មនុញ្ញ។ " រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូប មានភ័ព្វសំណាងគ្រប់គ្រាន់ស្មើគ្នា ក្នុងការកសាងជីវិត" )MoEYS, 2010,p.2)។ដើម្បីធានាបាននូវគុណភាពអប់រំ និងសិទ្ធិសេរីភាពក្នុងការសិក្សា គ្រូបង្រៀនត្រូវតែផ្តល់ឱកាសដល់សិស្ស គ្រប់រូប ដោយមិនប្រកាន់វណ្ណៈ មានន័យថា "គ្រូបង្រៀនមានករណីយកិច្ចជួយអ្នកសិក្សាមាតាបិតា និងអ្នក អាណាព្យាបាល អ្នកសិក្សាដោយមិនរើសអើង។ គ្រូបង្រៀនត្រូវជួយបង្រៀនបន្ថែមដល់អ្នកសិក្សារៀនយឺត " (MoEYS,2008,p.9)។

លើសពីនេះទៅទៀត រដ្ឋក៏មានបំណងលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀនឱ្យមានសមត្ថភាពពេញលេញក្នុងការបង្រៀននិងរៀន ស្របនឹងមាត្រាទី៦៧ នៃច្បាប់រដ្ឋធម្មនុញ្ញ ដែលចែងថា "រដ្ឋអនុវត្តកម្មវិធីសិក្សានិងគោលការណ៍គរុកោសល្យទំនើប"។ គ្រូបង្រៀនត្រូវស្វ័យសិក្សា និងស្រាវជ្រាវសម្រិតសម្រាំងបង្កើនចំណេះដឹងរបស់ខ្លួន និងចូលរួមគ្រប់សកម្មភាពបណ្តុះបណ្តាលឱ្យបានជាប្រចាំ"(MoEYS,2008, p.6)។ ការទទួលស្គាល់ នូវអំណាចដ៏អស្ចារ្យរបស់គ្រូបង្រៀនគឺមានសារៈសំខាន់ក្នុងការធានានូវការអនុវត្តភារកិច្ច និងការទទួលខុសត្រូវលើការងារ (Ingersoll, 2007)។ អ្នកស្រាវជ្រាវជាច្រើនបានបញ្ជាក់ថាទំនាក់ទំនងដ៏មានសារៈសំខាន់នៃតុល្យភាពរវាងស្វ័យសិក្សារបស់គ្រូបង្រៀន និងការទទួលខុសត្រូវ គឺជាមុខងារពិសេស ក្នុងការបង្រៀននិងរៀន )Gutman,1999)។ លោក Pearson & Moomaw (2005)

បានរកឃើញថាសេរីភាពនៃការស្រាវជ្រាវវិជ្ជាជីវៈគ្រូបង្រៀន គឺមិនអាចកាត់ផ្តាច់បានពីមិត្តរួមអាជីព និងគណៈគ្រប់គ្រងសាលាដោយទុកពួកគាត់ឱ្យក្លាយជាអាជីពមួយដែលមានភាពឯកកោនោះទេ។ ការអភិវឌ្ឍនូវសមត្ថភាពអាជីពរបស់ខ្លួនដើម្បីបម្រើឱ្យការបង្រៀននិងរៀន ប្រកបដោយប្រសិទ្ធភាពគឺគ្រូបង្រៀនត្រូវស្វ័យសិក្សាឱ្យបានជាប្រចាំ )Steh & Pozarnik,2005)។

គ្រូបង្រៀន មានតួនាទីជាកម្លាំងស្នូលរបស់សាលាក្នុងការបង្ហាត់សិស្សក្នុងថ្នាក់នីមួយៗតាមកម្មវិធីសិក្សាប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំខែ តាមមុខវិជ្ជារបស់ខ្លួន និងតាមម៉ោងកំណត់របស់រដ្ឋ។ គ្រូបង្រៀនជាអ្នកបច្ចេកទេសដោយការបង្រៀនមានវិធីសាស្ត្រ និងចេះប្រើប្រាស់នូវចិត្តគរុកោសល្យ បូកផ្សំជាមួយការស្រាវជ្រាវរបស់ខ្លួនដើម្បីសម្រេចវត្ថុបំណងមេរៀន ។ គ្រូបង្រៀនត្រូវតែទទួលខុសត្រូវ ក្នុងការបញ្ចប់កម្មវិធីសិក្សាប្រកបដោយគុណភាព )MoEYS,2009)។ ក្នុងន័យនេះ គ្រូបង្រៀនគឺជាមនុស្សដែលស្រឡាញ់កុមារ ចេះស្គាល់គុណសម្បត្តិ និងគុណវិបត្តិរបស់កុមារ ហើយចាត់ទុកកុមារជាមនុស្សពុំទាន់មានការរីកចម្រើននូវបញ្ញាគ្រប់គ្រាន់ ឬគ្រប់លក្ខណៈ។ ក្នុងការរស់នៅ ការយល់ដឹង ការកើតទុក្ខព្រួយ ការសប្បាយរីករាយ ការគិតពិចារណារបស់កុមារមានលក្ខណៈដោយឡែកទៅតាមបែបរបស់គេ។ ដូច្នេះគ្រូបង្រៀនត្រូវតែមានការយល់ដឹងនូវការប្រតិបត្តិរបស់កុមារ ដែលត្រូវជៀសវាង និងមិនត្រូវគិតថាកុមារជាមនុស្សអាក្រក់ហើយត្រូវដាក់ទណ្ឌកម្ម ប្រើប្រាស់ពាក្យសម្តីមិនសមរម្យ ដែលជួនកាលឈានដល់ប្រើអំពើហិង្សាលើកុមារថែមទៀតនោះឡើយ (MoEYS,2002)។ លទ្ធភាពជួយសម្របសម្រួលរបស់គ្រូបង្រៀន ចំពោះសិស្សគឺជាជាតុដ៏សំខាន់សម្រាប់បង្កើនបរិយាកាសសិក្សាប្រកបដោយគុណភាព ហើយសិស្សមានអារម្មណ៍ទទួលបានការគាំទ្រជាកម្លាំងចិត្តក្នុងការចូលរួមរៀនសូត្រ ធ្វើកិច្ចការសាលា និងជាបទពិសោធន៍ ដើម្បីចូលរួមក្នុងការងារសង្គម (Bru, Stornes,Munthe, & Thuen, 2010)។ សរុបមក ក្នុងនាមជាអ្នកអប់រំ "គ្រូបង្រៀនត្រូវជៀសវាងការប្រព្រឹត្តអំពើទាំងឡាយណា ដែលធ្វើឱ្យអាប់ឱនដល់កិត្តិយស និងវិជ្ជាជីវៈរបស់ខ្លួន។ គ្រូបង្រៀនមិនត្រូវផ្តល់ការសម្រួលគ្រប់បែបយ៉ាង ដែលនាំឱ្យខ្លួនធ្វើខុសច្បាប់ និងបទបញ្ជាឡើយ"(MoEYS, 2008,p.9) ។

ការយកចិត្តទុកដាក់លើឱកាសអភិវឌ្ឍសមត្ថភាពរបស់គ្រូគឺជាទុនក្នុងការផ្លាស់ប្តូរនូវការបង្រៀន និងផលវិជ្ជមានសម្រាប់សិស្ស (Glatthom,1997)។ គ្រូបង្រៀនមានមុខងារពិសេស គឺការបង្រៀន និងការអប់រំ ដែលភារកិច្ចនេះទាមទារឱ្យគ្រូបង្រៀន ប្រើអស់កម្លាំងកាយចិត្ត និងកម្លាំងប្រាជ្ញា ដើម្បីពង្រីកព្រំដែន ចំណេះដឹងផ្ទាល់ខ្លួន សម្រាប់ធ្វើការផ្ទេរទៅឱ្យកុមារប្រកបដោយគុណភាព )MoEYS,2002)។ គំនិតភ្លឺថ្លា និងបញ្ញាវាងវៃនឹងកើតមានឡើងដល់គ្រូទាំងអស់ប្រសិនបើពួកគាត់មានការខិតខំថែបំប៉នសមត្ថភាពបន្ថែម ពោលគឺត្រូវចេះស្វែងរកការស្រាវជ្រាវចំណេះដឹង និងបច្ចេកទេសថ្មីៗបន្ថែមជាប្រចាំ។ សារៈសំខាន់មួយទៀតរបស់គ្រូបង្រៀនគឺត្រូវមានចំណេះដឹងទូលំទូលាយដើម្បីបង្រៀនតិច តែសិស្សទទួលបានចំណេះដឹងច្រើន និងជ្រៅជ្រះ ដោយត្រូវចេះអំពីរបៀបផ្ទេរចំណេះដឹងទៅឱ្យសិស្សបានសមស្រប និងចេះលើកទឹកចិត្តសិស្សឱ្យចាប់យកចំណេះដឹងនេះដោយខ្លួនឯងផ្ទាល់ (MoEYS,2002)។ លោក Glahorn (1997) បានលើកឡើងថា គ្រូដែលចូលរួមក្នុងសកម្មភាពអភិវឌ្ឍសមត្ថភាពរបស់ខ្លួនឱ្យមានចំណេះដឹងទូលំទូលាយ និងមានចំណេះដឹងលើឯកទេសរបស់ខ្លួនបានរឹងមាំឃើញថា ការសិក្សារបស់សិស្សក៏ទទួលបានលទ្ធផលល្អដែរ។

ការបង្រៀនទាមទារនូវការឈ្លាសវៃ ការប៉ិនប្រសប់ ការយោគយល់ និងគុណសម្បត្តិល្អរបស់គ្រូ ព្រោះការបង្រៀនជាវិទ្យាសាស្ត្រផង និងជាសិល្បៈផង ដែលទាមទារឱ្យគ្រូបង្រៀនមានសីលធម៌វិជ្ជាជីវៈបន្ថែមលើអ្វីដែលធ្លាប់ទទួលបានការហាត់ពត់លត់ដំ ទាំងផ្លូវកាយ និងផ្លូវចិត្តនៅគ្រឹះស្ថានបណ្តុះបណ្តាល (MoEYS,2002)។ លើសពីនេះ គ្រូបង្រៀនត្រូវតែជាគម្រូ និងមានភាពឈ្លាសវៃក្នុងការបញ្ជ្រាបនូវខ្លឹមសារមេរៀន ទោះបីមេរៀនឬសៀវភៅអានមានខ្លឹមសារពុំសូវទាក់ទងនឹងស្ថានភាពរស់នៅឬមានខ្លឹមសារពុំសូវល្អគ្រប់គ្រាន់ក៏ដោយ ក៏គ្រូបង្រៀនគួរលៃយ៉ាងណារៀបចំសកម្មភាពសិក្សា និងអាកប្បកិរិយាជាគម្រូក្នុងការចម្លងនូវចំណេះដឹងដល់សិស្សគ្រប់ៗរូប (MoEYS, 2002)។ ផ្ទុយទៅវិញ ដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព គ្រូបង្រៀនត្រូវតែមានប្រព័ន្ធមួយដែលមានភាពជឿជាក់ និងមានតម្លៃស្នូលមួយដែលយកចិត្តទុកដាក់ និងផ្តល់តម្លៃដល់ការបង្រៀននិងរៀន (Levy & Murnane,2004)។ ការជួយ គាំទ្រ និងការណែនាំពីសហសេវិក និងគណៈគ្រប់គ្រង ផ្តល់នូវការយល់ដឹងពីអាជីពរបស់ខ្លួនបាន

ច្បាស់លាស់ និងការគោរពនូវមុខងាររបស់ខ្លួនដោយផ្សារភ្ជាប់នឹងស្ថានភាពពិត។ ការអភិវឌ្ឍនូវសមត្ថភាព នេះជាដំណោះស្រាយជួយចម្លង និងបំពេញនូវចន្លោះប្រហោងរវាងការរំពឹងទុកនូវអាជីពរបស់ខ្លួន និង ជោគជ័យការងារដែលជាធាតុដ៏សំខាន់សម្រាប់អង្គភាពសាលារៀន(Crokett,2007)។ គ្រូបង្រៀនក៏អាច បង្កើន ចំណេះដឹងតាមរយៈសកម្មភាពសិក្សាបន្ថែមក្រៅផ្លូវការ ដូចជាអំឡុងពេលញុំាអាហារជុំគ្នា វគ្គបំប៉ន ខ្លីៗ ក្លឹបសិក្សាដែលជាដំណើរការសិក្សាពេញមួយជីវិត ហើយមានភាពចាំបាច់សម្រាប់មនុស្សគ្រប់រូប និង ការ បង្កើនចំណេះដឹង ជំនាញ និងឥរិយាយបថជាដើម (Bhola,1983)។ អាជីពគ្រូបង្រៀនមានទំនាក់ ទំនងគ្នានឹងការសិក្សាបន្ថែម ព្រោះបើក្លាយជាគ្រូបង្រៀនពុំទាន់មានចំណេះដឹងពេញលេញនោះទេ គឺគ្រូ ត្រូវរក ឱកាសសិក្សាបន្ថែមនិងបង្កើននូវទំនាក់ទំនងជាមួយអ្នកដែលមានអាជីពដូចគ្នា(Murphy,1998)។ ជាង នេះទៅទៀត លោក Cooper & Miller (1998) បានធ្វើការសិក្សាទៅលើឥទ្ធិពលដែលជួយបង្កើន ការ អភិវឌ្ឍសមត្ថភាពដោយសិក្សាលើគ្រូចំនួន៣៨២រូប ហើយបានរកឃើញថា អ្នកពាក់ព័ន្ធដែលមាន ឥទ្ធិ ពលទាំងវិជ្ជមាន និងអវិជ្ជមានរួមមាន គណៈគ្រប់គ្រង៦៩% សមាជិកមកពីសាកលវិទ្យាល័យ១៨% សហការី រួមអាជីព៨% និងសមាគមន៍វិជ្ជាជីវៈ៤% ។

### ២.១.២.២ ឋានៈរបស់គ្រូបង្រៀន

គ្រូបង្រៀនត្រូវបានសង្គមចាត់ទុកថាជាភ្នាក់ងារផ្តល់នូវចំណេះដឹង និងជាអ្នកអាណាព្យាបាលទី២ របស់សិស្សានុសិស្សគ្រប់ៗរូប ព្រោះថាមនុស្សគ្រប់រូបត្រូវតែឆ្លងកាត់នូវការសិក្សា និងការអប់រំជាមួយគ្រូ ផ្ទាល់ តាមលក្ខណៈជាប្រព័ន្ធ និងត្រឹមត្រូវ។ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ចក្ខុវិស័យកសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ លើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យ ក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន ″(MoEYS,2010,p.4)។ ម្យ៉ាង ទៀត គ្រូបង្រៀនជាបុគ្គលិកអប់រំដែលរដ្ឋមានការយកចិត្តទុកដាក់។ បុគ្គលិកអប់រំត្រូវឆ្លងកាត់ការបណ្តុះ បណ្តាលទាំងមុនពេល និងឬក្នុងពេលកំពុងបម្រើការងារ។ បុគ្គលិកអប់រំ ត្រូវឆ្លងកាត់ការបណ្តុះបណ្តាល គរុកោសល្យ ដែលទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យអប់រំ។ លើសពីនេះទៀត ក្រសួងទទួល

បន្ទុក វិស័យអប់រំត្រូវកំណត់កម្មវិធីគោលសម្រាប់ការបណ្តុះបណ្តាលបុគ្គលិកអប់រំ កំណត់កាយសម្បទា និងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈ សម្រាប់ការជ្រើសរើសបុគ្គលិកអប់រំសាធារណៈ និងឯកជន (MoEYS, 007 ,p.7)។

ទិន្នន័យពីអ្នកស្រាវជ្រាវ Saifer, Edward, Ellis, Ko & Stuczynski (2011) បានបង្ហាញថា កម្មវិធីអប់រំគ្រូបង្រៀនត្រូវរកវិធីគ្រប់បែបយ៉ាង ដើម្បីបណ្តុះអ្នកអប់រំនៅថ្ងៃអនាគត អាចបង្រៀនក្មេងៗគ្រប់សមាសភាគបាន និងអាចដោះស្រាយបញ្ហាប្រឈមដែលគេជួបប្រទះ។ ដើម្បីទទួលបាននូវការបង្រៀន និងរៀនមានភាពល្អប្រសើរ បរិស្ថានសិក្សាឆ្លើយតបនឹងការរំពឹងទុក ក៏ដូចជាតម្រូវការរបស់សិស្ស គ្រូបង្រៀនត្រូវការជាចាំបាច់នូវការបណ្តុះបណ្តាលខ្លឹមសារមួយចំនួនដូចជា ការប្រើប្រាស់នូវបច្ចេកវិទ្យាព័ត៌មាន កម្មវិធីថ្មីៗ និងវិធីសាស្ត្របង្រៀនទាក់ទងនឹងភារកិច្ចរបស់ខ្លួន ពីព្រោះការអភិវឌ្ឍអាជីពមិនមែននៅនឹងមួយកន្លែងនោះទេ គឺត្រូវធ្វើការពង្រីកទំហំចំណេះដឹង និងជំនាញផ្សេងៗបន្ថែម (Winstone & Creamer,1998)។ ការបណ្តុះបណ្តាលដំបូងចំពោះគ្រូបង្រៀនគឺត្រូវរំពឹងទុកនូវសមត្ថភាពបង្រៀនពេញលេញដូចជា៖

- ❖ ធ្វើឱ្យគ្រូមានចំណេះដឹងទូទៅ និងចំណេះដឹងលើមុខវិជ្ជាឯកទេស ត្រូវបង្រៀនសិស្សឱ្យរឹងមាំ
- ❖ មានបំណិនវិជ្ជាជីវៈច្បាស់លាស់ ជាពិសេសគឺវិធីសាស្ត្របង្រៀន និងការគ្រប់គ្រងថ្នាក់រៀន និងមានទម្លាប់ស្វ័យពង្រឹងវិជ្ជាជីវៈបង្រៀន តាមរយៈការសិក្សាស្រាវជ្រាវ។
- ❖ មានមនសិការវិជ្ជាជីវៈខ្ពស់ សីលធម៌វិជ្ជាជីវៈ គុណធម៌ និងចេះរួមរស់ជាមួយអ្នកដទៃ។
- ❖ មានសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងជាមួយសាលារៀន និងសហគមន៍។
- ❖ មានទំនាក់ទំនងល្អរវាងសាលារៀន និងសហគមន៍ ស្មារតីចូលរួមអភិវឌ្ឍមូលដ្ឋាន និងប្រទេសជាតិ។
- ❖ មានស្មារតីចូលរួមអភិវឌ្ឍសហគមន៍ ពិសេសចេះអប់រំកុមារគ្រប់ស្រទាប់វណ្ណៈឱ្យក្លាយជាយុវជនមានសមត្ថភាព មានសីលធម៌ និងគុណធម៌ល្អ (MoEYS,2010,p.7)។

ទាក់ទងនឹងការអភិវឌ្ឍអាជីព គ្រូបង្រៀនត្រូវចូលរួមវគ្គបំប៉ន សិក្ខាសាលា និងសមាជដែលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជួយដល់គ្រូបង្រៀនឱ្យយល់ និងស្រឡាញ់អាជីពរបស់ខ្លួនដោយលើកកម្ពស់ជំនាញគ្រប់គ្រង ផ្តល់ការគាំទ្រគ្រប់បែបយ៉ាង ជំរុញការអភិវឌ្ឍសមត្ថភាព ជំនាញ និងធ្វើការស្វែងយល់នូវបញ្ហាសង្គម វប្បធម៌ និងនយោបាយដែលមានឥទ្ធិពលលើការអប់រំ (Henning, Kenedy,Cilente, & Sloane,2010)។ លើសពីនេះទៅទៀត ការប្រជុំគរុកោសល្យក៏ជាផ្នែកមួយនៃការបណ្តុះបណ្តាលបន្តដល់គ្រូបង្រៀន ដែលរៀបចំឡើងដោយនាយកសាលាក្នុងការលើកកម្ពស់គុណភាពគ្រូបង្រៀន។ នាយកសាលាគ្រប់រូបត្រូវមានភារកិច្ចចុះធ្វើអធិការកិច្ចគ្រូបង្រៀននិងបំប៉ន តាមរយៈការដឹកនាំ ការប្រជុំគរុកោសល្យក្នុងគោលបំណងជួយលើកកម្ពស់គុណភាពនៃការបង្រៀន និងរៀនរបស់គ្រូ ហើយតាមរយៈការប្រជុំនេះដែរគ្រូបង្រៀននឹងទទួលបាននូវប្រយោជន៍យ៉ាងច្រើនដូចជា៖

- ជួយបំប៉នគ្រូបង្រៀនជាទ្រង់ទ្រាយធំ លើផ្នែកចំណេះដឹង និងបំណិនផ្សេងៗតាមរយៈការដកស្រង់បទពិសោធន៍ពីគ្នាទៅវិញទៅមក និងការផ្សព្វផ្សាយចំណេះដឹងថ្មីៗ។

- ពង្រឹងសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនដើម្បីឱ្យគាត់បំពេញភារកិច្ចបានល្អតាមរយៈការណែនាំរៀនសូត្រផ្សព្វផ្សាយនូវបទប្បញ្ញត្តិ បទបញ្ជារ សារាចរ សេចក្តីណែនាំរបស់ក្រសួង និងខ្លឹមសារមួយចំនួនដែលពាក់ព័ន្ធដល់ការពង្រឹងមនសិការវិជ្ជាជីវៈរបស់គ្រូបង្រៀន។

- ពង្រឹងការងារជំនាញដែលពាក់ព័ន្ធដល់ការបង្រៀន និងរៀន។

- ជួយការងារគ្រប់គ្រងថ្នាក់ ក្រៅថ្នាក់និងក្រៅសាលា (MoEYS,2009,p.107)។

តាមរយៈសក្តានុពលរបស់គ្រូបង្រៀនទៅលើវិស័យអប់រំ មាត្រាទី២១នៃច្បាប់ស្តីពីការអប់រំបានលើកឡើងថា"រដ្ឋត្រូវលើកកម្ពស់គុណភាពអប់រំ ដើម្បីបំពេញសេចក្តីត្រូវការខាងការសិក្សាជាមូលដ្ឋាន និងសេចក្តីត្រូវការជំនាញសម្រាប់ធ្វើឱ្យអ្នកសិក្សាមានសមត្ថភាព និងលទ្ធភាពចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិប្រកបដោយប្រសិទ្ធភាព"(MoEYS,2007,p.7)។ ជាងនេះទៅទៀត ការអភិវឌ្ឍសមត្ថភាពអាជីពគិតទាំងមានផែនការ មិនមានផែនការ បទពិសោធន៍ជាផ្លូវការ និងមិនផ្លូវការ ដែលអាចជួយធ្វើឱ្យប្រសើរឡើងនូវអាជីពរបស់ខ្លួន(Schwartz & Bryan,1998)។ នេះសបញ្ជាក់ឱ្យឃើញថាគ្រូបង្រៀនត្រូវបានចាត់ទុក

ថាជាមនុស្សសំខាន់បំផុតក្នុងសង្គម ដែលមនុស្សគ្រប់រូបត្រូវតែឱ្យតម្លៃ និងរដ្ឋត្រូវតែយកចិត្តទុកដាក់ ដោយមិនត្រឹមតែផ្តល់នូវការបណ្តុះបណ្តាលដំបូងទេ ថែមទាំងផ្តល់នូវការបណ្តុះបណ្តាលបន្តដល់ពួកគាត់ ដែលកំពុងបម្រើការងារថែមទៀតផង ដើម្បីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនឱ្យដល់កម្រិតស្តង់ដាមួយដែល ក្រសួងចង់បាន និងមានការឯកភាពគ្នាទូទាំងប្រទេស។

គ្រូបង្រៀនមិនត្រឹមតែផ្តល់នូវចំណេះដឹងប៉ុណ្ណោះទេ ថែមទាំងផ្តល់នូវការអប់រំសីលធម៌ និងឥរិយាបថដល់សិស្សថែមទៀតផង។ គ្រូបង្រៀនត្រូវស្តាប់ ពិនិត្យ ឱ្យដំបូន្មាន ឬធ្វើជាអាណាព្យាបាលដល់អ្នកសិក្សាទូទៅដោយមិនលម្អៀង និងមិនប្រកាន់អំពីប្រភព អាយុ ភេទ ភាសា ពូជសាសន៍ ដើមកំណើត ជាតិ ពណ៌សម្បុរ ពិការភាព យេនឌ័រ ជំនឿ សាសនា និន្នាការនយោបាយ ឬឋានៈសង្គម ធនធាន ឬស្ថាន ភាពឯទៀតនៅក្នុងការអប់រំ និងសេវាអប់រំ˝ (MoEYS,2008,p.5-6)។ ការចាប់ផ្តើមបន្តិចម្តងៗរបស់គ្រូ នឹងធ្វើឱ្យកុមារជួបផ្ទាល់ និងចេះរស់នៅក្នុងតថភាពជាក់ស្តែង ចេះដកស្រង់បទពិសោធន៍គ្រប់យ៉ាងដើម្បី ពង្រឹងចំណេះដឹង ពង្រីកសម្បទា និងបំណិនប្រសប់របស់ពួកគេបានយ៉ាងងាយ។ លើសពីនេះទៅទៀត គួរ ចាប់អារម្មណ៍ថា ប្រសិនបើគ្រូគិតតែលើការបង្រៀនមួយមុខនិងអប់រំកុមារនៅក្នុងថ្នាក់ ដោយមិនពង្រឹងការយល់ដឹងរបស់ខ្លួនឱ្យបានទូលំទូលាយអំពីបញ្ហាសង្គមទេ សាលារៀនក៏ពុំអាចធានាបាននូវការសម្រេចគោលដៅអប់រំជាតិដែលផ្តល់នូវធនធានមនុស្សពេញលេញ ក្នុងការអភិវឌ្ឍប្រទេសជាតិ និងសម្រេចទិសដៅនៃការអប់រំសម័យទំនើបបានដែរ (MoEYS,2002)។ ជារួម គ្រូបង្រៀនមានតួនាទីសំខាន់បំផុតក្នុងសង្គម ហើយពួកគាត់ត្រូវមានការទទួលខុសត្រូវខ្ពស់និងធ្ងន់ធ្ងរ ព្រមទាំងត្រូវបំពេញភារកិច្ចដ៏ថ្លៃថ្លា ដើម្បីអនាគតប្រទេសជាតិ។

គ្រូបង្រៀនមានភារកិច្ចចូលរួមកសាងផែនការបង្រៀន ជាមួយប្រធានក្រុមបច្ចេកទេស និងអនុវត្តឱ្យសម្រេចបាននូវផែនការបង្រៀនរបស់ខ្លួន។ ពេលចាប់ផ្តើមបវេសនកាលនៃឆ្នាំនីមួយៗ គ្រូបង្រៀន និងប្រធានក្រុមបច្ចេកទេសត្រូវរៀបចំផែនការបង្រៀន ដែលក្នុងផែនការនោះ មានផែនការប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំត្រីមាស ប្រចាំខែ និងប្រចាំសប្តាហ៍..... ហើយគ្រូបង្រៀនត្រូវចេះលៃលកកំណត់នូវការបញ្ចប់មេរៀន

របស់ខ្លួនឱ្យបានសមស្រប និងត្រូវចេះប្រើប្រាស់ពេលដែលនៅសល់ សម្រាប់ការរំឭកមេរៀនឡើងវិញ (MoEYS,2009)។

ប្រសិទ្ធភាពនៃតួនាទីរបស់គ្រូបង្រៀនក្នុងការអប់រំ អាស្រ័យទៅលើគុណសម្បត្តិដែលមានជាប់នឹងបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនដូចជា៖ មានការយល់ដឹងជ្រៅជ្រះ និងច្បាស់លាស់ព្រមទាំងមានការភ្ញាក់រឭកខ្ពស់ពីតួនាទីរបស់ខ្លួន ចេះបកស្រាយត្រឹមត្រូវពីគោលការណ៍អប់រំ បង្ហាញឱ្យឃើញពីរូបារម្មណ៍ គំនិតច្នៃប្រឌិតប្លែកៗ ចេះដឹកនាំសិស្សឱ្យធ្វើសកម្មភាពរៀនដោយខ្លួនឯង មានសេចក្តីក្លាហាន សាកល្បងប្រើប្រាស់ល្បិចបង្រៀនថ្មីៗ និងហ៊ានប្រើប្រាស់ល្បិចដែលខ្លួនបានរកឃើញ បន្តបង្កើនចំណេះដឹងផ្ទាល់ខ្លួនឥតឈប់ឈរ ស្វ័យវាយតម្លៃជានិច្ច ចងចាំជានិច្ចថា ឥទ្ធិពលរបស់ខ្លួនទៅលើសិស្ស បន្សល់ទុកស្នាមយ៉ាងជ្រាលជ្រៅមិនងាយបំភ្លេច(MoEYS,2002,p.17)។

## ២.២ គម្រូស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

### ២.២.១ ការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសមួយចំនួន

#### ក.ការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសអង់គ្លេស

ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសអង់គ្លេស មានការកំណត់នូវសមាសភាគធំៗចំនួនពីរ និងមានសេចក្តីណែនាំ(Preamble) លម្អិតអំពីការប្រើប្រាស់នូវស្តង់ដាទាំងពីរនេះ។ សមាសភាគទីមួយគឺផ្តោតទៅលើការបង្រៀន និងសមាសភាគទីពីរគឺផ្តោតទៅលើការអនុវត្តដែលទាក់ទងនឹងវិជ្ជាជីវៈ និងបុគ្គលិកលក្ខណៈផ្ទាល់ខ្លួន(Department for Education of UK,2011,p.5)។

ក្នុងផ្នែកទីមួយ ការបង្រៀនមានសូចនាករចំនួនប្រាំបី ដែលគ្រូបង្រៀនត្រូវអនុវត្តរួមមាន៖ (១) កំណត់នូវការរំពឹងខ្ពស់ ការទូន្មាន ការលើកទឹកចិត្តសិស្ស និងធ្វើឱ្យសិស្សខិតខំបញ្ចេញអស់ពីសមត្ថភាពក្នុងការសិក្សា (២) លើកកម្ពស់នូវវឌ្ឍនៈភាព និងលទ្ធផលល្អសម្រាប់សិស្ស (៣) ចង្អុលបង្ហាញនូវមុខវិជ្ជាសិក្សា និងចំណេះដឹងក្នុងកម្មវិធីសិក្សា (៤) រៀបចំកិច្ចតែងការ និងបង្រៀនតាមកិច្ចតែងការឱ្យបានល្អ (៥) សម្របការបង្រៀនរបស់ខ្លួន ដើម្បីឆ្លើយតបនឹងភាពខ្លាំង និងតម្រូវការរបស់សិស្ស (៦) មានការវាយ

តម្លៃប្រកបដោយភាពសុក្រឹត និងផ្លែផ្កា (៧) មានការគ្រប់គ្រងឥរិយាបថឱ្យមានប្រសិទ្ធភាព ដើម្បីធានាបាននូវបរិស្ថានសិក្សាល្អ និងមានសុវត្ថិភាព (៨) បំពេញនូវការទទួលខុសត្រូវអាជីពវិជ្ជាជីវៈរបស់ខ្លួនឱ្យបានទូលំទូលាយ

ក្នុងសមាសភាគទីពីរផ្តោតទៅលើការអនុវត្តដែលទាក់ទងនឹងវិជ្ជាជីវៈ និងបុគ្គលិកលក្ខណៈផ្ទាល់ខ្លួន ហើយមានសូចនាករចំនួនបួន៖ (១) គ្រូបង្រៀនត្រូវរំពឹងអនុវត្តបាននូវស្តង់ដារបស់ខ្លួន និងបទ បញ្ញាផ្ទៃក្នុង (២) គ្រូបង្រៀនត្រូវលើកកម្ពស់ទំនុកចិត្តសាធារណៈចំពោះអាជីព និងក្រមសីលធម៌ទាំងក្នុង និងក្រៅសាលា (៣) គ្រូបង្រៀនត្រូវមានការយល់ដឹងឱ្យបានប្រសើរទាក់ទងនឹងជំនឿរបស់សង្គមគោលនយោបាយ ការអនុវត្តអាជីពជាគ្រូបង្រៀន និងការរក្សាឱ្យបាននូវស្តង់ដារវត្តមាន និងភាពទៀងទាត់ក្នុងការបង្រៀន (៤) គ្រូបង្រៀនត្រូវតែមានការយល់ដឹងអំពីតួនាទី ក្នុងការបង្រៀន ឋានៈរបស់គ្រូបង្រៀន និងការទទួលខុសត្រូវរបស់ខ្លួន (Department for Education of UK,2011,p.5)។

**ខ.ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសអូស្ត្រាលី**

ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសអូស្ត្រាលីផ្តោតទៅលើសមាសភាគធំៗចំនួនបីគឺចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ និងការចូលរួមវិជ្ជាជីវៈ។

**ចំណេះដឹងវិជ្ជាជីវៈ**មាន២សមាសភាគរង និងមានសូចនាករចំនួន១២។ សមាសភាគរងទាំងពីរនោះរួមមាន៖ (១) ស្គាល់សិស្ស និងរបៀបរៀនរបស់សិស្ស និង (២) យល់នូវខ្លឹមសារ និងរបៀបបង្រៀននូវខ្លឹមសារទាំងនោះ (AITSL,2014,p,1-6)

**ការប្រតិបត្តិវិជ្ជាជីវៈ**មាន៣សមាសភាគរង និងមានសូចនាករចំនួន១៧។ សមាសភាគរងទាំងនោះគឺ៖ (១) មានផែនការ និងអនុវត្តផែនការឱ្យមានប្រសិទ្ធភាពក្នុងការបង្រៀននិងរៀន (២) បង្កើតនិងរក្សាបរិស្ថានសិក្សាប្រកបដោយការជួយ និងមានសុវត្ថិភាព និង (៣) វាយតម្លៃ ផ្តល់ព័ត៌មានត្រឡប់ និងធ្វើរបាយការណ៍អំពីការសិក្សារបស់សិស្ស (AITSL,2014,p,7-15)

**ការចូលរួមវិជ្ជាជីវៈ**មាន២សមាសភាគរង និងមានសូចនាករចំនួន៨។ សមាសភាគរងទាំងនោះរួមមាន៖ (១) ការចូលរួមក្នុងការសិក្សាវិជ្ជាជីវៈ និង (២) ការចូលរួមជាអាជីពជាមួយសហការី ឪពុកម្តាយសិស្ស អ្នកអាណាព្យាបាលសិស្ស និងសហគមន៍ (AITSL,2014,p. 15-19)។

**គ. ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសន័រវេ**

សម្រាប់ប្រទេសន័រវេ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន បានកំណត់នូវប្រាំពីរចំណុចធំៗជាស្តង់ដាដែលគ្រូត្រូវអនុវត្តឱ្យបាន៖ (១) ចំណេះដឹងឯកទេស (២) ការផ្ទេរចំណេះដឹង (៣) ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងឥរិយាបថផ្ទាល់ខ្លួន (៤) ការអភិវឌ្ឍ និងការសិក្សាស្រាវជ្រាវ (៥) ជំនាញក្នុងការទំនាក់ទំនង (៦) ការពិនិត្យតាមដាន វាយតម្លៃ និងផ្តល់ព័ត៌មានត្រឡប់ និង (៧) ការបង្កើតទំនាក់ទំនងសហប្រតិបត្តិការ (Idpnorway,2014)

ក្នុងស្តង់ដានីមួយៗ បានពណ៌នានូវចំណុចមួយចំនួន ដែលគ្រូបង្រៀនត្រូវអនុវត្ត តែពុំបានកំណត់សូចនាករ ជាចំនួនជាក់លាក់ ដើម្បីងាយស្រួលក្នុងការប្រតិបត្តិតាមនោះទេ។

**ឃ.ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសម៉ារីលែន (Maryland)**

ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន របស់ប្រទេសម៉ារីលែន ឬឱ្យឈ្មោះថាជាស្តង់ដាអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនផ្តោតទៅលើសមាសភាគធំៗពីរគឺស្តង់ដាខ្លឹមសារចំណេះដឹង និងស្តង់ដាដំណើរការបង្រៀន (MTPDS,2001)។ ក្នុងស្តង់ដានីមួយៗមានកំណត់នូវស្តង់ដារង និងពណ៌នានូវសូចនាករលម្អិត សំខាន់ៗ ដើម្បីផ្តល់ភាពងាយស្រួលដល់គ្រូបង្រៀនក្នុងការអនុវត្ត។

- ក្នុង"ស្តង់ដាខ្លឹមសារចំណេះដឹង"មានស្តង់ដារងចំនួនប្រាំមួយទៀតគឺ៖ (១) ចំណេះដឹង និងគុណភាព នៃការបង្រៀន (២) ការស្រាវជ្រាវ (៣) ការសហប្រតិបត្តិការ (៤) តម្រូវការសិក្សាផ្សេងៗគ្នា (៥) បរិស្ថានសិក្សារបស់សិស្ស និង (៦) ការចូលរួមរបស់ឪពុកម្តាយសិស្ស។
- ក្នុង "ស្តង់ដាដំណើរការបង្រៀន" មានស្តង់ដារងចំនួនបីគឺ៖ (១) ការវិភាគលើទិន្នន័យ (២) ការវាយតម្លៃ និង (៣) ការរៀបចំ និងការសិក្សារបស់សិស្ស (MTPDS,2001)។

**ង.ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសថៃ**

បទប្បញ្ញត្តិ នៃក្រុមប្រឹក្សាគ្រូបង្រៀនរបស់ប្រទេសថៃ លើស្តង់ដាវិជ្ជាជីវៈ និងក្រមសីលធម៌របស់គ្រូបង្រៀនគឺសំដៅទៅលើបុគ្គលិកបង្រៀន និងអ្នករដ្ឋបាលអប់រំ។ ស្តង់ដានេះ ចែកចេញជាពីរជំពូក ដែលជំពូកទីមួយស្តីអំពីស្តង់ដាចំណេះដឹងវិជ្ជាជីវៈនិងបទពិសោធន៍ការងារ និងជំពូកទីពីរស្តីអំពីស្តង់ដានៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀន(Semsak,2005)។

សម្រាប់បុគ្គលិកបង្រៀនក្នុងជំពូកទីមួយ"ស្តង់ដាចំណេះដឹងវិជ្ជាជីវៈ និងបទពិសោធន៍ការងារ"ចែកចេញជាពីរសមាសភាគធំៗគឺ៖

**(១) ស្តង់ដានៃចំណេះដឹង**

- ភាសា និងបច្ចេកវិទ្យាសម្រាប់គ្រូបង្រៀន
- ការអភិវឌ្ឍកម្មវិធីសិក្សា
- ចិត្តវិទ្យាសម្រាប់គ្រូបង្រៀន
- ការវាស់វែង និងវាយតម្លៃការអប់រំ
- ការគ្រប់គ្រងថ្នាក់
- ការស្រាវជ្រាវក្នុងវិស័យអប់រំ
- ការបញ្ចូលរបៀបថ្មី និងព័ត៌មានបច្ចេកវិទ្យា
- មិត្តភាពគ្រូបង្រៀន

**(២)ស្តង់ដានៃបទពិសោធន៍វិជ្ជាជីវៈ** គឺមានន័យថា គ្រូបង្រៀនត្រូវតែបានបញ្ចប់ជាស្ថាពរនូវការបណ្តុះបណ្តាលក្នុងស្ថាប័នអប់រំគ្រូបង្រៀន ដែលឆ្លងកាត់កម្មវិធីបណ្តុះបណ្តាលពេញមួយឆ្នាំ និងទទួលបានលទ្ធផលបញ្ចប់ជាប់ជាស្ថាពរ ដែលលទ្ធផលនៃការសិក្សានេះត្រូវបានវាយតម្លៃ ដោយស្ថាប័នបណ្តុះបណ្តាលដែលពាក់ព័ន្ធនឹងច្បាប់ ដំណើរការ និងលក្ខខណ្ឌដែលបានកំណត់ ដោយក្រុមប្រឹក្សាគ្រូបង្រៀនរបស់ប្រទេសថៃ (Sermsak,2005,p.3)។

ក្នុងជំពូកទីពីរ "ស្តង់ដានៃការប្រតិបត្តិ" គ្រូបង្រៀនត្រូវអនុវត្តដូចខាងក្រោម៖

- អនុវត្តសកម្មភាពបង្រៀនជាប្រចាំស្របនឹងការអភិវឌ្ឍសមត្ថភាពរបស់គ្រូ
- មានការសម្រេចចិត្តអនុវត្តសកម្មភាពគ្រប់បែបយ៉ាង ដោយលៃយ៉ាងណាត្រូវគិតពីភាពទាក់ទងគ្នានូវខ្លឹមសារមេរៀនសម្រាប់អ្នកសិក្សា
- ប្ដេជ្ញាអភិវឌ្ឍអ្នកសិក្សាឱ្យសម្រេចនូវសក្ដានុពល
- អភិវឌ្ឍផែនការបង្រៀនសម្រាប់ការប្រតិបត្តិការបង្រៀនប្រកបដោយប្រសិទ្ធភាព
- អភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយការបង្រៀនឱ្យមានប្រសិទ្ធភាព
- រៀបចំសកម្មភាពបង្រៀនដោយផ្ដោតទៅលើលទ្ធផលអភិវឌ្ឍជាអចិន្ត្រៃយ៍របស់សិស្ស
- ធ្វើរបាយការណ៍អំពីគុណភាពនៃការសិក្សារបស់សិស្សដែលមានលក្ខណៈជាប្រព័ន្ធ
- អនុវត្តជាគម្រូល្អសម្រាប់អ្នកសិក្សា
- បង្កើនទំនាក់ទំនងសហប្រតិបត្តិការជាមួយស្ថាប័នអប់រំដទៃទៀត
- បង្កើនទំនាក់ទំនងសហប្រតិបត្តិការជាមួយសហគមន៍
- ស្វែងរក និងប្រើប្រាស់ព័ត៌មានសម្រាប់ការអភិវឌ្ឍ
- បង្កើតឱកាសសម្រាប់អ្នករៀនធ្វើការសិក្សាទៅតាមកាលៈទេសៈ (Sermsak,2005,p.4)។

## ច. ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនកម្ពុជា

ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់កម្ពុជាយើង បានកំណត់យកសមាសភាគធំៗចំនួន៤ គឺចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ ដែលសមាសភាគនីមួយៗ មានអនុសមាសភាគជាច្រើន ហើយនៅក្នុងអនុសមាសភាគនីមួយៗមានសេចក្តីពណ៌នាពីសូចនាករនីមួយៗ និងបានបញ្ជាក់ពីសមត្ថភាពលម្អិតតូចៗបន្តទៀត។

### (១) ចំណេះដឹងវិជ្ជាជីវៈ

ចំណេះដឹងវិជ្ជាជីវៈរបស់គ្រូបង្រៀន សំដៅលើចំណេះដឹងផ្នែកឯកទេសរបស់គ្រូបង្រៀន និងមានចំណេះដឹងទូទៅផ្សេងៗទៀតដ៏សម្បូរបែបដូចជា៖យល់ច្បាស់ពីតម្រូវការនៃការសិក្សាបន្ថែម ប្រវត្តិសិក្សា និងឥរិយាបថសិស្សម្នាក់ៗ ព្រមទាំងធ្វើការស្វែងយល់ពីប្រវត្តិរបស់សិស្ស ស្ថានភាពគ្រួសាររបស់សិស្ស និង

កត្តាផ្សេងៗដទៃទៀតដែលមានឥទ្ធិពលលើការសិក្សារបស់សិស្សដូចជាបញ្ហាយេនឌ័រ កត្តាសង្គមសេដ្ឋកិច្ច ពិការភាពរបស់សិស្ស សិស្សជាជនជាតិភាគតិច និងតម្រូវការផ្សេងៗរបស់សិស្ស )MoEYS,2011)។

ម្យ៉ាងទៀត គ្រូបង្រៀនត្រូវធ្វើការសិក្សាពីគោលនយោបាយនានារបស់ក្រសួងអប់រំ យុវជន និងកីឡា ដូចជាគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងនៃការអប់រំចំណេះទូទៅ និងអាចរៀបរាប់បានពីវិធីផ្សេងៗ ដើម្បីធ្វើឱ្យសម្រេចបាននូវគោលនយោបាយទាំងនោះ (MoEYS,2011)។ យោងតាមមាត្រាទី៨នៃក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន "គ្រូបង្រៀនមានករណីយកិច្ចរៀបចំកិច្ចតែងការបង្រៀន និងកំណត់ការពន្យល់សំដៅជានាបាននូវគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន"(MoEYS,2008,p.6)។

លើសពីនេះទៅទៀត គ្រូបង្រៀនគួរតែយល់ស៊ីជម្រៅ ទៅលើកិច្ចតែងការបង្រៀន យល់ពីរបៀបកំណត់វត្ថុបំណងមេរៀន និងធាតុសំខាន់ៗដែលមានក្នុងកិច្ចតែងការបង្រៀន ហើយនឹងកំណត់វិធីសាស្ត្រក្នុងការបង្រៀន ដោយប្រើគោលវិធីសិស្សមជ្ឈមណ្ឌល។ មិនត្រឹមតែប៉ុណ្ណោះ គ្រូបង្រៀនត្រូវចេះអំពីរបៀបវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ថាតើសិស្សមានការយល់ដឹងកម្រិតណា ហើយលទ្ធផលនេះអាចទទួលយកបានដែរឬទេ និងមានវិធានការកែលម្អទាន់ពេលវេលា ព្រមទាំងមានការរៀបចំនូវសម្ភារៈបង្រៀន និងរៀនឱ្យសម្បូរបែប និងស្របតាមខ្លឹមសារមេរៀននីមួយៗ (MoEYS,2011)។

**(២) ការប្រតិបត្តិវិជ្ជាជីវៈ**

ការប្រតិបត្តិរបស់គ្រូប្រកបដោយប្រសិទ្ធភាព លុះត្រាគ្រូបង្រៀនបានត្រៀមនូវកិច្ចតែងការដែលមានកំណត់នូវជំហានទាំង៥ នៃសកម្មភាពបង្រៀន វិធីសាស្ត្របង្រៀន និងសម្ភារៈបង្រៀនច្បាស់លាស់ស្របតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយផ្អែកលើសៀវភៅសិក្សាគោលទាំងសិស្ស និងគ្រូ។ ដើម្បីសម្រេចបាននូវវត្ថុបំណងមេរៀន គ្រូត្រូវចេះច្នៃប្រឌិតសម្ភារៈបង្រៀនងាយៗ ដែលអាចរកបានក្នុងស្រុក ហើយរៀបចំសម្ភារៈបង្រៀន និងរៀនទាំងនោះ ប្រកបដោយប្រសិទ្ធភាព ដើម្បីដឹកនាំសិស្សទាំងអស់ទទួលបាននូវលទ្ធផលគួរជាទីពេញចិត្ត (MoEYS,2011)។ បន្ថែមលើនេះទៀត គ្រូបង្រៀនត្រូវមានវិធីសាស្ត្របង្រៀនសម្បូរបែប និងចេះធ្វើការពិនិត្យតាមដានលើលទ្ធផលសិក្សារបស់សិស្សឱ្យបានជា

ប្រចាំផងដែរ។ គ្រូបង្រៀនត្រូវកសាងសំណួរតេស្តដែលមានទម្រង់ងាយ និងរយៈពេលសមស្របសម្រាប់សិស្សឆ្លើយ។ គ្រូបង្រៀនត្រូវត្រៀមចម្លើយព្រាងទុកមុន និងធ្វើការកែចម្លើយរបស់សិស្សឱ្យបានត្រឹមត្រូវ និងបង្ហាញពីប្រសិទ្ធភាពនៃការបង្រៀន និងរៀន (MoEYS,2011)។

បន្ថែមពីនេះទៅទៀត គ្រូបង្រៀនត្រូវតាមដានការចូលរួមរបស់សិស្ស តាមរយៈការសង្កេត និងធ្វើកំណត់ត្រា និងថែរក្សាកំណត់ត្រារបស់សិស្សអំពីការចូលរួម និងសកម្មភាពរបស់ពួកគេ។ គ្រូបង្រៀនត្រូវផ្តល់ព័ត៌មានត្រឡប់ទៅសិស្ស មាតាបិតា ឬអាណាព្យាបាលសិស្សអំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថសិស្សដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ តាមរយៈសន្លឹកកិច្ចការ ឬទំនាក់ទំនងផ្សេងៗ ដូចជារបាយការណ៍ សៀវភៅតាមដានការសិក្សារបស់សិស្ស ឬទៅជួបផ្ទាល់ក្នុងករណីចាំបាច់ (MoEYS, 2011)។ បន្ទាប់មក គ្រូបង្រៀនត្រូវមានវិធីជួយសិស្សឱ្យមានការទទួលខុសត្រូវ ចំពោះការសិក្សារបស់ខ្លួន និងមានគំនិតចូលរួមអភិវឌ្ឍសាលា ដើម្បីទ្រទ្រង់ការសិក្សា និងសុខុមាលភាពរបស់សិស្សទាំងអស់ព្រមទាំងបុគ្គលិកអប់រំ ក្នុងសាលា។ គ្រូបង្រៀនត្រូវប្រើវិធីបង្រៀនផ្សេងៗ និងមានការផ្លាស់ប្តូរជាប្រចាំ ដូចជាការប្រើប្រាស់នូវវិធីអនុមានរួម អនុមានញែក ការងារក្រុម បុគ្គល និងពន្យល់បង្ហាញ អំពីការដោះស្រាយបញ្ហាផ្សេងៗ។ គ្រូបង្រៀនគួរជ្រើសរើសវិធីបង្រៀន ដោយគិតអំពីសិស្សផងដែរ ពីរបៀបរៀនរបស់សិស្សពូកែ សិស្សមធ្យម សិស្សខ្សោយ និងមុខវិជ្ជាដែលជាមធ្យោបាយដឹកនាំសិស្សឱ្យសម្រេចគោលដៅសិក្សា។ ការរៀបចំដូច្នេះ នឹងផ្តល់ឱកាសដល់សិស្សសិក្សាពីដំណោះស្រាយបញ្ហា ដើម្បីចូលរួមគិតឱ្យបានល្អិតល្អន់ប្រកបដោយភាពច្នៃប្រឌិត និងការបង្រៀនដោយប្រើនូវបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(ICT) (MoEYS,2011)។

គ្រូបង្រៀនក៏ត្រូវជៀសវាងនូវការប្រតិបត្តិមួយចំនួនដែលអាចប៉ះពាល់ដល់កិត្តិយសគ្រូបង្រៀនផងដែរ។ យោងតាមមាត្រាទី១២ នៃក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនចែងថា "គ្រូបង្រៀនមិនត្រូវសមគំនិតតាមផ្លូវកាយ ឬតាមផ្លូវចិត្ត ឬសម្ភារៈ ឬតាមរយៈការផ្តល់ជាមធ្យោបាយ ដែលធ្វើឱ្យខូចប្រយោជន៍អ្នកសិក្សា ក្នុងសេវាអប់រំឡើយ។ គ្រូបង្រៀនមិនត្រូវដាក់ទណ្ឌកម្មខាងផ្លូវកាយ និងផ្លូវចិត្តដែលនាំឱ្យមានផលប៉ះពាល់ដល់អ្នកសិក្សានោះទេ"(MoEYS,2008,p.8)។ គ្រូបង្រៀនជាមនុស្សប្រកាន់នូវអព្យាក្រឹតភាព

និងមានភាពសណ្ដោសប្រណីដល់សិស្ស និងជាអ្នកផ្ដល់នូវភាពយុត្តិធម៌ដល់សិស្ស ហើយមានសេចក្ដីថ្លៃថ្នូរដែលមនុស្សគ្រប់គ្នាគោរព និងស្រឡាញ់។ ដូច្នេះ "គ្រូបង្រៀនមិនត្រូវរៃអង្គាសប្រាក់ ឬប្រមូលប្រាក់ក្រៅផ្លូវការ ឬធ្វើអាជីវកម្មនានាក្នុងថ្នាក់រៀនឡើយ។ គ្រូបង្រៀន ត្រូវជៀសវាងការប្រកបមុខរបរផ្សេងៗក្នុងបរិវេណគ្រឹះស្ថានសិក្សា" (MoEYS,2008,p.8)។

**(៣) ការសិក្សាវិជ្ជាជីវៈ**

គ្រូបង្រៀនមានតួនាទីជាអ្នកលើកទឹកចិត្ត និងធានាបាននូវភាពជោគជ័យរបស់សិស្សក្នុងការសិក្សា។ ដើម្បីធានាបាននូវគុណភាពនៃការសិក្សារបស់សិស្សគ្រូបង្រៀនត្រូវចេះរៀបចំស្វ័យវាយតម្លៃការសិក្សារបស់សិស្ស ការបង្រៀន និងរៀនរបស់ខ្លួន និងមានផែនការសិក្សាច្បាស់លាស់ ដើម្បីអភិវឌ្ឍវិជ្ជាជីវៈផ្ទាល់ខ្លួនប្រកបដោយគុណភាព និងប្រសិទ្ធភាព (MoEYS,2011)។ លើសពីនេះទៀត គ្រូបង្រៀនក៏ត្រូវមានចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់អនុវត្តក្នុងការបង្រៀន និងរៀនរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។ គ្រូបង្រៀនត្រូវមានបំណិនក្នុងការទំនាក់ទំនងជាមួយសិស្ស មាតាបិតា មិត្តរួមអាជីព និងជាមួយអ្នកពាក់ព័ន្ធផ្សេងៗទៀតក្នុងសហគមន៍។ គ្រូបង្រៀនត្រូវលើកកម្ពស់សមត្ថភាពរបស់ខ្លួន តាមរយៈការស្រាវជ្រាវឯកសារបន្ថែម និងការអានសៀវភៅ ដើម្បីពង្រឹង និងពង្រីកចំណេះដឹងឱ្យបានទូលំទូលាយ ដើម្បីជួយកែលម្អការបង្រៀនរបស់ខ្លួន ដូចជាចេះរៀបចំធ្វើថ្នាក់និទស្សន៍បង្ហាញបទពិសោធន៍ដែលទទួលបានពីការអាន និងការស្រាវជ្រាវដល់មិត្តរួមអាជីព និងការកែលម្អគ្នាទៅវិញទៅមក។ ម្យ៉ាងទៀតគ្រូបង្រៀនត្រូវសិក្សាស្វែងយល់ឱ្យបានច្បាស់អំពីរបៀបធ្វើបញ្ជីផ្សេងៗ និងចេះយកបទពិសោធន៍ពីសិក្ខាសាលា ឬវគ្គបំប៉ននានា មកផ្សព្វផ្សាយបន្ត ដើម្បីបង្កើនសមត្ថភាពការបង្រៀននិងរៀនទាំងអស់គ្នា (MoEYS,2011) ។

**(៤) សីលធម៌វិជ្ជាជីវៈ**

គ្រូបង្រៀនល្អមិនត្រឹមតែមានចំណេះដឹងខ្ពង់ខ្ពស់ទេ ថែមទាំងមានសីលធម៌វិជ្ជាជីវៈដែលទាក់ទងនឹងទិដ្ឋភាពទាំងអស់ សំដៅដល់ទាំងក្នុងការបង្រៀន និងរៀន ទំនាក់ទំនងជាមួយមជ្ឈដ្ឋានខាងក្រៅ។ យោងតាមក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនមាត្រាទី២៦បានចែងថា "គ្រូបង្រៀនមិនត្រូវធ្វើឱ្យបាត់បង់មន

សិការវិជ្ជាជីវៈក្នុងការបំពេញករណីយកិច្ច និងកាតព្វកិច្ចរបស់ខ្លួនឡើយ ក្នុងការប្រកបវិជ្ជាជីវៈបង្រៀន ក្រោមកិច្ចសន្យា ឬលក្ខន្តិកៈជាមួយស្ថាប័នសាធារណៈឬ ស្ថាប័នឯកជន ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ"(MoEYS, 2008,p.13)។

គ្រូបង្រៀនត្រូវបង្ហាញពីការយកចិត្តទុកដាក់របស់ខ្លួន និងថែរក្សាសិស្សហើយជានិច្ចកាល ធ្វើការដើម្បីប្រយោជន៍សិស្ស និងសង្គម។ ត្រូវមានសីលធម៌និយាយទៅកាន់សិស្ស សហការី និងអ្នកឯទៀតនៅក្នុងសហគមន៍ដោយមានការគោរពនិងលើកទឹកចិត្ត បង្ហាញពីការគោរពសិទ្ធិកុមារ និងមិនត្រូវនិយាយមើលងាយ ឬដាក់ពិន័យដល់សិស្សតាមរបៀបអំពើហិង្សា។ គ្រូបង្រៀនត្រូវធ្វើការងារជាក្រុម ជាមួយសហការី និងសមាជិកសហគមន៍ឯទៀត ដើម្បីប្រយោជន៍សិស្ស (MoEYS,2011)។

គ្រូបង្រៀន ត្រូវបង្ហាញពីការប្តេជ្ញាចិត្ត និងចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ គ្រូត្រូវទៅបង្រៀន និងចូលរួមព្រឹត្តិការណ៍ផ្សេងៗឱ្យបានទៀងទាត់ និងទាន់ពេលវេលា បង្ហាញពីអាកប្បកិរិយារាក់ទាក់ និងចិត្តសប្បុរសធម៌។ គ្រូត្រូវធ្វើជាគម្រូក្នុងការបង្ហាញ ពីការគោរពសិស្ស សហការី និងអ្នកឯទៀតក្នុងសហគមន៍ និងបង្ហាញពីអារម្មណ៍ជក់ចិត្ត និងគំនិតផ្តួចផ្តើមលើគ្រប់ទិដ្ឋភាពនៃសកម្មភាពវិជ្ជាជីវៈ មានការយល់ដឹងស៊ីជម្រៅលើក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងច្បាប់ស្តីពីការអប់រំ (MoEYS,2011)។ ម្យ៉ាងទៀត គ្រូបង្រៀនត្រូវមានអាកប្បកិរិយាវិជ្ជមាន ប្រកបដោយសីលធម៌ និងមានទំនាក់ទំនងដោយសុខដុមជាមួយសិស្ស និងសហគមន៍។ គ្រូត្រូវរៀបចំខ្លួនឱ្យសក្តិសមជាអ្នកដែលមានអាជីពវិជ្ជាជីវៈដោយមានសម្លៀកបំពាក់សមរម្យបញ្ចេញនូវសមត្ថភាពដែលខ្លួនមាន ដើម្បីបង្កើនទំនាក់ទំនងល្អ និងផ្តល់តម្លៃសីលធម៌ទៅមាតាបិតាសិស្ស និងអ្នកដទៃទៀត។ ជាងនេះទៅ ទៀតគ្រូបង្រៀនត្រូវមានយុត្តិធម៌ និងតម្លាភាពក្នុងការប្រព្រឹត្តចំពោះសិស្ស សហសេវិក និងសមាជិក ផ្សេងៗ របស់សហគមន៍(MoEYS,2011)។

### ២.២.២ បញ្ហាប្រឈមរបស់សាលារៀន

#### ២.២.២.១ បញ្ហាប្រឈមមួយចំនួនរបស់គ្រូបង្រៀន នៅតាមបណ្ដាប្រទេសមួយចំនួន

កង្វះគ្រូបង្រៀនមានផលប៉ះពាល់ជាអវិជ្ជមានទៅលើគុណភាពអប់រំ ដែលធ្វើឱ្យកើនឡើងនូវចំនួនសិស្សក្នុងថ្នាក់នីមួយៗ និងការផ្លាស់ចេញនូវគ្រូល្អៗដែលមានសមត្ថភាពបង្រៀនខ្ពស់។ យោងតាមលោក Hammond & Berry (2006) រកឃើញថាគ្រូភាគច្រើនមិនចង់ទៅបម្រើការនៅជនបទទេ ដោយសារពួកគាត់យល់ឃើញថា តំបន់ទាំងនោះផ្ដល់នូវប្រាក់ខែទាប និងលក្ខខណ្ឌធ្វើការងារមិនសូវល្អដូចតំបន់ទីប្រជុំជន។ ជាងនេះទៅទៀត ផលវិបាកមួយដែលសំខាន់ ទាក់ទងនឹងការផ្ដល់ប្រាក់ខែទាបនៅតំបន់អាស៊ី កណ្ដាល បានធ្វើឱ្យកើនឡើងនូវចំនួនគ្រូជាច្រើនរកមុខរបរទីពីរ ដើម្បីជួយបំពេញបន្ថែម នូវតម្រូវការជីវភាពប្រចាំថ្ងៃ(UNESCO,2008)។ ការមិនពេញចិត្តនឹងលក្ខខណ្ឌដែលរដ្ឋផ្ដល់ឱ្យ និងឈានទៅរកមុខរបរទីពីរនេះ ធ្វើឱ្យគ្រូបង្រៀន ពុំមានពេលគ្រប់គ្រាន់សម្រាប់ត្រៀមមេរៀនបង្រៀនសិស្ស និងអភិវឌ្ឍនូវសមត្ថភាពខ្លួនឯងដែលធ្វើឱ្យពួកគាត់ឃ្លាតឆ្ងាយពីស្ដង់ដាវិជ្ជាជីវៈគ្រូបង្រៀន។

ការខ្វះខាតនូវការលើកទឹកចិត្តក្នុងអាជីពការងារអាចប៉ះពាល់ដល់អារម្មណ៍គ្រូបង្រៀនក្នុងការបំពេញការងារ និងទៅលើគុណភាពនៃការបង្រៀន និងរៀន។ លោក Rousseau(2012) បានរកឃើញថា ភាពមិនពេញចិត្តរបស់គ្រូចំពោះការងាររបស់គាត់ដូចជាអាជីពគ្រូបង្រៀន គឺជាព័ត៌មានដ៏អាក្រក់សម្រាប់សិស្សានុសិស្ស ក្នុងការជំរុញឱ្យពួកគាត់មានចំណង់ចំណូលចិត្តលើការសិក្សា។ សីលធម៌ និងការលើកទឹកចិត្តរបស់គ្រូ ដែលជាកត្តាដ៏សំខាន់អាចធ្វើឱ្យប៉ះពាល់ដល់ភាពខ្ពង់ខ្ពស់របស់គ្រូបង្រៀននៅក្នុងសង្គម(Baike,2002)។ ជាងនេះទៅទៀត Morgan & O′ Leary (2004) កត់សម្គាល់ឃើញថា មានភស្ដុតាងជាច្រើនដែលបញ្ជាក់ថានៅពេលគ្រូមានការពេញចិត្តនឹងការងារបង្រៀន និងរៀនរបស់ខ្លួន នាំឱ្យលទ្ធផលនៃការសិក្សារបស់សិស្សក៏កើនឡើងដែរ។ អ្នកស្រាវជ្រាវបានផ្ដល់ជាទស្សនៈថាការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងាររបស់គ្រូអាចជួយឱ្យគុណភាពអប់រំបានប្រសើរឡើងដែរ។ ជាពិសេស គួរបង្កើនការយកចិត្តទុកដាក់លើការផ្ដល់នូវការគាំទ្រដល់ការបង្រៀននិងរៀន ផ្ដល់នូវសម្ភារៈឧបទេសសម្បូរបែប

និងការតុបតែងបរិស្ថានថ្នាក់ឱ្យមានសោភ័ណ្ឌភាពតាមបែបគរុកោសល្យ ដើម្បីទាក់ទាញនូវការសិក្សារបស់សិស្ស(Sanusi,1998)។ លើសពីនេះទៅទៀត លោក Akinwumi(2000) បានកត់សម្គាល់ឃើញថា គ្រូបង្រៀនដែលបម្រើការងារនៅតាមសាលាឯកជន ទទួលបានការលើកទឹកចិត្តល្អប្រសើរជាងគ្រូបង្រៀនស្ថិតក្នុងសាលារដ្ឋ។ ការមិនយកចិត្តទុកដាក់ដល់គ្រូក៏ដូចជាពុំសូវមានការលើកទឹកចិត្ត ឱ្យសមនឹងតម្រូវការគ្រូចង់បានដូចជាប្រាក់ខែទាប និងបញ្ហាវិន័យសិស្សក្នុងតំបន់ជនបទជាកត្តាធ្លាក់ចុះ នូវប្រជាប្រិយភាពរបស់គ្រូបង្រៀន(Kopkowski,2008)។ អ្នកស្រាវជ្រាវ បានធ្វើការស្រាវជ្រាវក្នុងតំបន់សាហារ៉ា នៃប្រទេសអាហ្វ្រិចបានរកឃើញថា គ្រូបង្រៀននៅតំបន់នោះភាគច្រើនពុំមានការពេញចិត្តចំពោះមុខរបរអាជីពជាគ្រូបង្រៀនទេ ពីព្រោះមុខរបរនេះ ពុំទទួលបានការលើកទឹកចិត្តឱ្យបានសមរម្យ ដល់គ្រូបង្រៀនឡើយ (UNESCO,2008)។ តំបន់ជនបទភាគច្រើន ដែលគ្រូបង្រៀនគិតថាជាតំបន់ពិបាកពុំមានការទាក់ទាញ និងថែរក្សាគ្រូឱ្យនៅបង្រៀនបានយូរអង្វែង ដោយសារកម្រិតជីវភាពនៃការរស់នៅទាប និងមានការលំបាកក្នុងការអភិវឌ្ឍសមត្ថភាពខ្លួនបន្ថែម។ អ្នកស្រាវជ្រាវ Gonzalez & Brown (2008) សិក្សាទៅលើមូលហេតុដែលគ្រូបង្រៀនបោះបង់អាជីពជាគ្រូបង្រៀនបន្ទាប់ពីបង្រៀនបានមួយឆ្នាំក្នុងសហរដ្ឋអាមេរិកដោយធ្វើការសម្ភាសអតីតគ្រូបង្រៀនទាំងនោះចំនួនប្រាំបីនាក់បានរកឃើញថាពួកគាត់សម្រេចចិត្តបោះបង់ការងារនេះ ដោយសារមូលហេតុយ៉ាងធំអំពីការប្រព្រឹត្តមិនល្អ ការកើតមានអំពើពុករលួយរបស់អ្នករដ្ឋបាល សិស្ស ពុំសូវមានវិន័យល្អ និងការទទួលបានប្រាក់ខែឧបត្ថម្ភមានកម្រិតទាបពេក។ បើយោងទៅលើអ្នកស្រាវជ្រាវរបស់លោក Lowe (2006) ដែលបានសិក្សាលើវិធីទាក់ទាញ និង រក្សាគ្រូបង្រៀនដែលល្អក្នុងសាលាតូចមួយបានបញ្ជាក់ថា គ្រូជួបនឹងបញ្ហាច្រើន ជាពិសេសអំពីការរៀបចំបរិស្ថានសិក្សាឱ្យបានល្អ និងលក្ខខណ្ឌមួយចំនួនដែលមិនអាចរស់នៅបានថ្លៃថ្នូរជាគ្រូបង្រៀន។ គាត់បានរកឃើញដំណោះស្រាយមួយដ៏ល្អ សម្រាប់កង្វះខាតគ្រូបង្រៀននៅតំបន់ទាំងនោះ ដោយលើកទឹកចិត្តដល់គ្រូបង្រៀនល្អៗ ដែលចូលនិវត្តន៍ឱ្យជួយបង្រៀនសិស្ស ជាជាងការខ្វះខាតគ្រូបង្រៀន និងធ្វើឱ្យចំនួនសិស្សកើនឡើងច្រើនក្នុងថ្នាក់ នីមួយ។ ជាងនេះទៅទៀត Akyeampong & Stephens (2002) បានអះអាងថា មូលហេតុដែលគ្រូបង្រៀនមិនចង់ទៅបម្រើការនៅសាលាក្នុងតំបន់ ពីព្រោះនៅតំបន់ទាំងនោះ គ្រូបង្រៀនប្រឈមមុខខ្លាំង

នឹងប្រាក់ខែទាប និងរបៀបរស់នៅពិបាកជាងនៅតំបន់ទីក្រុង។ ផ្សេងពីនេះទៀត តំបន់ជនបទប្រឈមខ្លាំងនឹងបញ្ហាសុខភាពដូចជាសម្បូរជំងឺឆ្លង និងកង្វះខាតមណ្ឌលសុខភាព។ លោក Collins (1999) បញ្ជាក់ថា ភាពមិនចង់ទៅធ្វើការនៅតំបន់ជនបទនេះហើយ ដែលជាបញ្ហាកង្វះខាតគ្រូនៅតំបន់ទាំងនោះ និងជាហេតុនាំឱ្យគ្រូបង្រៀនមួយចំនួនបង្រៀនខុសមុខវិជ្ជាឯកទេសរបស់ខ្លួន ពិសេសមុខវិជ្ជាវិទ្យាសាស្ត្រ។ ដូច្នេះ បញ្ហាជីវភាពរស់នៅ ការលំបាកក្នុងការរស់នៅតំបន់ជនបទនាំឱ្យពុំមានគ្រូបង្រៀនគ្រប់គ្រាន់ក្នុងការបង្រៀនសិស្ស និងជ្រើសរើសគ្រូបង្រៀនខុសឯកទេសមកបង្រៀន ដែលជាហេតុនាំឱ្យប៉ះពាល់ដល់គុណភាពអប់រំ។ លោក Ingersoll & Smith (2003) បានរកឃើញថាចំនួនគ្រូបង្រៀនដ៏ច្រើនប្រហែល ៤០% នៃគ្រូបង្រៀនចេញថ្មី ឬគ្រូបង្រៀនពុំសូវមានបទពិសោធ បានលាលែងអាជីពជាគ្រូបង្រៀនរបស់ខ្លួនក្នុងអំឡុងពេលប្រាំឆ្នាំដំបូង។ បញ្ហានេះ បណ្តាលមកពីការគាបសង្កត់ពីសាលារៀន ភាពមិនពេញចិត្តនឹងការងារ ការឈប់ដោយបណ្តោះអាសន្ន និងការស្វែងរកការងារដែលទទួលបានកម្រៃខ្ពស់ជាងនេះ។ Lowe (2006) បានរកឃើញថា ជុំវិញរឿងបរិស្ថានសាលារៀនមិនល្អនៅតំបន់ជនបទ ជាហេតុដែលមិនអាចស្រូបយកគ្រូថ្មីៗមកបម្រើការងារ និងមិនអាចធ្វើការទប់ស្កាត់ ឬរារាំងគ្រូមួយចំនួនឱ្យនៅបម្រើការងាររយៈពេលយូរអង្វែងបាន ហើយកត្តាសំខាន់បំផុតដែលមិនអាចហាមឃាត់ពួកគាត់ឱ្យផ្លាស់ចេញបាន គឺនៅតំបន់ជនបទ គ្រូបង្រៀនពុំមានឱកាសអភិវឌ្ឍន៍សមត្ថភាពខ្លួនបន្ថែម បើប្រៀបធៀបនឹងគ្រូបង្រៀនដែលបម្រើការងារនៅតំបន់ទីក្រុង។ Hanushek & Wobmann (2007) បានរកឃើញថាការបណ្តុះបណ្តាលគ្រូសម័យបច្ចុប្បន្ន ភាគច្រើនទទួលបានលទ្ធផលល្អ ប៉ុន្តែបញ្ហាប្រឈមដែលអាចកើតមានចំពោះគ្រូគឺការបង្រៀនរបស់ពួកគាត់មានភាពផ្ទុយទៅនឹងអ្វីដែលពួកគាត់បានធ្លាប់ទទួលការបណ្តុះបណ្តាល ទាំងផ្នែកវិធីសាស្ត្រ និងគរុកោសល្យ។

## ២.៣.២ បញ្ហាប្រឈមមួយចំនួនរបស់គ្រូនៅកម្ពុជា

### ក.បញ្ហាប្រឈមទៅលើគុណភាពគ្រូបង្រៀន

គុណភាពគ្រូបង្រៀន គឺជាបញ្ហាសំខាន់ដែលជះឥទ្ធិពលដល់គុណភាពសិក្សារបស់សិស្ស។ ធនាគារពិភពលោកបានគូសបញ្ជាក់ថា គ្រូបង្រៀនគឺមានសារៈសំខាន់ក្នុងការកំណត់គុណភាពរបស់សាលា

ហើយក៏ជាសមាសភាពសំខាន់ក្នុងការពង្រឹកការអប់រំនៅកម្ពុជាផងដែរ (WB,2014)។ យោងតាមផែនការ យុទ្ធសាស្ត្រវិស័យអប់រំ២០១៤-២០១៨ បានលើកឡើងនូវបញ្ហាប្រឈមកន្លងមកធំៗចំនួនពីរ ដែលទាក់ ទងនឹងគុណភាពគ្រូបង្រៀនៈ (ទី១) គឺប្រព័ន្ធអប់រំសព្វថ្ងៃមិនទាន់បានផ្តល់ការបង្រៀន និងរៀនប្រកបដោយគុណភាពនិងផ្សារភ្ជាប់ខ្លឹមសារទៅនឹងការរស់នៅរបស់កុមារនិងយុវជនពេញលេញទេ (ទី២) ការ ផ្គត់ផ្គង់ និងការពង្រាយគ្រូដែលមានគុណភាពទៅមូលដ្ឋានដែលមានតម្រូវការ មិនទាន់ឆ្លើយតបនឹងកង្វះ ខាតជាក់ស្តែង (MoEYS,2014a)។ របាយការណ៍សង្ខេបរបស់ក្រសួងអប់រំ យុវជន និងកីឡា បានរក ឃើញថា នៅតំបន់ជនបទ និងតំបន់ខ្ពង់រាបក្នុងប្រទេសកម្ពុជា កំពុងប្រឈមមុខនឹងកង្វះខាតគ្រូបង្រៀន និងបណ្ណាល័យ។ ទន្ទឹមនឹងការបង្រៀនរបស់គ្រូ ពិសេសចំនួនម៉ោងបង្រៀនមិនបានដល់និយាមកំណត់របស់ក្រសួងដែលមានចំនួនពី៨០០ទៅ១០០០ម៉ោងក្នុងមួយឆ្នាំ(MoEYS,2014b)។ ដូច្នេះ កត្តាគ្រូបង្រៀនគឺសំខាន់បំផុតពិសេសក្នុងតំបន់ដែលខ្វះខាតគ្រូបង្រៀន ហើយបញ្ហានេះបង្ហាញឱ្យឃើញថា គ្រូ បង្រៀនពុំទាន់អនុវត្តតាមការណែនាំរបស់ក្រសួងនូវភារកិច្ច និងតួនាទីរបស់ខ្លួននៅឡើយ ដែលទាមទារឱ្យគ្រូបង្រៀនមានគុណភាពសម្រាប់ការបង្រៀន និងរៀន។

**ខ.បញ្ហាប្រឈមអំពីគុណភាពសិស្សប្រឡងចូលធ្វើគ្រូបង្រៀន**

បញ្ហាប្រឈម គឺទាក់ទងនឹងចំណេះដឹងមូលដ្ឋានរបស់គ្រូបង្រៀនទាប នាំឱ្យគ្រូបង្រៀនភាគច្រើនពិបាកក្នុងការអនុវត្តស្តង់ដាវិជ្ជាជីវៈ។ ទិន្នន័យរបស់ធនាគារពិភពលោកបានបង្ហាញថា ចំណេះដឹងមូលដ្ឋានរបស់គ្រូបឋមសិក្សាមានកម្រិតទាប ប្រហែល៧៥ភាគរយនៃគ្រូទាំងអស់ បានរៀនចប់ត្រឹមកម្រិតអនុវិទ្យាល័យ និងប្រហែលតែ២៥ភាគរយទទួលបានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ គ្រូបង្រៀនអនុវិទ្យាល័យ ប្រហែល៧៥ភាគរយ មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងមានតែ១៨ភាគរយប៉ុណ្ណោះ ដែលបានបន្តទៅមហាវិទ្យាល័យ ហើយភាគច្រើនជាគ្រូបង្រៀនវ័យក្មេង (WB,2008)។

ជាងនេះទៅទៀត WB (2008) បានកត់សម្គាល់ឃើញថា គ្រូបឋមសិក្សា និងគ្រូអនុវិទ្យាល័យប្រមាណ ២០ភាគរយពុំទាន់មានសញ្ញាបត្របណ្តុះបណ្តាលគ្រូ។ ការអភិវឌ្ឍសមត្ថភាពបន្ថែមគឺពឹងផ្អែកទាំងស្រុងលើការបណ្តុះបណ្តាលបន្ត ខណៈពេលដែលការបណ្តុះបណ្តាលបន្តទាំងនោះអាចបានដល់គ្រូ

បង្រៀនប្រហែលតែ១៥ភាគរយប៉ុណ្ណោះក្នុងឆ្នាំសិក្សា២០០៥-២០០៦។ នេះមានន័យថា ការបណ្ដុះបណ្ដាលបន្ត គឺពុំគ្រប់គ្រាន់សម្រាប់ពួកគាត់ឡើយ (WB,2008)។ បញ្ហាគ្រូបង្រៀនដែលពុំទាន់មានសញ្ញាបត្រគរុកោសល្យគឺបណ្ដាលមកពីក្រោយរបបប្រល័យពូជសាសន៍ពុំមានគ្រូបង្រៀនគ្រប់គ្រាន់ដើម្បីបំពេញឱ្យតម្រូវការបង្រៀនសិស្ស ទើបរាជរដ្ឋាភិបាលបានជ្រើសរើសអ្នកចេះមកបំប៉នរយៈពេលខ្លី ឱ្យក្លាយជាគ្រូបង្រៀន និងក្រោយមកមានការបញ្ចូលគ្រូបង្រៀនជាប់កិច្ចសន្យាជាគ្រូក្របខ័ណ្ឌ ក្នុងតំបន់សមាហរណកម្មមួយចំនួន ដែលពួកគាត់សព្វថ្ងៃសុទ្ធតែជាគ្រូចាស់ៗ និងកំពុងចូលនិវត្តន៍ជាបន្តបន្ទាប់។

ការស្រូបយកសិស្សពូកែឱ្យចូលទទួលការបណ្ដុះបណ្ដាលជាគ្រូបង្រៀនត្រូវបរាជ័យ ព្រោះសិស្សភាគច្រើនគិតថា អាជីពជាគ្រូបង្រៀនជាជម្រើសសម្រាប់សិស្សពុំមាននិទ្ទេសល្អ និងពុំមានលទ្ធភាពបន្តការសិក្សានៅមហាវិទ្យាល័យ។ ធនាគារពិភពលោក (2014) បានរកឃើញថា កម្ពុជាមានការលំបាកក្នុងការជ្រើសរើសសិស្សដែលមានគុណភាពចូលរួមប្រឡង ដើម្បីក្លាយជាគ្រូបង្រៀន ទោះបីជាការដាក់ពាក្យចូលរួមប្រឡងមានចំនួនច្រើនក៏ដោយ។ ក្នុងការប្រឡងចូលគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន សម្រាប់និទ្ទេស A ដល់ F ដែល A តំណាងនិទ្ទេសទទួលបានពិន្ទុខ្ពស់បំផុត និង F ជានិទ្ទេសធ្លាក់ឃើញថា សិស្សដែលចូលរួមការប្រឡង មានតែនិទ្ទេស C, D, និងE ប៉ុណ្ណោះ ដាក់ពាក្យចូលរួមប្រឡងគ្រូបង្រៀនកម្រិតមូលដ្ឋាននៅឆ្នាំ២០១៤។ បញ្ហាប្រឈមនេះ បណ្ដាលមកពីពួកគេយល់ឃើញថា គ្រូបង្រៀនជាមុខរបរមួយដែលទទួលបានប្រាក់កម្រៃទាប និងសង្គមមិនសូវឱ្យតម្លៃ។ ដូច្នេះនៅពេលគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូទទួលបានសិស្សដែលមាននិទ្ទេសពុំសូវល្អ នាំឱ្យមានការលំបាកក្នុងការបណ្ដុះបណ្ដាល ព្រោះថា គ្រឹះស្ថានបណ្ដុះបណ្ដាលមានតួនាទីបំប៉នតែលើវិធីសាស្ត្របង្រៀន និងចិត្តគរុកោសល្យប៉ុណ្ណោះ។ ផ្ទុយទៅវិញដោយសារតែគរុសិស្សមានចំណេះដឹងទាប ទើបបច្ចុប្បន្ននេះ គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ ចាំបាច់ត្រូវបំប៉នឡើងវិញនូវខ្លឹមសារចំណេះដឹងទូទៅដែលធ្វើឱ្យការបណ្ដុះបណ្ដាលមានការខាតបង់ពេលវេលានិងមិនបានគ្រប់ជ្រុងជ្រោយ ហើយជាលទ្ធផល ផលិតបាននូវគ្រូបង្រៀនពុំទាន់ឆ្លើយតបនឹងស្តង់ដា នៅពេលពួកគាត់ចេញបង្រៀនថ្មីៗ។

ដោយសារសិស្សដែលមានសមត្ថភាពភាគច្រើន ពុំចូលរួមប្រឡង នាំឱ្យក្រសួងអប់រំ យុវជន និង

កីឡាសម្រេចទម្លាក់នូវលក្ខខណ្ឌនៃការជ្រើសរើសឱ្យទាបសម្រាប់បេក្ខជនចូលរួមប្រឡងធ្វើជាគ្រូបង្រៀន។ ការចូលរួមប្រឡងមានលក្ខខណ្ឌជ្រើសរើសសិស្សដែលមានអាយុចាប់ពី១៦ឆ្នាំ ដល់២៥ឆ្នាំ ដោយគិតត្រឹមថ្ងៃប្រឡង ហើយបេក្ខជនដែលដាក់ពាក្យមានកម្រិតវប្បធម៌ចាប់ពីធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណេះទូទៅ ឬមានសញ្ញាបត្រដែលមានតម្លៃសមមូលឡើងទៅ។ ដោយឡែក សម្រាប់ខេត្តខ្ពង់រាបមួយចំនួន ដូចជាខេត្តរតនគិរីនិងមណ្ឌលគិរី បេក្ខជនទាំងពីរភេទត្រូវមានកម្រិតវប្បធម៌ចាប់ពីសញ្ញាបត្រមធ្យមសិក្សាបឋមភូមិចំណេះទូទៅ ឬសញ្ញាបត្រដែលមានតម្លៃសមមូលឡើងទៅ។ ជាងនេះទៅទៀត ក្រសួងអប់រំ យុវជន និងកីឡាមានការបើកទូលាយ និងលើកទឹកចិត្តសម្រាប់គ្រូជាប់កិច្ចសន្យា និងសិស្សមកពីតំបន់ជួបការលំបាក ឱ្យចូលប្រឡងក្របខណ្ឌរដ្ឋបាន ដោយដាក់ពាក្យប្រឡងនៅតាមរាជធានីខេត្តធ្វើជាគ្រូបង្រៀន និងធ្វើចំណាត់ថ្នាក់ដោយឡែក (MoEYS,2014c)។

### គ.បញ្ហាប្រឈមនៃប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជា

ការបំផ្លិចបំផ្លាញនូវហេដ្ឋារចនាសម្ព័ន្ធ ក្នុងរបបប្រល័យពូជសាសន៍ បានធ្វើឱ្យកម្ពុជាមានការលំបាកក្នុងការស្តារ និងពង្រឹងគុណភាពអប់រំ។ របបប្រល័យពូជសាសន៍បានកែប្រែមជ្ឈមណ្ឌលសិក្សា និងបានបណ្តេញប្រជាពលរដ្ឋចេញពីទីក្រុង ដើម្បីទៅធ្វើស្រែចម្ការក្នុងគោលបំណងបង្កើននូវផលិតផលកសិកម្ម ហើយសាលារៀនត្រូវបានកែប្រែធ្វើជាគុកនិងកសិដ្ឋានចិញ្ចឹមសត្វ(Kiemnan,1985)។ បន្ទាប់ពីការដួលរលំនូវរបបប្រល័យពូជសាសន៍ ប៉ុល ពត ឆ្នាំ១៩៧៩ រដ្ឋាភិបាលថ្មីបានចាប់ផ្តើមរៀបចំប្រព័ន្ធអប់រំ និងបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនឡើងវិញ។ នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៩ សាលាគរុកោសល្យ និងវិក្រឹតការត្រូវបានដំណើរការ ហើយបន្ទាប់មកមានការបណ្តុះបណ្តាលដំបូង (Pre-Service) ដល់គ្រូរយៈពេលខ្លី និងវែង។ ដោយសារពុំមានធនធានមនុស្សគ្រប់គ្រាន់ ការបណ្តុះបណ្តាលដំបូងមានច្រើនទម្រង់ដូចជា ៧+១/៣+១, ៧+១/៤+១, ៨+១/៥+៣, ១១+២/៧+១, ១២+២/៩+២ (MoEYS,2013b) និងរហូតដល់បច្ចុប្បន្ននេះគឺ១២+២សម្រាប់គ្រូបង្រៀននៅបឋមសិក្សា។ មានន័យថា ឧទាហរណ៍៧+១ គឺជាលក្ខខណ្ឌជ្រើសរើសសិស្សបានរៀនចប់ថ្នាក់ទី៧ មកបណ្តុះបណ្តាលរយៈពេលមួយឆ្នាំ សម្រាប់តំបន់វាលរាប ឬទីប្រជុំជន និងរូបមន្ត ៣+១ គឺជ្រើសរើសសិស្សដែលបានរៀនចប់ថ្នាក់ទី៣ មកបណ្តុះបណ្តាលរយៈ

ពេលមួយឆ្នាំសម្រាប់តំបន់ខ្ពង់រាប ឬតំបន់ដាច់ស្រយាលឱ្យក្លាយជាគ្រូបង្រៀននៅបឋមសិក្សា។ ដូច្នេះ កម្រិតចំណេះដឹងជាមូលដ្ឋានរបស់គ្រូបង្រៀនតាមតំបន់នីមួយៗនិងការបណ្តុះបណ្តាលគឺពុំទាន់ធានាបាននូវគ្រូបង្រៀនដែលមានគុណភាព ឬមានស្តង់ដានៅឡើយ។

ដើម្បីលើកកម្ពស់សមត្ថភាពគ្រូបង្រៀន ក្រសួងអប់រំ យុវជន និងកីឡាបានបណ្តុះបណ្តាលដំបូង និងបណ្តុះបណ្តាលបន្តដល់គ្រូបង្រៀនថែមទៀត ពិសេសគ្រូបង្រៀនដែលមានមូលដ្ឋានចំណេះដឹងទាប។ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការបណ្តុះបណ្តាលបន្តដល់ពួកគាត់ក្នុងគោលបំណងបំប៉នសមត្ថភាពគ្រូបន្ថែមគឺចាប់ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៨៨ គឺបណ្តុះបណ្តាលរយៈពេលខ្លីដល់គ្រូបឋមសិក្សាបានចំនួន២២៩៧៦រូប និងពីឆ្នាំ១៩៨២ ដល់ឆ្នាំ ២០១២ ក្រសួងអប់រំ យុវជន និងកីឡា បានបណ្តុះបណ្តាលគ្រូបឋមរយៈពេលវែង បានចំនួន ៥៦៩៥៩ រូប (MoEYS,2013b)។ លើសពីនេះទៅទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការគ្រូបង្រៀនក្នុងតំបន់ដែលខ្វះខាតគ្រូបង្រៀន ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការបណ្តុះបណ្តាលគ្រូកិច្ចសន្យាចំនួន៨០២រូប ក្នុងនោះមានអ្នកគ្រូចំនួន២៤០រូប ក្នុងតំបន់សមាហរណកម្មឱ្យក្លាយជាគ្រូបង្រៀនកម្រិតបឋមបញ្ចូលក្នុងក្របខណ្ឌរដ្ឋក្នុងឆ្នាំសិក្សា២០០៧-២០០៩ ក្នុងរយៈពេលខ្លីត្រឹមតែមួយខែកន្លះប៉ុណ្ណោះ (MoEYS,2013b)។

ទោះជាយ៉ាងណាក៏ដោយ គ្រូបង្រៀនមួយចំនួនពុំទទួលបានការបណ្តុះបណ្តាលពេញលេញទេ ហើយពួកគាត់ពឹងផ្អែកលើការបំប៉នសមត្ថភាពពីថ្នាក់ក្រសួងនិងថ្នាក់ខេត្ត។ គ្រូចាស់ៗមួយចំនួនដែលពុំធ្លាប់ទទួលបានការបណ្តុះបណ្តាលដំបូង ក៏នៅតែបម្រើការងាររហូតដល់សព្វថ្ងៃនេះ ហើយការបណ្តុះបណ្តាលបន្តដល់ពួកគាត់ក៏មិនបានគ្រប់គ្នាដែរ។ ការសិក្សាពីប្រវត្តិនៃការអប់រំគ្រូនៅកម្ពុជា Phin (2014) បានធ្វើសំណួរស្ទង់មតិបុគ្គលិកអប់រំ ហើយបានរកឃើញថា ក្រោយឆ្នាំ១៩៧៩ ដើម្បីបំពេញតម្រូវការនៃការខ្វះខាតគ្រូបង្រៀន អ្នកដែលពុំមានចំណេះដឹងជ្រៅជ្រះ និងពលរដ្ឋដែលចេះដឹងតិចតួច ត្រូវបានជ្រើសរើសឱ្យធ្វើជាគ្រូបង្រៀន ហើយបច្ចុប្បន្នពួកគាត់មួយចំនួននៅបន្តការងារដល់បច្ចុប្បន្ន ខណៈពេលដែលការបំប៉នបន្តដល់ពួកគាត់ពុំបានឆ្លើយតបនឹងតម្រូវការជាក់ស្តែង។

ដូច្នេះ ប្រព័ន្ធបណ្តុះបណ្តាលគ្រូនៅមានកម្រិតទាប និងធនធានមនុស្សដែលចូលរួមក្នុងការបណ្តុះបណ្តាលក៏ពុំទាន់ជ្រើសរើសបាននូវអ្នកដែលមានកម្រិតសញ្ញាបត្រខ្ពស់ៗ និងមានចំណេះដឹងសមស្របជាអ្នកអប់រំបន្តដល់កុមារ ដើម្បីក្លាយជាធនធានមនុស្សដែរ ព្រោះថា "គ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់គឺជាកត្តាគន្លឹះ ក្នុងការជួយសិស្សឱ្យសម្រេចបានលទ្ធផលល្អប្រសើរក្នុងការសិក្សា" (MoEYS,2015,p.3)។ កត្តាសំខាន់ដែលនាំឱ្យមានការប្រេះឆាក្នុងប្រព័ន្ធអប់រំកម្ពុជាគឺពាក់ព័ន្ធនឹងកត្តាជំរុញនៃការអប់រំ និងសេដ្ឋកិច្ចសង្គម(UNESCO,2011)។ បញ្ហានេះ បានធ្វើឱ្យប្រទេសកម្ពុជាខកខាននូវការសន្យារបស់ខ្លួនក្នុងការកែប្រែសង្គមជាសង្គមសម័យទំនើប និងផ្តល់គ្រូបង្រៀនដែលមានគុណភាពឱ្យទៅដល់តំបន់ជួបការលំបាក និងតំបន់ដែលមានបញ្ហាប្រឈម ដែលធ្វើឱ្យគ្រូបង្រៀនបាត់បង់នូវចំណង់ចំណូលចិត្តនៃអាជីពរបស់ខ្លួន និងការមិនចាប់អារម្មណ៍លើការសិក្សារបស់សិស្ស (UNESCO,2011)។

## ២.៤ មូលហេតុដែលនាំឱ្យមានស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

### ២.៤.១ ការបង្កើតស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសមួយចំនួន

ក្នុងប្រទេស Queensland ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន គឺជាភស្តុតាងសម្រាប់បញ្ជាក់ពីការសិក្សាយកអាជីពជាគ្រូបង្រៀនក្នុងអំឡុងពេលបញ្ចប់ការបណ្តុះបណ្តាល។ មានន័យថាស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន គឺជាកញ្ចប់សមាសភាគមួយដែលគ្រូត្រូវសម្រេចឱ្យបាន មុនពួកគេបញ្ចប់ការសិក្សានៅគ្រឹះស្ថានបណ្តុះបណ្តាល ហើយសេចក្តីណែនាំក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននេះ មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងជាឯកសារសំខាន់សម្រាប់ធ្វើការវាយតម្លៃគុណភាពគ្រូបង្រៀនពេលបញ្ចប់ការបណ្តុះបណ្តាលដំបូង (Queensland College of Teacher,2009)។

សម្រាប់ប្រទេស Maryland ការបង្កើតឱ្យមានស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន គឺក្នុងគោលបំណងផ្តល់ការណែនាំ និងជួយជំរុញការខិតខំប្រឹងប្រែងរបស់គ្រូ ឱ្យអភិវឌ្ឍសមត្ថភាពអាជីពទាំងអស់គ្នា (Mayland State Department of Education,2015)។ ស្តង់ដានេះ ផលិតឡើង ដើម្បីអំពាវនាវដល់អ្នកពាក់ព័ន្ធនឹងការអប់រំទាំងអស់ ធ្វើការរួមគ្នា ដើម្បីធានាបាននូវការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ ឱ្យទទួលបានគុណ

ភាពខ្ពស់ និងធានាថា គ្រូបង្រៀនទាំងអស់អាចអនុវត្តស្តង់ដានេះប្រកបដោយភាពជោគជ័យ។ ស្តង់ដានេះត្រូវបានទទួលស្គាល់ថា ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនជាត្រីវិស័យសម្រាប់សកម្មភាពរៀន និងបង្រៀនឱ្យបានទូលំទូលាយ (Maryland State Department of Education,2015)។

ស្តង់ដាគ្រូបង្រៀនរបស់ប្រទេសអង់គ្លេស ត្រូវបានកែលម្អជាថ្មី និងត្រូវបានដាក់ឱ្យប្រើប្រាស់ចាប់ពីខែកញ្ញា ឆ្នាំ២០១២។ ស្តង់ដានេះកំណត់នូវការរំពឹងទុកជាអប្បរមានៃការអនុវត្តរបស់គ្រូបង្រៀន និងគ្រូឧទ្ទេស ដែលគិតថាជាចំណុចដែលគ្រូបង្រៀនត្រូវចាត់ទុកថាមានចំណេះដឹងខ្ពង់ខ្ពស់ប្រកបដោយគុណភាព (Department for Education of UK,2011)។ ការរៀបចំស្តង់ដានេះ គឺដើម្បីកំណត់នូវកម្រិតសមត្ថភាពមូលដ្ឋាន ដែលគ្រូបង្រៀនត្រូវប្រតិបត្តិ ដោយគិតថាស្តង់ដានេះជាចំណុចគុណភាពរបស់គ្រូបង្រៀន។ ម្យ៉ាងទៀតស្តង់ដានេះ ក៏សម្រាប់គ្រូបង្រៀនធ្វើការវាយតម្លៃពីការអនុវត្តរបស់ខ្លួន ដើម្បីបង្កើននូវកម្រិតនៃការអនុវត្ត ព្រោះថាស្តង់ដានេះបានកំណត់នូវចំណុចជាក់លាក់មួយចំនួន ដែលរំពឹងថាគ្រូបង្រៀនអាចពង្រីកចំណេះដឹង ជំនាញ និងយល់នូវការបង្ហាញ ដើម្បីឈានទៅអនុវត្តបាននូវស្តង់ដា (Department for Education of UK,2011)។

លើសពីនេះទៀត ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសអង់គ្លេសថ្មីនេះ ប្រើសម្រាប់ជំនួសឱ្យស្តង់ដាចាស់ស្តីអំពីភាពខ្ពង់ខ្ពស់នៃគុណភាពគ្រូបង្រៀន (qualified teacher status) និងស្តង់ដាស្នូលនៃវិជ្ជាជីវៈគ្រូបង្រៀន(The Core Professional Standards) ដែលបោះពុម្ពដោយអតីតភ្នាក់ងារអភិវឌ្ឍន៍ និងបណ្តុះបណ្តាលសម្រាប់សាលារៀន (Training and Development Agency for Schools), (Department for Education of UK,2011)។ នៅក្នុងសេចក្តីផ្តើមនៃស្តង់ដានោះ ក៏បានពន្យល់ណែនាំគ្រូបង្រៀនផងដែរ គឺគ្រូត្រូវបង្កើតការអប់រំដល់ក្មេងៗដែលនេះជាចំណុចត្រូវយកចិត្តទុកដាក់មុនគេបំផុត។ គ្រូបង្រៀនត្រូវបង្រៀនដោយភាពស្មោះត្រង់ ជាមួយភាពម្ចាស់ការ។ ដូច្នេះ គ្រូបង្រៀនត្រូវមានចំណេះដឹងឯកទេសរបស់ខ្លួន បង្កើនចំណេះដឹង និងជំនាញរបស់ខ្លួនឱ្យទាន់សម័យកាល និងមានការគិតគូពីខ្លួនឯងឱ្យបានល្អិតល្អន់ ស្វែងរកទំនាក់ទំនងអាជីពរបស់ខ្លួនក្នុងភាពជាវិជ្ជមាន និងធ្វើការជាមួយឪពុកម្តាយសិស្ស

ដើម្បីឱ្យពួកគាត់មានការចាប់អារម្មណ៍កាន់តែខ្លាំងចំពោះកូនៗរបស់គាត់( Department for Education of UK,2011,p.10 )

ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមានគោលបំណងជួយគ្រូបង្រៀនឱ្យដល់កម្រិតមួយ ដែលប្រទេសនីមួយៗគិតថាជាចំណុចល្អប្រកបដោយគុណភាព។ ប៉ុន្តែប្រទេសមួយចំនួនប្រើស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននេះ សម្រាប់វាស់សមត្ថភាពគរុសិស្សកំពុងសិក្សាមុនពេលបញ្ចប់នៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនដំបូង និងប្រទេសខ្លះប្រើស្តង់ដាគ្រូបង្រៀននេះ ជាត្រីវិស័យជួយដល់គ្រូបង្រៀនកំពុងបង្រៀនឱ្យអនុវត្តតាម ដើម្បីធានានូវប្រសិទ្ធភាពនៃការបង្រៀន និងរៀន។

## ២.៤ ការកកើតស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជា

ក្រសួងបានខិតខំផ្តួចផ្តើមគំនិតកសាងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននេះឡើង សម្រាប់ជាត្រីវិស័យចង្អុលប្រាប់អ្នកទាំងអស់ក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ក៏ដូចជាវគ្គវិក្រឹតការនានា ដើម្បីធ្វើឱ្យបច្ចុប្បន្នភាពនៃសមត្ថភាពរបស់គ្រូបង្រៀន សមស្របតាមយុគសម័យបច្ចេកវិទ្យាព័ត៌មាន និងសង្គមដោយផ្អែកលើពុទ្ធិ។ ស្តង់ដានេះនឹងជួយជំរុញឱ្យការអភិវឌ្ឍជួរគ្រូបង្រៀន ដើម្បីធានានូវគុណភាពពិសេសជួយគ្រូបង្រៀនឱ្យមានលទ្ធភាព និងសមត្ថភាពពេញលេញក្នុងការបង្រៀន និងរៀន ( MoEYS, 2011, p.11 )។ ទោះបីជាការអប់រំនៅកម្ពុជាមានការប្រែប្រួលប្រសើរឡើងច្រើនពិតមែនក្តី របាយគ្រូបង្រៀន និងកម្រិតសមត្ថភាពរបស់ពួកគាត់នៅមានភាពមិនស្មើគ្នាទេ ដោយសារប្រទេសកម្ពុជាធ្លាប់ទទួលរងនូវសង្គ្រាមជាច្រើន ហើយរូបមន្តនៃការបណ្តុះបណ្តាលគ្រូបង្រៀនក៏មានភាពផ្សេងគ្នាដែរ។ ដោយឃើញ ស្ថានភាពដូច្នេះ ទើបក្រសួងអប់រំ យុវជន និងកីឡាចាប់ផ្តើមកសាងឯកសារស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននេះឡើង ក្នុងគោលបំណងចង់បាននូវកម្រិតគុណភាពគ្រូបង្រៀនសមស្រប សំដៅកំណត់នូវស្តង់ដាមួយដែល មានលក្ខណៈឯកភាពគ្នាទូទាំងប្រទេស និងប្រហាក់ប្រហែលគ្រូបង្រៀននៅក្នុងតំបន់ ហើយសង្ឃឹមថាគ្រូ បង្រៀននឹងអនុវត្តបាននូវស្តង់ដានេះ។ ចំពោះគ្រូបង្រៀនដែលមិនទាន់អនុវត្តបានសម្រេចនឹងព្យាយាម ខិតខំបន្ថែមទៀត ដោយប្រើប្រាស់ស្តង់ដាវិជ្ជាជីវៈនេះធ្វើជាមូលដ្ឋាន ( MoEYS,2011 )។

លក្ខណៈពិសេសនៃស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន គឺមានគោលបំណងជំរុញនូវការអនុវត្តរបស់គ្រូឱ្យដល់កម្រិតមួយដែលក្រសួងអាចទទួលយកបានដោយគិតថាស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនមានផលប្រយោជន៍សម្រាប់គ្រូបង្រៀនក្នុងការ (១) កែលម្អការបង្រៀននិងរៀន (២) ផ្តល់ចក្ខុវិស័យសម្រាប់បណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន (៣) កែលម្អកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន (៤) រៀបចំផែនការអភិវឌ្ឍន៍សាលារៀន (៥) ធ្វើឱ្យគ្រូបង្រៀនមានលទ្ធភាព និងមានឱកាសជាច្រើនក្នុង ការស្វែងរកសេវាការងារធ្វើទាំងក្នុងស្ថាប័នរដ្ឋ និងស្ថាប័នឯកជន (៦) បង្កើនសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនឱ្យប្រហាក់ប្រហែលនឹងប្រទេសក្នុងតំបន់ (៧) ផ្តល់ជាមូលដ្ឋានគ្រឹះដើម្បីដំឡើងឋានន្តរសក្តិ (MoEYS, 2011, p.7)។

ការកសាងស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន គឺមិនមែនមានបំណងវាយតម្លៃសមត្ថភាពគ្រូបង្រៀន ដើម្បីដាក់ទណ្ឌកម្ម ចាត់ជាប្រភេទគ្រូល្អ ឬគ្រូខ្សោយនោះទេ ពោលគឺក្រសួងអប់រំ យុវជន និងកីឡាមានបំណងលើកស្ទួយការបង្រៀន និងរៀនរបស់គ្រូបង្រៀនទាំងអស់ ពិសេសធ្វើឱ្យមានការឯកភាពគ្នាទូទាំងប្រទេស និងសម្រាប់ជួយសម្រួលការសិក្សារបស់សិស្សឱ្យទទួលបានលទ្ធផលសិក្សាដែលមានកម្រិតសមស្របអាចទទួលយកបាន។ ម្យ៉ាងទៀត បើប្រៀបធៀបទៅនឹងស្តង់ដាកម្មវិធីសិក្សាចំណោះទូទៅ ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ជាឧបករណ៍ដ៏សំខាន់បំផុត និងជាខ្នាតគម្រូ សម្រាប់អ្នកអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនធ្វើផែនការកសាងសមត្ថភាពគ្រូបង្រៀន (MoEYS,2011)។

## ២.៤.៣ ការប្រៀបធៀបស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន

ដោយសារទម្រង់នៃស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន មានលក្ខណៈខុសៗគ្នា ពីប្រទេសមួយទៅប្រទេសមួយ ដូច្នេះការប្រៀបធៀបនេះ ផ្តោតតែទៅលើស្តង់ដាគោល និងការពណ៌នាស្តង់ដាគោលតែប៉ុណ្ណោះ ពោលគឺមិនរៀបរាប់លម្អិតដល់ចំណុចសូចនាករនីមួយៗនោះទេ។

| ស្តង់ដាគោល | ការពណ៌នាស្តង់ដាគោល | កម្ពុជា | ឡាវ | ម៉ាឡេស៊ី | អង់គ្លេស | អូស្ត្រាលី |
|---|---|---|---|---|---|---|
| ចំណេះដឹងវិជ្ជាជីវៈ | • ស្គាល់សិស្ស(តម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា និងឥរិយាបថសិក្សារបស់សិស្ស) | ✓ | ✓ | ✓ | ✓ | ✓ |
| | • ដឹងច្បាស់ពីប្រភេទគ្រួសារ និងកត្តាផ្សេងៗដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្សនិងដឹងពីរបៀបដោះស្រាយបញ្ហាទាំងនោះ | ✓ | ✓ | ✓ | ✓ | ✓ |
| | • យល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និង គោលបំណងអប់រំចំណេះទូទៅ | ✓ | | | ✓ | |
| | • យល់ដឹងពីទ្រឹស្តីនៃការសរសេរកិច្ចតែងការបង្រៀន | ✓ | | | | |
| | • យល់ដឹងពីខ្លឹមសារនៃកម្មវិធីសិក្សា ហើយមានសមត្ថភាពពន្យល់និងបង្រៀនខ្លឹមសារមុខវិជ្ជាដែលមានក្នុងកម្មវិធីសិក្សាបានល្អ | ✓ | ✓ | ✓ | ✓ | ✓ |
| | • យល់ដឹងពីរបៀបបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងទៀតក្នុងន័យឱ្យសិស្សទទួលបានបំណិនជាច្រើន និងមានចិត្តកាន់តែចង់រៀន | ✓ | ✓ | ✓ | ✓ | ✓ |
| | • យល់ដឹងពីបរិស្ថានក្នុងថ្នាក់រៀន និងសហគមន៍ | ✓ | ✓ | ✓ | ✓ | ✓ |
| | • យល់ដឹងពីរបៀបរៀនរបស់សិស្ស | ✓ | ✓ | ✓ | ✓ | ✓ |
| | • យល់ដឹងពីភាពខុសគ្នានៃសម្បទា ល្បឿន និងរបៀបសិក្សារបស់សិស្ស | ✓ | ✓ | ✓ | | ✓ |

| | | | | | | |
|---|---|---|---|---|---|---|
| | • មានចំណេះដឹងផ្នែកភាសា | | ✓ | | ✓ | |
| | • មានសញ្ញាបត្របរិញ្ញា ឬសញ្ញាបត្រសមមូល ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាគ្រូបង្រៀន | | ✓ | | | |
| | • មានយុទ្ធសាស្ត្របង្រៀនសិស្សជាជនជាតិដើម និងក្រុមជនជាតិរស់នៅលើដីកោះ | | | | | ✓ |
| ការប្រតិបត្តិវិជ្ជាជីវៈ | • រៀបចំកិច្ចតែងការបង្រៀន កម្មវិធីបង្រៀន និងការវាយតម្លៃលទ្ធផលសិក្សាបានត្រឹមត្រូវ ហើយមានប្រសិទ្ធភាព | ✓ | | | ✓ | ✓ |
| | • រៀបចំសម្ភារបង្រៀននិងរៀន ដើម្បីធ្វើឱ្យការសិក្សាសម្រេចបានលទ្ធផលល្អ | ✓ | | ✓ | ✓ | ✓ |
| | • ប្រើប្រាស់វិធីសមស្របសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | ✓ | ✓ | ✓ | ✓ | ✓ |
| | • តាមដានការចូលរួម និងថែរក្សាកំណត់ត្រា នៃភាពរីកចម្រើនរបស់សិស្ស | ✓ | ✓ | ✓ | ✓ | ✓ |
| | • ផ្តល់ព័ត៌មានត្រឡប់ទៅសិស្ស មាតាបិតា ឬអាណាព្យាបាលសិស្សអំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស | ✓ | ✓ | ✓ | ✓ | ✓ |
| | • ផ្តល់បរិស្ថានសិក្សាដែលមានសុវត្ថិភាព និងធ្វើឱ្យសិស្សទាំងអស់ខិតខំរៀនសូត្រអស់ពីលទ្ធភាព | ✓ | ✓ | ✓ | ✓ | ✓ |
| | • ជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | |
|---|---|---|---|---|---|---|
| | • ចូលរួមអភិវឌ្ឍសាលារៀន ដើម្បីទ្រទ្រង់ការសិក្សានិងសុខុមាលភាពរបស់សិស្ស ព្រមទាំងសហសេវិក/មិត្តរួមអាជីព | ✓ | ✓ | ✓ | ✓ | ✓ |
| | • ប្រើវិធីបង្រៀនផ្សេងៗ ដើម្បីជួយសម្រួលដល់ការសិក្សារបស់សិស្ស និងសម្រេចឱ្យបានតាមស្តង់ដាកម្មវិធីសិក្សារបស់ក្រសួង | ✓ | ✓ | ✓ | ✓ | ✓ |
| | • ផ្តល់មធ្យោបាយឱ្យស្របទៅតាមរបៀបសិក្សា និងតម្រូវការផ្សេងៗគ្នារបស់សិស្សតាមរយៈការអនុវត្តន៍វិធីបង្រៀនសមស្រប និងសម្បូរបែប | ✓ | ✓ | ✓ | ✓ | ✓ |
| | • រៀបចំ និងផ្តល់ឱ្យសិស្សនូវឱកាសសិក្សាពីដំណោះស្រាយដើម្បីចូលរួមគិតឱ្យបានល្អិតល្អន់ និងដោយច្នៃប្រឌិត | ✓ | ✓ | ✓ | ✓ | ✓ |
| | • ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍បើមានលទ្ធភាព ដើម្បីធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព | ✓ | ✓ | ✓ | | ✓ |
| | • កំណត់នូវវត្ថុបំណងមេរៀនខ្ពស់មានភាពតឹងតែង និងប្រកួតប្រជែងចំពោះសិស្សគ្រប់ប្រភេទ | | | | ✓ | |
| | • ទទួលខុសត្រូវសម្រាប់ការចូលរួម ការរីកចម្រើន និងលទ្ធផលសិក្សារបស់សិស្ស | | | | ✓ | ✓ |
| | • ធ្វើការវាយតម្លៃជាប្រចាំ និងវាយតម្លៃបញ្ចប់ដើម្បីជានាភាពរីកចម្រើនរបស់សិស្ស | | | | ✓ | ✓ |

| | | | | | | |
|---|---|---|---|---|---|---|
| ការសិក្សាវិជ្ជាជីវៈ | • វាយតម្លៃការបង្រៀន ការអភិវឌ្ឍន៍ខ្លួន និងការប្រើប្រាស់ផែនការសម្រាប់ដឹកនាំស្វ័យសិក្សាវិជ្ជាជីវៈបានទៀងទាត់ | ✓ | ✓ | ✓ | ✓ | ✓ |
| | • អភិវឌ្ឍចំណេះដឹងបច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ និងបំណិន សម្រាប់ការអនុវត្តការបង្រៀន និងរៀន | ✓ | ✓ | ✓ | | ✓ |
| | • ធ្វើឱ្យប្រសើរឡើងនូវបំណិនទំនាក់ទំនងជាមួយសិស្ស មាតាបិតាមិត្តរួមអាជីព និងសហគមន៍ | ✓ | ✓ | ✓ | ✓ | ✓ |
| | • អានអត្ថបទវិជ្ជាជីវៈគ្រូបង្រៀននិងស្រាវជ្រាវដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យធ្វើឱ្យការបង្រៀនកាន់តែប្រសើរឡើង | ✓ | ✓ | ✓ | ✓ | |
| | • ធ្វើអន្តរកម្មជាមួយគ្រូដទៃទៀតក្នុងសកម្មភាពសិក្សាវិជ្ជាជីវៈផ្សេងៗ | ✓ | ✓ | ✓ | ✓ | |
| | • បង្ហាញពីការយកចិត្តទុកដាក់និងថែរក្សាសិស្សហើយជានិច្ចកាលធ្វើការដើម្បីប្រយោជន៍សិស្ស និងសង្គម | ✓ | ✓ | ✓ | ✓ | |
| | • អភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ដោយយកចិត្តទុកដាក់ក្នុងការដោះស្រាយវិវាទ និងការគ្រប់គ្រងវិបត្តិ | | | ✓ | | |
| | • ផែនការអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀនត្រូវបានវាយតម្លៃដោយផ្អែកលើ ទិន្នន័យនៃលទ្ធផលសិក្សារបស់សិស្ស | | | ✓ | | ✓ |
| | • គ្រូបង្រៀនត្រូវអានផ្តល់ព័ត៌មានត្រឡប់ចំពោះការស្រាវជ្រាវថ្មីៗ ដែលពាក់ព័ន្ធ និងធ្វើការស្រាវជ្រាវអំពីសម្មតិកម្មរបស់ខ្លួន | | | ✓ | | |
| | • បង្ហាញការយល់ដឹងបែបការគិត និងលើកកម្ពស់នូវតម្លៃនៃអាហារូបករណ៍ | | | | ✓ | |

| | | | | | | |
|---|---|---|---|---|---|---|
| | • បង្ហាញ និងមានផែនការនៃតម្រូវការក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀន | | | | | |
| សីលធម៌វិជ្ជាជីវៈ | • បង្ហាញពីការប្តេជ្ញាចិត្ត និងចូលរួមចំណែក ក្នុងវិជ្ជាជីវៈគ្រូបង្រៀន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ | ✓ | ✓ | ✓ | ✓ | ✓ |
| | • បង្ហាញអាកប្បកិរិយាវិជ្ជមានជាគម្រូប្រកបដោយសីលធម៌ និងមានទំនាក់ទំនងដោយសុខដុមជាមួយសិស្ស និងសហគមន៍ | ✓ | ✓ | ✓ | ✓ | ✓ |
| | • ប្រើប្រាស់ភាពយុត្តិធម៌ និងតម្លាភាព ក្នុងការប្រព្រឹត្តជាមួយសិស្ស សហសេវិក និងសមាជិកផ្សេងៗរបស់សហគមន៍ | ✓ | ✓ | ✓ | ✓ | ✓ |
| | • សម្រេចនូវក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងទទួលខុសត្រូវចំពោះភារកិច្ចរបស់ខ្លួន | | | | | ✓ |

ការរៀបចំស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន គឺសំខាន់បំផុតត្រូវបម្រើឱ្យគោលនយោបាយអប់រំ និងតម្រូវការសម្រាប់ប្រទេសនីមួយៗ។ ការរៀបចំត្រូវតែស៊ីគ្នាទៅនឹងបរិបទសង្គមដែលជាហេតុនាំឱ្យមានចំណុចមួយចំនួនក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមានចំណុចដូចគ្នាច្រើន ចំណែកឯចំណុចខុសគ្នាគឺមានតិចតួចបំផុត។ ចំណុចខ្លះប្រទេសយើងមាន និងចំណុចខ្លះទៀតប្រទេសយើងបែរជាគ្មានទៅវិញ។

យោងតាមតារាង២.១បង្ហាញឱ្យឃើញថាស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសថៃពុំបាននិយាយអំពីគ្រូបង្រៀនអាចពណ៌នាបានអំពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ និងការរៀបចំកិច្ចតែងការបង្រៀនទេ។ ផ្ទុយទៅវិញ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនប្រទេសថៃមានពណ៌នាថាគ្រូបង្រៀនត្រូវមានចំណេះដឹងផ្នែកភាសា និងមានសញ្ញាបត្រយ៉ាងទាបកម្រិតបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល ដែលការកំណត់ស្តង់ដានេះ សម្រាប់បរិបទប្រទេសកម្ពុជាយើងពុំមាននោះទេ។ សម្រាប់ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនប្រទេសម៉ាឡេស៊ីក៏ពុំបានលើកឡើងពីគោលនយោបាយអប់រំជាតិ គោល

ដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅដែលគ្រូបង្រៀនត្រូវតែសិក្សាស្វែងយល់ដែរ ប៉ុន្តែស្តង់ដានេះបានកំណត់ឱ្យគ្រូយកចិត្តទុកដាក់ក្នុងការដោះស្រាយវិវាទក្នុងសាលា យកចិត្តទុកដាក់លើការគ្រប់គ្រងវិបត្តិ ហើយគ្រូបង្រៀនត្រូវបានវាយតម្លៃលើការអភិវឌ្ឍសមត្ថភាពរបស់ខ្លួន ដោយផ្អែកលើលទ្ធផលសិក្សារបស់សិស្ស និងគ្រូបង្រៀន ហើយត្រូវផ្តល់ព័ត៌មានត្រឡប់អំពីការសិក្សាស្រាវជ្រាវថ្មីៗ ដែលពាក់ព័ន្ធនឹងសម្មតិកម្មរបស់ខ្លួន។

ចំពោះស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសអង់គ្លេស ឃើញថាមិនបានរៀបរាប់អំពីគ្រូត្រូវយល់ដឹងពីទ្រឹស្តីនៃការសរសេរកិច្ចតែងការបង្រៀន ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ការយល់ដឹងពីភាពខុសគ្នានៃសម្បទា ល្បឿន និងរបៀបសិក្សារបស់សិស្សទេ ប៉ុន្តែស្តង់ដាវិជ្ជាជីវៈនេះបានលើកឡើងពីការទទួលខុសត្រូវសម្រាប់ការចូលរួម ការរីកចម្រើន និងលទ្ធផលសិក្សារបស់សិស្ស និងធ្វើការវាយតម្លៃជាប្រចាំ (Formative Assessment) វាយតម្លៃបញ្ចប់ (Summative Assessment) ដើម្បីធានាបានភាពរីកចម្រើនរបស់សិស្ស ហើយគ្រូបង្រៀនត្រូវបង្ហាញការយល់ដឹងបែបការគិត និងលើកកម្ពស់នូវតម្លៃនៃអាហារូបករណ៍។

ចំណែកឯស្តង់ដាគ្រូបង្រៀនរបស់ប្រទេសអូស្ត្រាលី ក៏ពុំបានលើកឡើងថា គ្រូបង្រៀនត្រូវយល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ គោលបំណងអប់រំចំណេះទូទៅ ឬអានអត្ថបទវិជ្ជាជីវៈគ្រូបង្រៀន ការយល់ដឹងពីទ្រឹស្តីនៃការសរសេរកិច្ចតែងការបង្រៀន និងការធ្វើអន្តរកម្មជាមួយគ្រូដទៃទៀតក្នុងសកម្មភាពសិក្សាវិជ្ជាជីវៈផ្សេងៗទេ។ ម្យ៉ាងទៀតស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់ប្រទេសអូស្ត្រាលីបានលើកឡើងពីការទទួលខុសត្រូវសម្រាប់ការចូលរួម ការរីកចម្រើន និងលទ្ធផលសិក្សារបស់សិស្សព្រមទាំងធ្វើការវាយតម្លៃបញ្ចប់ដើម្បីធានាភាពរីកចម្រើនរបស់សិស្ស និងយុទ្ធសាស្ត្របង្រៀនសិស្សជនជាតិដើម និងក្រុមជនជាតិរស់នៅលើដីកោះ។

សរុបសេចក្តីមក ចំណុចមួយចំនួនដែលប្រទេសកម្ពុជាពុំមានលើកឡើងខាងលើ ឃើញថាជាចំណុចល្អបើប្រទេសកម្ពុជាអាចធ្វើបាន ដូចជាស្តង់ដាគ្រូបង្រៀនត្រូវកម្រិតនូវចំណេះដឹងទូទៅចាប់ពី

សញ្ញាបត្របរិញ្ញាបត្រឡើងទៅ ប៉ុន្តែសម្រាប់ចំណុចខ្លះ គឺមិនមានភាពសមស្របទេ សម្រាប់ប្រទេសកម្ពុជា។

## ២.៥ ក្របខណ្ឌទស្សនាទាន

គោលបំណងសំខាន់ក្នុងការសិក្សានេះ គឺចង់ធ្វើការវាស់វែង និងពិនិត្យតាមដានការអនុវត្តស្តង់ ដាវិជ្ជាជីវៈគ្រូបង្រៀនទៅលើគ្រូកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ ។ សារៈសំខាន់នៃការសិក្សានេះចង់កំណត់ឱ្យបាននូវការអនុវត្តជាក់ស្តែងរបស់គ្រូបង្រៀនកម្រិតមធ្យមសិក្សានិងកត្តាដែលមានឥទ្ធិពលក្នុងការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។ ការសិក្សានេះក៏ចង់រកឱ្យឃើញផងដែរ នូវចំណុចល្អ និងចំណុចខ្វះខាតដែលគិតថាជាចំណុចលំបាក ចំពោះគ្រូបង្រៀនក្នុងការសម្រេចបាននូវស្តង់ដាវិជ្ជាជីវៈ គ្រូបង្រៀន និងពីមូលហេតុដែលខកខានមិនបានបំពេញក្នុងសូចនាករនីមួយៗនៃស្តង់ដានេះ។ តាមរយៈ ការរំឭកទ្រឹស្តីខាងលើឃើញថា ដើម្បីធានាបាននូវប្រសិទ្ធភាព និងគុណភាពនៃការបង្រៀន គ្រូបង្រៀនមិន ត្រឹមតែមានចំណេះដឹង ដែលខ្លួនត្រូវបង្រៀននោះទេ គ្រូបង្រៀនត្រូវមានការប្រតិបត្តិប្រកបដោយរបៀបផ្ទេរ និងវិធីសាស្ត្រសម្បូរបែប ជាពិសេសដើម្បីទទួលបាននូវចំណេះដឹងថ្មី និងវិធីសាស្ត្របែបទំនើប គ្រូបង្រៀនត្រូវតែធ្វើការស្រាវជ្រាវបន្ថែម ។ លក្ខខណ្ឌទាំងបីនេះ ក៏នៅមិនទាន់ពេញលេញនោះដែរសំខាន់បំផុតក្នុងវិជ្ជាជិវៈជាអ្នកអប់រំ គ្រូបង្រៀនត្រូវមានសីលធម៌មួយទៀត ដើម្បីទទួលបាននូវតម្លៃ ហើយមានការគោរពស្រឡាញ់ពីសិស្ស។

យោងតាមការរំឭកទ្រឹស្តីដែលបានសិក្សាខាងលើនិងដើម្បីទទួលបាននូវប្រសិទ្ធភាព និងគុណភាពអបរំសម្រាប់បរិបទកម្ពុជា ក្របខណ្ឌទស្សនាទានសម្រាប់ការសិក្សានេះ គឺត្រូវផ្អែកលើទ្រឹស្តីក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់កម្ពុជា ដែលផ្តោតទៅលើសមាសភាគធំៗចំនួនបួនគឺ ចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ ដែលជាធាតុចូលយ៉ាងសំខាន់សម្រាប់ដំណើរការបង្រៀននិងរៀនប្រកបដោយប្រសិទ្ធភាព ( MoEYS,2011 )




**ប្រភព: MoEYS,2011: ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន**

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធាបបទស្តីពី« **ការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន នៅសាលាមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តតាកែវ** គឺប្រើប្រាស់វិធីសាស្ត្របរិមាណវិស័យ « ដើម្បីសិក្សាស្វែងយល់ ពីកម្រិតនៃការអនុវត្តស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន និងបញ្ហាប្រឈមក្នុងការអនុវត្ត របស់លោកគ្រូអ្នកគ្រូ នៅក្នុងខេត្តតាកែវ។ វិធីសាស្ត្របរិមាណវិស័យ គឺទទួលបានតម្លៃមធ្យមភាគពិន្ទុ ពីកម្រងសំណួរ។

## ៣.១. ភាគសំណាកនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវនេះ យើងបានប្រើប្រាស់វិធីសាស្ត្រជ្រើសរើសសំណាកចៃដន្យ( probability Simple random sampling) គឺជាវិធីសាស្ត្រស្រាវជ្រាវដែលធ្វើទៅតាមភាពចៃដន្យធម្មតា មកស្រាវជ្រាវបានជ្រើសរើសយកសំណាក១៥០ ដែលក្នុងនោះលោកគ្រូអ្នកគ្រូ ត្រូវបំពេញកម្រងសំណួរតែពីរផ្នែកប៉ុណ្ណោះគឺ ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន និងផ្នែកទី២ ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន។ បុគ្គលិកបង្រៀនចំនួន ១៥០នាក់ ក្នុងចំណោមបុគ្គលិកបង្រៀនសរុបចំនួន ៩៩៦នាក់នៃអនុវិទ្យាល័យទាំង ៦៦ក្នុងក្រុង/ស្រុកទាំងដប់។ ដោយសារពេលវេលាមិនគ្រប់គ្រាន់ យើងមិនអាចប្រមូលទិន្នន័យបានគ្រប់សាលាបានទេ ទើបអ្នកស្រាវជ្រាវជ្រើសរើសសាលាក្នុងតំបន់៣ ដែលតំណាងឱ្យមួយខេត្តតាកែវតែម្តង។ ហើយក្នុងតំបន់ទាំង ៣ យើងជ្រើសរើសអនុវិទ្យាល័យចំនួន ១២អនុវិទ្យាល័យ ដែលក្នុងចំណោមអនុវិទ្យាល័យចំនួនដប់ពីរនោះ មានអនុវិទ្យាល័យបួនជ្រើសចេញពីអនុវិទ្យាល័យស្ថិតនៅទីប្រជុំជន អនុវិទ្យាល័យបួនទៀតស្ថិតនៅជនបទ និងអនុវិទ្យាល័យបួន ស្ថិតនៅក្នុងតំបន់ដាច់ស្រយាល។ ភាគសំណាកដែលជាបុគ្គលិកបង្រៀនត្រូវបំពេញកម្រងសំណួរដែលមានពីរផ្នែកគឺ ផ្នែកទី១ព័ត៌មានផ្ទាល់ខ្លួន ផ្នែកទី២ចំណេះដឹងអំពីការ អនុវត្តក្រមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។ ក្នុងនោះភាគសំណាគចំនួន ៥០ត្រូវបានជ្រើសរើសចេញពីអនុវិទ្យាល័យដែលស្ថិតនៅទីប្រជុំជននៃក្រុង/ស្រុកទាំង ១០ និងភាគសំណាកចំនួន ៥០ទៀតត្រូវបានជ្រើសរើសចេញពីអនុវិទ្យាល័យដែលស្ថិតនៅតំបន់ជនបទនៃក្រុង/ស្រុកដដែល និងភាគសំណាកចំនួន ៥០ទៀតត្រូវបានជ្រើសរើស

ចេញពីអនុវិទ្យាល័យដែលស្ថិតនៅតំបន់ដាច់ស្រយាល ។ ការជ្រើសរើសភាគសំណាកតាមវិធីនេះអាចធ្វើជាតំណាងនៃក្រុង/ស្រុកនីមួយៗប្រកបដោយភាពជឿជាក់ពីព្រោះភាគសំណាកដែលជ្រើសរើសយកគឺដើម្បីតំណាងឱ្យខេត្តទាំងមូល។

តារាងចំនួនសំណាកដែលបានជ្រើសរើសនៅតាមគោលដៅ៖

| **ល.រ** | **ក្រុមគោលដៅ** | **ក្រុង/ស្រុក** | **សរុប** | |
|---|---|---|---|---|
| **ខ** | **កម្រិតអនុវិទ្យាល័យ** | | **គ្រូបង្រៀន** | **សរុប** |
| ១ | វិ.ជាស៊ីមតាកែវ | ដូនកែវ | ១៥ | ៥០ |
| ២ | វិ.ឈើទាល | | ១៣ | |
| ៣ | អនុវិ.បារាយករណ៍ | | ១១ | |
| ៤ | អនុវិ.អង្គមេត្រី | | ១១ | |
| ៥ | អនុវិ.អង្គជុំ | សំរោង | ៨ | ៥០ |
| ៦ | អនុវិ.ថ្មដា | | ១០ | |
| ៧ | វិ.ហ៊ុនសែនបាទី | បាទី | ៣២ | |
| ៨ | វិ.ហ៊ុនសែនទន្លេបាទី | បាទី | | |
| ៩ | អនុវិ.ព្រៃកផ្ទោល | អង្គរបូរី | ១០ | ៥០ |
| ១០ | អនុវិ.ហ៊ុនសែនរំលក | | ៧ | |
| ១១ | វិ.ហ.ស អង្គរបូរី | | ២១ | |
| ១២ | វិ.ហ.ស សំរោងពន្លៃ | | ១២ | |
| សរុបរួម | | | ១៥០ | ១៥០ |

## ៣.២. ឧបករណ៍ស្រាវជ្រាវ

### ៣.២.១ ការបង្កើតខ្លឹមសារ

ចំពោះឧបករណ៍ស្រាវជ្រាវវិញ អ្នកស្រាវជ្រាវបានរៀបចំបង្កើតកម្រងសំណួរ សម្រាប់ លោកគ្រូ-អ្នកគ្រូ(បុគ្គលិកបង្រៀន) ធ្វើការបំពេញដែលចំណាយពេលប្រមាណពី៤៥ ទៅ៦០នាទី។ វិធីសាស្ត្រដែលបានជ្រើសរើសនៅក្នុងការសិក្សាស្រាវជ្រាវនេះគឺជាការស្ទង់មតិ ដើម្បីសិក្សាពីស្ថានភាពនៃការប្រតិបត្តិស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននិដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន នៅកម្រិតមធ្យមសិក្សាបឋមភូមិ ។ កម្រងសំណួរប្រភេទនេះត្រូវបានរៀបចំឡើងតាម Word ។

ក្នុងការបង្កើតកម្រងសំណួរទាំងនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់ឯកសារជំនួយខ្លះៗ ហើយបានកែសម្រួលខ្លឹមសារមួយចំនួនដើម្បីឱ្យស្របទៅនឹងស្ថានភាពជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា។ ឯកសារជំនួយដែលត្រូវបានប្រើប្រាស់សម្រាប់ការបង្កើតកម្រងសំណួរនេះមានប្រភពចេញពី ឯកសារស្តង់ដាវិជ្ជាជីវៈ គ្រូបង្រៀន (២០១០)។

### ៣.២.២ ទម្រង់កម្រងសំណួរ

**ផ្នែកទី១** ព័ត៌មានផ្ទាល់ខ្លួន ក្នុងផ្នែកនេះមាន៤សំណួរ។ អ្នកស្រាវជ្រាវចង់ដឹងអំពី ទីតាំងអនុវិទ្យាល័យ តួនាទី ភេទ និងបទពិសោធន៍បំពេញការងារក្នុងវិស័យអប់រំរបស់បុគ្គលិកអប់រំ។

**ផ្នែកទី២** ចំណេះដឹងអំពីស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ។

## ៣.៣ នីតិវិធី និងដំណើរការប្រមូលទិន្នន័យ

ក្រៅពីទ្រឹស្តី និងទិន្នន័យដែលមានស្រាប់ យើងក៏បានបញ្ជូនកម្រងសំណួរតាមប្រព័ន្ធអនឡាញដើម្បីប្រមូលទិន្នន័យជាក់ស្តែងនៅតាមគោលដៅនានា ដើម្បីទទួលបានទិន្នន័យបឋមសម្រាប់យកមកវិភាគក្នុងការសិក្សាស្រាវជ្រាវនេះ។ នៅក្នុងការប្រមូលទិន្នន័យនេះដែរ គឺយើងបានប្រើប្រាស់រយៈពេល២សប្តាហ៍ ពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ ហើយយើងបានទំនាក់ទំនងជាមួយថ្នាក់ដឹកនាំមន្ទីរ ថ្នាក់ដឹកនាំការិយាល័យជុំវិញមន្ទីរ នាយកអនុវិទ្យាល័យ ដើម្បីបញ្ជូនលិខិតបទដ្ឋាននៃការចុះប្រមូលទិន្នន័យនៅតាមគោលដៅនីមួយៗ បន្ទាប់មកយើងក៏ ចែកកម្រងសំណួរដែលបានរៀបចំឡើង

ទៅកាន់អនុវិទ្យាល័យគោលដៅចំនួន១២នៅស្រុក/ក្រុងទាំង១០ ពេលគឺចុះសិក្សាស្រាវជ្រាវនៅគ្រប់ស្រុក/ក្រុងទាំងអស់នៃខេត្តតាកែវ ក្នុងនោះ ក្រុងដូនកែវមាន០២អនុវិទ្យាល័យ និង២វិទ្យាល័យ ស្រុកសំរោង មាន០២អនុវិទ្យាល័យ ស្រុកបាទីមាន០២វិទ្យាល័យ ស្រុកអង្គរបូរីមាន០២អនុវិទ្យាល័យ និង ២ វិទ្យាល័យ ។ ការជ្រើសរើសចំនួនអនុវិទ្យាល័យពីក្នុង ក្រុង ស្រុកនីមួយៗដោយកំណត់យកអនុវិទ្យាល័យមួយស្ថិតក្នុងតំបន់ទីប្រជុំជន និងអនុវិទ្យាល័យមួយទៀតស្ថិតក្នុងតំបន់ជនបទនៃក្រុង និងអនុវិទ្យាល័យស្ថិតក្នុងតំបន់ដាច់ស្រយាលពីក្រុង ស្រុកទាំងនោះដើម្បីធ្វើជាតំណាងក្រុងស្រុកទាំងអស់នោះ។

មុនពេលបញ្ជូនកម្រងសំណួរនេះដល់អ្នកចូលរួមផ្តល់ព័ត៌មាន ជាដំបូងយើងបានយកលិខិតដែលចេញដោយវិទ្យាស្ថានជាតិអប់រំ លេខ២៤០អយក.វជអ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ ដើម្បីធ្វើសំណើបន្ត ទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ ដើម្បីសុំការអនុញ្ញាតចុះប្រមូលទិន្នន័យ។ បន្ទាប់ពីបានលិខិតអនុញ្ញាតពីលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡារួចមក អ្នកស្រាវជ្រាវក៏បានយកលិខិតស្នើសុំនោះទៅប្រគល់ជូនលោក លោកស្រី ជាថ្នាក់ដឹកនាំមន្ទីរ ថ្នាក់ដឹកនាំការិយាល័យ និងនាយក នាយិកា តាមតេឡេក្រាម។ បន្ទាប់មក យើងបានជួបជាមួយនាយក នាយិកាសាលាដើម្បីជម្រាបពួកគាត់ពីគោលបំណងនៃការចុះសិក្សាស្រាវជ្រាវ ក្រមសីលធម៌នៃការស្រាវជ្រាវ និងប្រយោជន៍ដើម្បីទទួលបានការចូលរួម ព្រមទាំងសុំការអនុញ្ញាតដើម្បីឱ្យគាត់ជួយផ្តល់ព័ត៌មានអំពីលោកគ្រូ អ្នកគ្រូដែលត្រូវបំពេញកម្រងសំណួរ។ បន្ទាប់មកទៀតយើងខ្ញុំក៏បានចែកកម្រងសំណួរទៅតាមសាលាគោលដៅ និងបញ្ជូនកម្រងសំណួរដែលមាននៅក្នុងតំណតាមរយៈតេឡេក្រាមផ្ទាល់ខ្លួនរបស់នាយក នាយិកា និងគ្រុបតេឡេក្រាមរបស់សាលារៀននីមួយៗទៅដល់អ្នកចូលរួមទាំងអស់ចំនួន១៥០នាក់។ ក្នុងនោះអនុវិទ្យាល័យទីរួមខេត្តបានឆ្លើយតបមកវិញចំនួន០៩នាក់ អនុវិទ្យាល័យម្រុំខាងត្បូងបានឆ្លើយតបមកវិញចំនួន០៥នាក់ អនុវិទ្យាល័យហ៊ុនសែនសំរោងទងបានឆ្លើយតបមកវិញចំនួន០៨នាក់ អនុវិទ្យាល័យអង្គខ្មៅបានឆ្លើយតបមកវិញចំនួន១០នាក់ អនុវិទ្យាល័យមហាសាំងបានឆ្លើយតបមកវិញចំនួន១០នាក់ អនុវិទ្យាល័យព្រៃក្មេងបានឆ្លើយតបមកវិញចំនួន០៩នាក់ អនុវិទ្យាល័យសង្គមសិក្សាបានឆ្លើយតបមកវិញចំនួន០៥នាក់ អនុវិទ្យាល័យបន្ទាយខ្មែរបានឆ្លើយតបមកវិញចំនួន០៩នាក់ អនុវិទ្យាល័យស្រង់បានចំនួន០៩នាក់ អនុវិទ្យាល័យសែនទាវបាន

ចំនួន០៨នាក់ អនុវិទ្យាល័យហ៊ុនសែនបរសេដ្ឋបានចំនួន១០នាក់ អនុវិទ្យាល័យអង្គលំទងបានចំនួន១០នាក់ អនុវិទ្យាល័យវត្តតៀងបានចំនួន០៦នាក់ អនុវិទ្យាល័យអមលាំងបានចំនួន០៨នាក់ អនុវិទ្យាល័យបន្ទាយប្រណាកបាន១០នាក់ អនុវិទ្យាល័យរ៉ូតារីបាន០៦នាក់។ ក្នុងការបំពេញកម្រងសំណួរទាំងនេះ យើងខ្ញុំបានអនុញ្ញាតឱ្យពួកគាត់បំពេញកម្រងសំណួរនៅពេលណាក៏បាន អាស្រ័យលើពេលវេលានិងលទ្ធភាព(សេវាអ៊ិនធឺណិត)របស់ពួកគាត់ហើយយើងខ្ញុំបានទំនាក់ទំនងជាមួយពួកគាត់ គ្រប់ពេល តាមតេឡេក្រាមដើម្បីពន្យល់នូវចំណុចទាំងឡាយណា ដែលពួកគាត់ចង់សាកសួរព័ត៌មានបន្ថែមក្នុងករណីមានសំណួរ ឬចម្ងល់។ យើងខ្ញុំយកចិត្តទុកដាក់ក្នុងការសម្របសម្រួល និងសហការជាមួយក្រុមគោលដៅទាំងអស់ ដើម្បីទទួលបានព័ត៌មានមួយអាចជឿទុកចិត្តបានសម្រាប់យកទៅវិភាគក្នុងការសិក្សាស្រាវជ្រាវ។ សម្រាប់ចំនួន២៥នាក់ដែលបានបាត់នេះអាចបណ្តាលមកពីបញ្ហាបច្ចេកទេស គឺប្រហែលពួកគាត់ឆ្លើយរំលងសំណួរណាមួយដែលជាមូលហេតុធ្វើឱ្យបញ្ជូនកម្រងសំណួររបស់ខ្លួនត្រឡប់មកវិញ មិនបានជោគជ័យ។ ម្យ៉ាងទៀតនៅតំបន់ខ្លះមិនមានសេវាអ៊ីនធឺនែត និងមួយចំនួនទៀតមិនបានបំពេញតែម្តងអាចមកពីពួកគាត់មិនសូវយល់ពីការចូលតាមរយៈតំណ ហើយមួយចំនួនទៀតអាចគេចវេសន៍មិនចូលរួមបំពេញកម្រងសំណួរ។

## ៣.៤. ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យដែលទទួលបាន តាមរយៈការបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវប្រើប្រាស់កម្មវិធី Ms. Excel ដើម្បីរកមធ្យម គម្លាតស្តង់ដា ដូច្នេះនៅក្នុងការវិភាគចម្លើយ ចំពោះរាល់សំណួរទាំងអស់ត្រូវបានធ្វើការវិភាគ គឺវិភាគជាបណ្តុំទៅលើចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ ។ ចំពោះការវិភាគនេះអ្នកសិក្សាស្រាវជ្រាវបានវិភាគលើចំណុចសំខាន់មួយចំនួន ដូចជាៈ កម្រិតនៃការយល់ដឹងពីខ្លឹមសារ និងសកម្មភាពនៅក្នុងការបំពេញភារៈកិច្ចទៅតាមម៉ោងពេលដែលបានកំណត់ដោយច្បាប់ កម្រិតនៃការពេញចិត្តចំពោះការបំពេញភារៈកិច្ចដោយផ្អែកលើលក្ខណៈសម្បត្តិគ្រូបង្រៀនកម្ពុជា សិក្សាប្រៀបធៀបបញ្ហាប្រឈមសំខាន់ៗដែលអនុវិទ្យាល័យនៅតំបន់ប្រជុំជន និងតំបន់ជនបទនៃក្រុងស្រុកនីមួយៗជួបប្រទះ និងទស្សនៈយល់ឃើញដើម្បីបង្កើតយុទ្ធសាស្រ្តជំរុញគ្រូបង្រៀនឱ្យ

ប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈបានខ្ជាប់ខ្ជួនក្នុងការបំពេញភារកិច្ចប្រចាំថ្ងៃរបស់ខ្លួនដែលគិតជាប្រេកង់ និង គិតជាភាគរយ។

រាល់ទិន្នន័យទាំងអស់ដែលបានធ្វើការវិភាគរួច នឹងត្រូវបានទាញចេញមកបង្ហាញទៅតាមគោលបំណងសំខាន់ៗទាំងពីរនៃការសិក្សាស្រាវជ្រាវ ដើម្បីងាយស្រួលក្នុងការបង្ហាញ និងធ្វើសេចក្ដីសន្និដ្ឋានពីលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ។ បន្ទាប់ពីទទួលបានលទ្ធផលហើយ យើងនឹងទាញសេចក្ដីសន្និដ្ឋាន ព្រមទាំងធ្វើការផ្ទៀងផ្ទាត់ជាមួយចំណោទបញ្ហាដែលបានលើកឡើងជាសំណួរស្រាវជ្រាវ និងគោលបំណងនៃការសិក្សាស្រាវជ្រាវនេះ ហើយធ្វើការវាយតម្លៃទៅលើស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងបញ្ហាប្រឈមក្នុងការអនុវត្ត។ ជាចុងក្រោយបន្ទាប់ពីកំណត់បាននូវបញ្ហាប្រឈមក្នុងការក្នុងអនុវត្តស្តង់ដាវិជ្ជាជីវៈរបស់លោកគ្រូអ្នកគ្រូ យើងនឹងផ្តល់អនុសាសន៍មួយចំនួនដល់ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាក្នុងការអនុវត្តស្តង់ដាវិជ្ជាជីវៈប្រកបដោយប្រសិទ្ធភាព ។

## ៣.៤.១ កម្រិតចង្អុលបង្ហាញ

ការវាយតម្លៃលើស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន នៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ គឺប្រើតម្លៃបកស្រាយអត្ថន័យតម្លៃមធ្យមរបស់កម្រងសំណួរតាមបែបអត្រាវង្វាយតម្លៃកំណត់ពិន្ទុលើតម្លៃមធ្យម គឺយកតាមលំនាំពិន្ទុរបស់ Wannatawee ,Workham,&Panya(2017) ដោយបង្ហាញលទ្ធផលដូចខាងក្រោម៖

Mean=៤.៥១- ៥.00 មានន័យថា កម្រិតអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមធ្យមសិក្សាស្ថិតនៅកម្រិត**ខ្ពស់បំផុត**

Mean=៣.៥១- ៤.៥0 មានន័យថា កម្រិតអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមធ្យមសិក្សាស្ថិតនៅកម្រិត**ខ្ពស់**

Mean=២.៥១- ៣.៥0 មានន័យថា កម្រិតអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមធ្យមសិក្សាស្ថិតនៅកម្រិត**មធ្យម**

Mean=១.៥១- ២.៥០ មានន័យថា កម្រិតអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមធ្យមសិក្សាស្ថិតនៅកម្រិត**ទាប**

Mean=១.៥១- ២.៥០ មានន័យថា កម្រិតអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមធ្យមសិក្សាស្ថិតនៅកម្រិត**ទាបបំផុត**

### ៣.៤.២ ដំណាក់កាលនៃការវិភាគទិន្នន័យ

នៅក្នុងដំណាក់កាលនៃការវិភាគទិន្នន័យ អ្នកសិក្សាស្រាវជ្រាវធ្វើការវិភាគទិន្នន័យដែលប្រមូលបានតាមរយៈការបំពេញកម្រងសំណួរពីអ្នកចូលរួមនានា។ ការវិភាគកម្រងសំណួរមានគោលបំណងស្វែងរកឲ្យឃើញ ពីកម្រិតនៃការយល់ដឹងរបស់ពួកគាត់ទាក់ទងនឹងការអនុវត្តស្តង់ដាវិជ្ជាជីវៈរបស់គ្រូបង្រៀន។ ការបំពេញភារកិច្ចតាមបំណែងចែកភារកិច្ចរបស់អនុវិទ្យាល័យដែលពួកគាត់កំពុងបំពេញការងារ ការយល់ដឹងអំពីស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងការយល់ឃើញរបស់ លោកគ្រូ អ្នកគ្រូក្នុងការចូលរួមរកដំណោះស្រាយ ដើម្បីឱ្យការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមានភាពប្រសើរឡើង។

### ៣.៤.៣ ការបកស្រាយទិន្នន័យ

ទិន្នន័យលើកម្រងសំណួរសម្រាប់អ្នកពាក់ព័ន្ធ លោកគ្រូ អ្នកគ្រូ ត្រូវបានវិភាគរួមគ្នាតែម្តង មុនដំបូងយើងធ្វើការបកស្រាយទៅលើទិន្ន័យរួមទាំង ១៥០ នាក់ ហើយយើងក៏ធ្វើការបែងចែកការវិភាគផងដែរទៅតាមតំបន់ដែលអនុវិទ្យាល័យនីមួយៗស្ថិតនៅ ដើម្បីឆ្លុះបញ្ចាំងលក្ខណៈដោយឡែករបស់តំបន់នីមួយៗលើចំណុចមួយចំនួន ព្រមទាំងធ្វើការវិភាគ និងវាយតម្លៃសម្រាប់កម្រិតខេត្តទាំងមូល។

### ៣.៤.៤ ការវិភាគទិន្នន័យលើកម្រងសំណួរ

កម្រងសំណួរ ដែលប្រមូលបានពីក្រុមគោលដៅក្នុងការផ្តល់ទិន្នន័យ ត្រូវបានយកមករៀបចំតាមតំបន់ សម្រាប់ជាមូលដ្ឋានក្នុងការវិភាគទិន្នន័យបរិមាណវិស័យ។ ការវិភាគទិន្នន័យដោយផ្តោតទៅលើ៖ ១មធ្យមភាគពិន្ទុ(២ (%)ភាគរយ ((Mean)និង ៣ គម្លាតស្តង់ដា( Standard Deviatation)។ សំណួរស្រាវជ្រាវទី១ គឺវិភាគទៅលើកម្រងសំណួរ ដែលផ្តោតទៅលើសូចនាករគន្លឹះ សំណួរស្រាជ្រាវទី២ គឺធ្វើការទទួលបានពីលទ្ធផលនៃសំណួរស្រាវជ្រាទី១ ។អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរ

ដែលមានលក្ខណៈពហុជ្រើសរើសទៅតាមកម្រិតចង្អុលបង្ហាញនីមួយៗ សំណួរជាការតេស្តចំណេះដឹងក្នុងទម្រង់បិទ និងការផ្តល់មតិយោបល់សម្រាប់ស្វែងរកទិន្នន័យជាធាតុចូលបន្ថែម។ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ Microsoft Exell ដើម្បីសិក្សាពីភាគរយ មធ្យមភាពពិន្ទុ និងគម្លាតស្តង់ដា ដើម្បីវិភាគទៅលើស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈ បញ្ហាប្រឈម និងដំណោះស្រាយក្នុងការអនុវត្តនៅតាមសាលាមធ្យមសិក្សាបឋមភូមិក្នុង ខេត្តតាកែវ។

## ៣.៥ ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ

ដើម្បីរក្សាក្រមសីលធម៌ក្នុងការសិក្សាស្រាវជ្រាវ យើងបានធ្វើការណែនាំខ្លួន និងប្រាប់ពីគោលបំណង រយៈពេលសុំសម្ភាសន៍ ការសន្យាលើលក្ខខណ្ឌមួយចំនួនដូចជា រក្សាការសម្ងាត់ជូនគាត់ ព័ត៌មានដែលទទួលបានមិនត្រូវបានយកទៅប្រើប្រាស់ ក្នុងគោលបំណងផ្សេងទៀតឡើយ ។

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

# ជំពូក៤៖ លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

ជំពូកទី៤នេះនឹងបង្ហាញពីលទ្ធផល នៃការវិភាគទិន្នន័យលើប្រធានបទ៖ ការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ។ លទ្ធផលនៃការវិភាគទិន្នន័យ ត្រូវបានយកមកបកស្រាយ តាមរបៀបដូចខាងក្រោម៖

## ៤.១.លទ្ធផលស្រាវជ្រាវ

### ៤.១.១.ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន នៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ

#### ក.ចំណេះដឹងវិជ្ជាជីវៈ

តារាងទី១ បង្ហាញថាស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនទៅលើសមាសភាគទី១ ចំណេះដឹងវិជ្ជាជីវៈ ត្រង់សូចនាករទី២ (Mean=4.73,SD=0.97) បង្ហាញថា ការអនុវត្តទៅលើផ្នែកនេះរបស់លោកគ្រូ-អ្នកគ្រូបានល្អណាស់ ដោយលោកគ្រូ-អ្នកគ្រូ បានវាយតម្លៃទៅលើលទ្ធផលសិក្សារបស់សិស្សបានល្អ យល់ដឹងពីសមត្ថភាពសិស្ស និងយល់ពីឥរិយាបថសិក្សារបស់សិស្ស។ សូចនាករទី៣ (Mean=4.60,SD=1.07) ក៏បង្ហាញពីកម្រិតនៃការយល់ដឹងរបស់លោកគ្រូ-អ្នកគ្រូបានល្អ ទៅលើការសិក្សារបស់សិស្ស។ គាត់បានអនុវត្តជាប្រចាំទៅលើរបៀបនៃការសិក្សារបស់សិស្ស និងតាមដានសកម្មភាពរៀនរបស់សិស្ស។ សូចនាករទី៧ (Mean=4.84, SD=0.71) លោកគ្រូ-អ្នកគ្រូយល់ដឹងបានច្បាស់ពីលំនាំនៃការសរសេរកិច្ចតែងការ។ សូចនាករទី៩ (Mean= 4.30,SD=1.06) បង្ហាញកម្រិតខ្ពស់ ដោយលោកគ្រូ-អ្នកគ្រូរៀបចំបរិស្ថានសិក្សាបានស្អាតជាប្រចាំ តាមរយៈការបែងចែកសិស្សជាវេនសម្អាតជាប្រចាំ ដើម្បីឱ្យបរិស្ថានថ្នាក់រៀនស្អាត បង្កើនបរិយាកាសរៀនសូត្ររបស់សិស្ស។ សូចនាករទី១០ (Mean=4.75,SD=0.86) បង្ហាញថាលោកគ្រូ អ្នកគ្រូអនុវត្តបានល្អណាស់ទៅលើការវាយតម្លៃការស្វ័យសិក្សារបស់សិស្សជាប្រចាំដោយបណ្តុះស្មារតីសិស្សឱ្យចេះស្វ័យសិក្សា។ សូចនាករទី១ ( Mean=3.33,SD=1.94) បង្ហាញថាការអនុវត្តនៅ កម្រិតមធ្យម លោកគ្រូ-អ្នកគ្រូ ពុំសូវយល់ដឹងទៅលើខ្លឹមសារសមាសភាគទាំង៤ របស់

ស្តង់ដាវិជ្ជាៈគ្រូបង្រៀន។ សូចនាករទី៥ (Mean= 2.58,SD=1.34) ស្ថិតក្នុងកម្រិតមធ្យម លោកគ្រូ-អ្នកគ្រូយល់ដឹងពីគោលដៅនៃការអប់រំជាតិនៅមានកម្រិត ពុំសូវមានការពង្រឹងចំណេះដឹងបន្ថែម។ សូចនាករទី៨ (Mean=3.29,SD-1.95) បង្ហាញថាកម្រិតមធ្យម។ លោកគ្រូ-អ្នកគ្រូពុំសូវមានការយល់ដឹងទៅលើម៉ោងដែលត្រូវបង្រៀន។ សូចនាករទី១១ កម្រិតនៃការអនុវត្តមធ្យម (Mean=2.93,SD=0.53)។ សូចនាករទី៤ (Mean=2.07,SD=1.39) បង្ហាញពីពិន្ទុកម្រិតទាប ពោលគឺលោកគ្រូ-អ្នកគ្រូពុំបានដឹងឬយល់ពីគោលនយោបាយអប់រំទាល់តែសោះ។ សូចនាករទី ៦ ទទួលបានកម្រិតពិន្ទុទាប (Mean=1.53,SD= 0.93)។ នៅក្នុងផ្នែកនេះយើងរកឃើញចំណុចដែលត្រូវកែលម្អគឺមានសូចនាករទី១,៥,៨,១១ ដែលជាចំណុចស្ថិតក្នុងកម្រិតអនុវត្តមធ្យម និងសូចនាករទី ៤,៦ ដែលបង្ហាញ កម្រិតនៃការអនុវត្តទាប។

***តារាងទី១៖បង្ហាញពីតម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតអនុវត្តស្តង់ដាវិជ្ជាជីវៈរបស់គ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិ លើសមាសភាគទី១ (ចំណេះដឹងវិជ្ជាជីវៈ)***

| ល.រ | **ចំណេះដឹងវិជ្ជាជីវៈ** | Mean | SD | កម្រិតអនុវត្ត |
|---|---|---|---|---|
| ១ | តើសមាសភាគ ដែលមានចែងក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមានប៉ុន្មាន?អ្វីខ្លះ?ចូររៀបរាប់។ | 3.33 | 1.94 | មធ្យម |
| ២ | តើសិស្សដែលលោកគ្រូ អ្នកគ្រូបង្រៀន មានខ្សោយប៉ុន្មានភាគរយ មធ្យមប៉ុន្មានភាគរយ ល្អបង្គួរប៉ុន្មានភាគរយ ល្អប៉ុន្មានភាគរយ និងល្អប្រសើរមានប៉ុន្មានភាគរយ? | 4.73 | 0.97 | ខ្ពស់បំផុត |
| ៣ | តើសិស្សដែលលោកគ្រូ អ្នកគ្រូបង្រៀន យកចិត្តទុកដាក់និងខិតខំស្វ័យសិក្សាដោយខ្លួនឯងប៉ុន្មាន%? | 4.60 | 1.07 | ខ្ពស់បំផុត |
| ៤ | តើគោលនយោបាយអប់រំមានប៉ុន្មាន? អ្វីខ្លះ? សូមលោកគ្រូ - អ្នកគ្រូ រៀបរាប់។ | 2.07 | 1.39 | ទាប |

| | | | | |
|---|---|---|---|---|
| ៥ | តើគោលដៅនៃការអប់រំរបស់កម្ពុជាចង់បានធនធានមនុស្ស បែបណាដើម្បីប្រែក្លាយប្រទេសទៅជាប្រទេសមានចំណូល មធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសអភិវឌ្ឍន៍នៅ ឆ្នាំ២០៥០ ? | 2.58 | 1.04 | មធ្យម |
| ៦ | ចាប់ពីឆ្នាំ២០១៣ រហូតមកដល់បច្ចុប្បន្ននេះ តើក្រសួង អប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ប៉ុន្មានដំណាក់ កាលហើយ ?តើដំណាក់កាលនីមួយៗផ្តោតលើអ្វីខ្លះ ? | 1.53 | 0.93 | ទាប |
| ៧ | សូមលោកគ្រូ - អ្នកគ្រូតម្រៀបជំហាននៃការសរសេរកិច្ច តែងការបង្រៀនខាងក្រោមឱ្យត្រូវតាមលំដាប់។ | 4.84 | 0.71 | ខ្ពស់បំផុត |
| ៨ | តើនៅក្នុង១សប្តាហ៍ អ្នកគ្រូ - លោកគ្រូបង្រៀនប៉ុន្មាន ម៉ោង ? | 3.29 | 1.95 | មធ្យម |
| ៩ | តើលោកគ្រូ - អ្នកគ្រូអាចបានរៀបចំបរិស្ថានសិក្សាក្នុងថ្នាក់ បានប៉ុន្មានភាគរយ ? | 4.30 | 1.06 | ខ្ពស់ |
| ១០ | តើសិស្សរបស់លោកគ្រូ-អ្នកគ្រូ ធ្វើកិច្ចការផ្ទះ ខ្សោយប៉ុន្មាន ភាគរយ មធ្យមប៉ុន្មានភាគរយ ល្អបង្គួរប៉ុន្មានភាគរយ ល្អ ប៉ុន្មានភាគរយ និងល្អប្រសើរប៉ុន្មានភាគរយ ? | 4.75 | 0.86 | ខ្ពស់បំផុត |
| ១១ | តើលោកគ្រូ - អ្នកគ្រូ អាចប្រៀបធៀបសមត្ថភាពសិស្ស ដោយរបៀបណា ? | 2.93 | 0.53 | មធ្យម |
| សរុប | | 3.54 | 1.62 | ខ្ពស់ |

## ខ.ការប្រតិបត្តិវិជ្ជាជីវៈ

តារាងទី២ បង្ហាញពីលទ្ធផលកម្រិតពិន្ទុសរុបនៃការប្រតិបត្តិវិជ្ជាជីវៈ គឺកម្រិតមធ្យម (Mean =3.16, SD=1.20) ដែលនៅក្នុងផ្នែកនេះយើងឃើញថាសូចនាករដែលត្រូវបានលើកយកមកឱ្យលោកគ្រូ-អ្នកគ្រូធ្វើការបំពេញនូវចម្លើយ មានទាំងអស់១២ សូចនាករ ហើយក្នុងនោះសូចនាករដែលទទួលបានពិន្ទុកម្រិតខ្ពស់ជាងគេគឺមានតែ២សូចនាករ ពោលគឺសូចនាករទី១ (Mean=4.08 ,SD=1.00) លោកគ្រូ-អ្នកគ្រូមានការរៀបចំកិច្ចតែងការបង្រៀនបានច្រើន និងអនុវត្តនូវការសរសេរកិច្ចតែងការបានជាប្រចាំ។ សូចនាករដែលមានកម្រិតពិន្ទុខ្ពស់ដែរនោះ គឺសូចនាករទី៦ (Mean=4.39,SD=1.15) លោកគ្រូ-អ្នកគ្រូបានដឹកនាំសិស្សឱ្យចូលរួមសម្អាតបរិស្ថានបានល្អ។រីឯសូចនាករចំនួន៨ទៀតទទួលបានកម្រិតពិន្ទុមធ្យមដែលជាចំណុចត្រូវកែលម្អបន្ថែមទៀត។ សូចនាករទី២ (Mean=3.06,SD=1.19) បង្ហាញនូវកម្រិតពិន្ទុមធ្យមមានន័យថាលោកគ្រូ - អ្នកគ្រូមិនសូវបានរៀបចំសម្ភារឧបទេសសម្រាប់ការបង្រៀនបានល្អទេ។ សូចនាករទី៣ (Mean=2.82,SD=0.63) បង្ហាញពីកម្រិតពិន្ទុមធ្យម លោកគ្រូ- អ្នកគ្រូប្រើប្រាស់វិធីវាយតម្លៃសិស្សមិនទាន់សម្បូរបែប ភាគច្រើនគាត់ប្រើវិធីដដែលៗ និងមិនសូវមានសុក្រឹតភាព។ សូចនាករទី ៤ (Mean= 3.21, SD= 1.20) បង្ហាញថាស្ថិតក្នុងកម្រិតពិន្ទុមធ្យម មានន័យថាលោកគ្រូ-អ្នកគ្រូមិនសូវបានកត់ត្រានូវភាពរីកចម្រើនរបស់សិស្សបានល្អនោះទេ។ សូចនាករទី៥ (Mean= 2.64, SD= 1.52) បង្ហាញថាកម្រិតពិន្ទុមធ្យម លោកគ្រូ-អ្នកគ្រូមិនបានផ្តល់សៀវភៅតាមដានការសិក្សាទៅអាណាព្យាបាលរបស់សិស្សបានជាប់លាប់ ឬអត់បានជូនសោះតែម្តង។ សូចនាករទី៧ (Mean=2.98, SD=0.86) បង្ហាញកម្រិតពិន្ទុមធ្យម លោកគ្រូ-អ្នកគ្រូ បានចូលរួមពង្រឹងសិស្សខ្សោយរបស់ខ្លួននៅមានកម្រិត។ សូចនាករទី៨ (Mean=2.97, SD=0.83) លោកគ្រូ-អ្នកគ្រូដឹកនាំសិស្សឱ្យចេះចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍សាលារៀននៅមានកម្រិត។ សូចនាករទី៩ (Mean=2.71,SD=0.84) បង្ហាញកម្រិតពិន្ទុមធ្យម លោកគ្រូ-អ្នកគ្រូប្រើប្រាស់វិធីបង្រៀនផ្សេងៗដើម្បីសម្រួលដល់ការសិក្សារបស់សិស្សមិនទាន់សម្បូរបែបនៅឡើយ។ សូចនាករទី១០ (Mean=2.90, 1.28) បង្ហាញកម្រិតពិន្ទុមធ្យម លោកគ្រូ-អ្នកគ្រូមិនសូវបានប្រើប្រាស់វិធីប្លែកៗឱ្យស្របតាមការសិក្សារបស់សិស្សនៅឡើយទេ។ សូចនាករទី១១ (Mean= 2.77,SD=2.77) លោកគ្រូ-អ្នកគ្រូមិន

សូវផ្តល់ឱកាសឱ្យសិស្សបានដោះស្រាយបញ្ហាដោយខ្លួនឯងទេ។ សូចនាករទី១២ (Mean=3.38,SD=1.07) បង្ហាញថាកម្រិតពិន្ទុមធ្យម លោកគ្រូ-អ្នកគ្រូមានការយល់ដឹងពីសារៈសំខាន់ លើការប្រើប្រាស់បំណិនបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍នៅមានកម្រិតទាប។

***តារាងទី២៖បង្ហាញពីតម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតអនុវត្តស្តង់ដាវិជ្ជាជីវៈរបស់គ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិ លើសមាសភាគទី២(ការប្រតិបត្តិវិជ្ជាជីវៈ)***

| ល.រ | ការប្រតិបត្តិវិជ្ជាជីវៈ | Mean | SD | កម្រិតអនុវត្ត |
|---|---|---|---|---|
| ១ | តើលោកគ្រូ - អ្នកគ្រូ រៀបចំកិច្ចតែងការបង្រៀនសម្រាប់មេរៀនបានប៉ុន្មានភាគរយ? | 4.08 | 1.00 | ខ្ពស់ |
| ២ | តើលោកគ្រូ-អ្នកគ្រូ រៀបចំសម្ភារឧបទេសបង្រៀនសម្រាប់មេរៀនបានប៉ុន្មានភាគរយ? | 3.06 | 1.19 | មធ្យម |
| ៣ | តើលោកគ្រូ-អ្នកគ្រូ ប្រើប្រាស់វិធីអ្វីខ្លះក្នុងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស?ចូររៀបរាប់។ | 2.82 | 0.63 | មធ្យម |
| ៤ | តើលោកគ្រូ-អ្នកគ្រូមានការកត់ត្រាការរីកចម្រើនរបស់សិស្សបានប៉ុន្មានភាគរយ? | 3.21 | 1.20 | មធ្យម |
| ៥ | តើលោកគ្រូ-អ្នកគ្រូបានផ្តល់សៀវភៅតាមដានការសិក្សារបស់សិស្សទៅអាណាព្យាបាលសិស្សបានប៉ុន្មានភាគរយ? | 2.64 | 1.52 | មធ្យម |
| ៦ | តើលោកគ្រូ-អ្នកគ្រូ ដឹកនាំសិស្សឱ្យចូលរួមសម្អាតថ្នាក់រៀនបានប៉ុន្មានភាគរយ? | 4.39 | 1.15 | ខ្ពស់ |

| | | | | |
|---|---|---|---|---|
| ៧ | តើលោកគ្រូ-អ្នកគ្រូបានពង្រឹងសិស្សខ្សោយរបស់ខ្លួនដោយរបៀបណាខ្លះ? | 2.98 | 0.86 | មធ្យម |
| ៨ | តើសិស្សដែលលោកគ្រូ-អ្នកគ្រូបង្រៀន បានចូលរួមសកម្មភាពអ្វីខ្លះដើម្បីអភិវឌ្ឍសាលារៀន? | 2.97 | 0.83 | មធ្យម |
| ៩ | តើ លោកគ្រូ- អ្នកគ្រូ ប្រើប្រាស់វិធីបង្រៀនផ្សេងៗអ្វីខ្លះដើម្បីសម្រួលដល់ការសិក្សារបស់សិស្ស? | 2.71 | 0.84 | មធ្យម |
| ១០ | តើលោកគ្រូ- អ្នកគ្រូ ប្រើប្រាស់វិធីសាស្ត្របង្រៀនប្លែកៗ ឱ្យស្របតាមការសិក្សារបស់សិស្សបានប៉ុន្មានភាគរយ? | 2.90 | 1.28 | មធ្យម |
| ១១ | តើលោកគ្រូ-អ្នកគ្រូ ផ្តល់ឱកាសឱ្យសិស្ស ដោះស្រាយបញ្ហាដោយខ្លួនឯងបានប៉ុន្មានភាគរយ? | 2.77 | 1.21 | មធ្យម |
| ១២ | តើលោកគ្រូ- អ្នកគ្រូមានយល់ដឹងពីសារៈសំខាន់លើការប្រើប្រាស់បំណិនបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍បានកម្រិតណា? | 3.38 | 1.07 | មធ្យម |
| សរុប | | 3.16 | 1.20 | មធ្យម |

## **គ.ការសិក្សាវិជ្ជាជីវៈ**

តារាងទី៣ បង្ហាញថា ការអនុវត្ត ការសិក្សាវិជ្ជាជីវៈមានកម្រិតពិន្ទុមធ្យម (Mean=3.31,SD=1.51) ។ នៅក្នុងផ្នែកនេះយើងឃើញថាសូចនាករដែលត្រូវបានលើកយកមកឱ្យលោកគ្រូ- អ្នកគ្រូធ្វើការបំពេញនូវចម្លើយ មានទាំងអស់៥ សូចនាករ ហើយក្នុងនោះសូចនាករដែលទទួលបានពិន្ទុកម្រិតខ្ពស់ជាងគេគឺមានតែ១សូចនាករប៉ុណ្ណោះ ពោលគឺសូចនាករទី៣ (Mean=3.75,SD=1.09)។ លទ្ធផលនេះបង្ហាញឱ្យឃើញថាលោកគ្រូ-អ្នកគ្រូ មានការយល់ដឹងច្បាស់ពីបំណិនទំនាក់ទំនងជាមួយសិស្ស មាតាបិតា មិត្តរួមអាជីព និងសហគមន៍ ។ សូចនាករ៤ទៀត ទទួលបានពិន្ទុកម្រិតមធ្យមលើកម្រិតនៃការអនុវត្ត ជាចំណុចដែលត្រូវ

កែលម្អ។ សូចនាករទី១(Mean=3.27,SD=1.19)បង្ហាញពិន្ទុកម្រិតមធ្យម។ លោកគ្រូ- អ្នកគ្រូ មានការស្វ័យវាយតម្លៃការងាររបស់ខ្លួនទាប។ សូចនាករទី២ (Mean= 3.18,SD=3.18) ក៏បង្ហាញពីកម្រិតពិន្ទុនៃការអនុវត្តមធ្យមដែរ មានន័យថា លោកគ្រូ-អ្នកគ្រូមានចំណេះដឹងទៅលើបំណិនបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ទាប។ សូចនាករទី៤ (Mean=3.47,SD=1.92) លោកគ្រូ-អ្នកគ្រូ មួយចំនួនមិនធ្លាប់ស្គាល់ឬអានអត្ថបទស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនថាជាអ្វី។ សូចនាករទី៥(Mean=2.87,SD=1.95) បង្ហាញកម្រិតពិន្ទុមធ្យម មានន័យថាលោកគ្រូ- អ្នកគ្រូមួយចំនួន ធ្លាប់បានចូលរួមសិក្ខាសាលា ឬវគ្គបំប៉ន និងបានកត់ត្រាឈ្មោះសិក្ខាសាលាបានខ្លះៗ។

***តារាងទី៣៖បង្ហាញពីតម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតអនុវត្តស្តង់ដាវិជ្ជាជីវៈរបស់គ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិ លើសមាសភាគទី៣ (ការសិក្សាវិជ្ជាជីវៈ)***

| ល.រ | ការសិក្សាវិជ្ជាជីវៈ | Mean | SD | កម្រិតអនុវត្ត |
|---|---|---|---|---|
| ១ | តើលោកគ្រូ-អ្នកគ្រូស្វ័យវាយតម្លៃការងាររបស់ខ្លួនបានប៉ុន្មានភាគរយ? | 3.27 | 1.19 | មធ្យម |
| ២ | តើលោកគ្រូ- អ្នកគ្រូមានចំណេះដឹងទៅលើបំណិនបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍កម្រិតណា? | 3.18 | 1.00 | មធ្យម |
| ៣ | តើលោកគ្រូ-អ្នកគ្រូ យល់ច្បាស់នូវបំណិនទំនាក់ទំនងជាមួយសិស្ស មាតាបិតា មិត្តរួមអាជីព និងសហគមន៍កម្រិតណា? | 3.75 | 1.09 | ខ្ពស់ |
| ៤ | តើលោកគ្រូ-អ្នកគ្រូ ធ្លាប់ស្គាល់ឬអានអត្ថបទស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនដែរឬទេ ? | 3.47 | 1.92 | មធ្យម |

| | | | | |
|---|---|---|---|---|
| ៥ | តើលោកគ្រូ-អ្នកគ្រូ ធ្លាប់បានចូលរួមសិក្ខាសាលា ឬវគ្គបំប៉នដែរឬទេ ? ចូរប្រាប់ឈ្មោះសិក្ខាសាលា ឬវគ្គបំប៉នដែលលោកគ្រូ-អ្នកគ្រូបានចូលរួម | 2.87 | 1.95 | មធ្យម |
| សរុប | | 3.31 | 1.51 | មធ្យម |

## ឃ.សីលធម៌វិជ្ជាជីវៈ

តារាងទី៤ បង្ហាញថាការអនុវត្តស្តង់ដារវិជ្ជាជីវៈរបស់គ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវលើសមាសភាគទី៤គឺ សីលធម៌វិជ្ជាជីវៈមានកម្រិតពិន្ទុមធ្យម(Mean=2.76,SD=0.86)។ ក្នុងសមាសភាគ នេះមានសូចនាករ ចំនួន៣ ហើយសូចនាករទាំងអស់សុទ្ធតែទទួលបានកម្រិតមធ្យម ដែលជាចំណុចត្រូវតែធ្វើការកែលម្អបន្ថែម ។ សូចនាករទី១ (Mean=2.69,SD=0.84) បង្ហាញកម្រិតពិន្ទុមធ្យម។ លោកគ្រូ-អ្នកគ្រូ នៅមិនទាន់មានការយកចិត្តទុកដាក់ និងថែរក្សាសិស្សតាមមធ្យោបាយច្រើនរូបភាពនៅឡើយ។ សូចនាករទី២ បង្ហាញកម្រិតពិន្ទុមធ្យម (Mean=3.00,SD=0.73)។ លោកគ្រូ-អ្នកគ្រូមិនសូវបានបង្ហាញនូវអាកប្បកិរិយាដែលជាគម្រូប្រកបដោយសីលធម៌ចំពោះសិស្ស។ សូចនាករទី៣ (Mean=2.60, SD=2.60) បង្ហាញកម្រិតពិន្ទុមធ្យម។ លោកគ្រូ-អ្នកគ្រូប្រើប្រាស់ភាសាយុត្តិធម៌ និងតម្លាភាពក្នុងការប្រព្រឹត្តជាមួយសិស្ស សហសេវិក និងសមាជិកផ្សេងៗទៀតរបស់សហគមន៍ មិនទាន់បានទូលំទូលាយនៅឡើយ។ ដូចនេះចំណុចទាំង៣នេះ លោកគ្រូ-អ្នកគ្រូ ត្រូវតែយកចិត្តទុកដាក់ពង្រឹងបន្ថែមទៀត។

***តារាងទី៤៖បង្ហាញពីតម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតអនុវត្តស្តង់ដារវិជ្ជាជីវៈរបស់គ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិ លើសមាសភាគទី៤ (សីលធម៌វិជ្ជាជីវៈ)***

| ល.រ | សីលធម៌វិជ្ជាជីវៈ | Mean | SD | កម្រិតអនុវត្ត |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| ១ | តើលោកគ្រូ-អ្នកគ្រូបង្ហាញពីការយកចិត្តទុកដាក់ និងថែរក្សាសិស្សតាមមធ្យោបាយអ្វីខ្លះ? | 2.69 | 0.84 | មធ្យម |
| ២ | តើលោកគ្រូ-អ្នកគ្រូ មានអាកប្បកិរិយាបែបណាក្នុងការបង្ហាញជាគម្រូប្រកបដោយសីលធម៌? | 3.00 | 0.73 | មធ្យម |
| ៣ | តើលោកគ្រូ-អ្នកគ្រូប្រើប្រាស់ភាសាយុត្តិធម៌ និងតម្លាភាពក្នុងការប្រព្រឹត្តជាមួយសិស្ស សហសេវិក និងសមាជិកផ្សេងៗទៀតរបស់សហគមន៍យ៉ាងដូចម្តេចខ្លះ? | 2.60 | 0.93 | មធ្យម |
| សរុប | | 2.76 | 0.86 | មធ្យម |

ជាងនេះទៀត បើសង្ខេបតារាងទាំង៤ខាងលើមកជាតារាងរួមមួយ ដើម្បីងាយស្រួលយល់ពីកម្រិតនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងតាកែវ តាមផ្នែកនីមួយៗ និងជារួមបានបង្ហាញដូចខាងក្រោម៖

***តារាងទី៥៖ បង្ហាញពីតម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតអនុវត្តស្តង់ដាវិជ្ជាជីវៈរបស់គ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ***

| ល.រ | ខ្លឹមសារអថេរគោល | Mean | SD | កម្រិតអនុវត្ត | លំដាប់ |
|---|---|---|---|---|---|
| ១ | .ចំណេះដឹងវិជ្ជាជីវៈ | 3.54 | 1.62 | ខ្ពស់ | 1 |
| ២ | .ការប្រតិបត្តិវិជ្ជាជីវៈ | 3.16 | 1.20 | មធ្យម | 3 |
| ៣ | .ការសិក្សាវិជ្ជាជីវៈ | 3.31 | 1.51 | មធ្យម | 2 |
| ៤ | .សីលធម៌វិជ្ជាជីវៈ | 2.76 | 0.86 | មធ្យម | 4 |
| សរុប | | 3.19 | 0.30 | មធ្យម | |

តារាងទី៥ នេះបានបង្ហាញជារួមនូវកម្រិតនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវគិតតាមតម្លៃមធ្យម និងគម្លាតស្តង់ដានៃផ្នែកសមាសភាគទាំង៤ពោល សមាសភាគទី១ ចំណេះដឹងវិជ្ជាជីវៈ សមាសភាគទី២ ការប្រតិបត្តិវិជ្ជាជីវៈ សមាសភាគទី៣ ការសិក្សាវិជ្ជាជីវៈ និងសមាសភាគទី៤ សីលធម៌វិជ្ជាជីវៈ។ តាមតារាងទី៥ នេះ មធ្យមពិន្ទុសរុបសម្រាប់ការអនុវត្តស្តង់ដាទាំងមូលស្ថិតក្នុងកម្រិតមធ្យម(Mean=3.19, SD=0.30) ហើយក្នុងចំណោមសមាសភាគទាំង៤នៃ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន សមាសភាគទី១ (ចំណេះដឹងវិជ្ជាជីវៈ) គ្រូបង្រៀនទទួលបានកម្រិតពិន្ទុខ្ពស់ជាងគេ (Mean=3.54,SD=1.62) មានន័យថា អនុវត្តបានល្អប្រសើរជាងគេ។ ចំពោះសមាសភាគ ៣ ផ្សេងទៀតមានកម្រិតពិន្ទុមធ្យមដូចគ្នា។ សមាសភាគទី៣ ការសិក្សាវិជ្ជាជីវៈបង្ហាញលំដាប់ពិន្ទុទី២ (Mean=3.31 ,SD=1.51) សមាសភាគទី២ ការប្រតិបត្តិវិជ្ជាជីវៈ បង្ហាញលំដាប់ពិន្ទុទី៣ (Mean=3.16 ,SD=1.20) និងសមាសភាគទី៤ បង្ហាញលំដាប់ពិន្ទុទី៤ (Mean=2.76,SD=0.86) ។

### ៤.១.២.ការប្រៀបធៀបតាមតំបន់លើ ការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន នៅសាលាមធ្យមសិក្សា បឋមភូមិក្នុងខេត្តតាកែវ

#### ក.ចំណេះដឹងវិជ្ជាជីវៈ

តាមតារាងប្រៀបធៀបទី៦ បង្ហាញថាចំណេះដឹងវិជ្ជាជីវៈរបស់លោកគ្រូ អ្នកគ្រូនៅតំបន់ដាច់ស្រយាល ទទួលបានកម្រិតពិន្ទុខ្ពស់ជាងគេ (Mean=3.62,SD=1.59) បន្ទាប់មកគឺនៅតំបន់ទីប្រជុំជន (Mean= 3.59,SD=1.62)។ រីឯ តំបន់ជនបទវិញកម្រិតនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមានកម្រិតទាបជាងគេបង្អស់(Mean =3.42,SD = 1.68)។

*តារាងទី៦៖ តារាងប្រៀបធៀបកម្រិតអនុវត្ត ចំណេះដឹងវិជ្ជាជីវៈតាមតំបន់*

| ល.រ | ចំណេះដឹងវិជ្ជាជីវៈ | Mean | SD | កម្រិតអនុវត្ត | លំដាប់ |
|---|---|---|---|---|---|
| ១ | តំបន់ទីប្រជុំជន | 3.59 | 1.62 | ខ្ពស់ | 2 |
| ២ | តំបន់ជនបទ | 3.42 | 1.68 | មធ្យម | 3 |

| ៣ | តំបន់ដាច់ស្រយាល | 3.62 | 1.59 | ខ្ពស់ | 1 |
|---|---|---|---|---|---|

## ខ.ការប្រតិបត្តិវិជ្ជាជីវៈ

តាមតារាងប្រៀបធៀបទី៧ បង្ហាញថាការប្រតិបត្តិវិជ្ជាជីវៈរបស់លោកគ្រូ អ្នកគ្រូនៅតំបន់ទាំងបីគឺមានកម្រិតអនុវត្តមធ្យមដូចគ្នា ដោយឡែកបើគិតតាមលំដាប់ តំបន់ដាច់ស្រយាលទទួលបានកម្រិតអនុវត្តពិន្ទុមធ្យមលំដាប់ទី១ (Mean=3.25,SD=0.95) តំបន់ប្រជុំជនទទួលបានកម្រិតអនុវត្តពិន្ទុមធ្យម លំដាប់ទី២ (Mean=3.12,SD=1.17) និងតំបន់ជនបទទទួលបានកម្រិតអនុវត្តពិន្ទុមធ្យមលំដាប់ទី៣ (Mean=3.10,SD = 1.07)

*តារាងទី៧៖ តារាងប្រៀបធៀបកម្រិតអនុវត្ត ការប្រតិបត្តិវិជ្ជាជីវៈតាមតំបន់*

| ល.រ | ការប្រតិបត្តិវិជ្ជាជីវៈ | Mean | SD | កម្រិតអនុវត្ត | លំដាប់ |
|---|---|---|---|---|---|
| ១ | តំបន់ទីប្រជុំជន | 3.10 | 1.07 | មធ្យម | 3 |
| ២ | តំបន់ជនបទ | 3.12 | 1.17 | មធ្យម | 2 |
| ៣ | តំបន់ដាច់ស្រយាល | 3.25 | 0.95 | មធ្យម | 1 |

## គ.ការសិក្សាវិជ្ជាជីវៈ

តាមតារាងប្រៀបធៀបទី៨បង្ហាញថា ការសិក្សាវិជ្ជាជីវៈរបស់លោកគ្រូ អ្នកគ្រូនៅតំបន់ទាំងបីគឺតំបន់ដាច់ស្រយាលមានកម្រិតអនុវត្តពិន្ទុខ្ពស់ជាងគេ (Mean=3.54 ,SD=1.42) បន្ទាប់មកទៀតតំបន់ទីប្រជុំជនទទួលបានកម្រិតអនុវត្តពិន្ទុខ្ពស់លំដាប់ទី២ (Mean=3.51,SD=1.50) និងតំបន់ជនបទទទួលបានកម្រិតអនុវត្តពិន្ទុមធ្យមលំដាប់ទី៣ទាបជាងគេ (Mean=2.88,SD=1.53)។

*តារាងទី៨៖ តារាងប្រៀបធៀបកម្រិតអនុវត្ត ការសិក្សាវិជ្ជាជីវៈតាមតំបន់*

| ល.រ | ការប្រតិបត្តិវិជ្ជាជីវៈ | Mean | SD | កម្រិតអនុវត្ត | លំដាប់ |
|---|---|---|---|---|---|
| ១ | តំបន់ទីប្រជុំជន | 3.51 | 1.50 | ខ្ពស់ | 2 |
| ២ | តំបន់ជនបទ | 2.88 | 1.53 | មធ្យម | 3 |
| ៣ | តំបន់ដាច់ស្រយាល | 3.54 | 1.42 | ខ្ពស់ | 1 |

## ឃ.សីលធម៌វិជ្ជាជីវៈ

តាមតារាងប្រៀបធៀបទី៩ បង្ហាញថាសីលធម៌វិជ្ជាជីវៈរបស់លោកគ្រូអ្នកគ្រូនៅតំបន់ទាំងបីគឺមានកម្រិតអនុវត្តពិន្ទុមធ្យមស្មើគ្នា ដោយឡែកបើគិតតាមលំដាប់ តំបន់ជនបទទទួលបានកម្រិតអនុវត្តពិន្ទុមធ្យលំដាប់ទី១ (Mean=2.87,SD=0.88) តំបន់ដាច់ស្រយាលទទួលបានកម្រិតអនុវត្តពិន្ទុមធ្យមលំដាប់ទី២ (Mean= 2.84 ,SD=0.64) និងតំបន់ប្រជុំជនទទួលបានកម្រិតអនុវត្តពិន្ទុមធ្យមលំដាប់ទី៣ (Mean =2.59,SD = 0.99)

*តារាងទី៩៖ តារាងប្រៀបធៀបកម្រិតអនុវត្ត សីលធម៌វិជ្ជាជីវៈតាមតំបន់*

| ល.រ | ការប្រតិបត្តិវិជ្ជាជីវៈ | Mean | SD | កម្រិតអនុវត្ត | លំដាប់ |
|---|---|---|---|---|---|
| ១ | តំបន់ទីប្រជុំជន | 2.59 | 0.99 | មធ្យម | 3 |
| ២ | តំបន់ជនបទ | 2.87 | 0.88 | មធ្យម | 1 |
| ៣ | តំបន់ដាច់ស្រយាល | 2.84 | 0.64 | មធ្យម | 2 |

### ៤.១.៣. ការវិភាគការអនុវត្តតាមតំបន់ លើការអនុវត្តស្តង់ដាវិជ្ជាជីវៈរបស់គ្រូបង្រៀន នៅសាលាមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តតាកែវ

## ក.តំបន់ទីប្រជុំជន

តារាងទី១០ នេះបង្ហាញពីការសរុបកម្រិតពិន្ទុនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន នៅសាលាមធ្យមសិក្សាបឋមភូមិក្នុងតំបន់ទីប្រជុំជន គិតតាមតម្លៃមធ្យម និងគម្លាតស្តង់ដា។ តាមផ្នែកនៃសមាស

ភាគនីមួយៗ ដែលសមាសភាគទាំងអស់មានចំនួន៤ សមាសភាគ គឺសមាសភាគទី១ចំណេះដឹងវិជ្ជាជីវៈ សមាសភាគទី២ ការប្រតិបត្តិវិជ្ជាជីវៈ សមាសភាគទី៣ ការសិក្សាវិជ្ជាជីវៈ និងសមាសភាគទី៤ សីលធម៌វិជ្ជាជីវៈ។ តាមរយៈតារាងទី១០នេះផងដែរយើងសង្កេតឃើញថា ការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅតំបន់ទីប្រជុំជនមានកម្រិតមធ្យម (Mean=3.19,SD=0.30) ហើយក្នុងចំណោមសមាសភាគទាំង៤ របស់ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន យើងសង្កេតឃើញថាចំណេះដឹងវិជ្ជាជីវៈរបស់គ្រូបង្រៀនទទួលបានកម្រិតអនុវត្តពិន្ទុខ្ពស់ជាងគេ (Mean=3.59,SD=1.62) ។ បន្ទាប់មកទៀតសមាសភាគទី៣ ការសិក្សាវិជ្ជាជីវៈបង្ហាញលំដាប់ពិន្ទុទី២ (Mean=3.51,SD=1.50) ហើយចំពោះសមាសភាគ២ ទៀត មានកម្រិតអនុវត្តពិន្ទុមធ្យមដូចគ្នា។ សមាសភាគទី២ ការប្រតិបត្តិវិជ្ជាជីវៈស្ថិតនៅលំដាប់ទី២ (Mean=3.12,SD=1.17) ស្ថិតក្នុងការអនុវត្តកម្រិតមធ្យម ។ សមាសភាគទី៣ ការសិក្សាវិជ្ជាជីវៈ ស្ថិតនៅលំដាប់លេខ៣ (Mean= 3.10, SD=1.07)និងសមាសភាគទី៤កម្រិតនៃការអនុវត្តស្ថិតនៅលំដាប់លេខ៤ (Mean=2.59,SD= 0.99)។

សរុបជាលទ្ធផលមកការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន នៅតំបន់ទីប្រជុំជនទទួលបានកម្រិតអនុវត្តពិន្ទុមធ្យម ដែលតំបន់នេះគ្រូកម្រិតមធ្យមសិក្សាបឋមភូមិត្រូវតែមានការកែលម្អបន្ថែមទៀត ដើម្បីឱ្យការអនុវត្តកាន់តែល្អប្រសើរ។

***តារាងទី១០៖ បង្ហាញពីតម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតអនុវត្តស្តង់ដាវិជ្ជាជីវៈរបស់គ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ នៅតំបន់ទីប្រជុំជន***

| ល.រ | ខ្លឹមសារអថេរគោល | Mean | SD | កម្រិតអនុវត្ត | លំដាប់ |
|---|---|---|---|---|---|
| ១ | .ចំណេះដឹងវិជ្ជាជីវៈ | 3.59 | 1.62 | ខ្ពស់ | 1 |
| ២ | .ការប្រតិបត្តិវិជ្ជាជីវៈ | 3.10 | 1.07 | មធ្យម | 3 |
| ៣ | .ការសិក្សាវិជ្ជាជីវៈ | 3.51 | 1.50 | ខ្ពស់ | 2 |
| ៤ | .សីលធម៌វិជ្ជាជីវៈ | 2.59 | 0.99 | មធ្យម | 4 |
| សរុប | | 3.20 | 1.30 | មធ្យម | |

## ខ.តំបន់ជនបទ

តារាងទី១១ បង្ហាញពីកម្រិតពិន្ទុសរុបនៃការអនុវត្តស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន នៅសាលាមធ្យមសិក្សាបឋមភូមិក្នុងតំបន់ជនបទគិតតាមតម្លៃមធ្យម និងគម្លាតស្តង់ដា។ តាមផ្នែកនៃសមាសភាគនីមួយៗដែលសមាសភាគទាំងអស់មានចំនួន៤ គឺ សមាសភាគទី១ ចំណេះដឹងវិជ្ជាជីវៈ សមាសភាគទី២ ការប្រតិបត្តិវិជ្ជាជីវៈ សមាសភាគទី៣ ការសិក្សាវិជ្ជាជីវៈ និងសមាសភាគទី៤ សីលធម៌វិជ្ជាជីវៈកម្រិតនៃការអនុវត្តទទួលបានមធ្យមពិន្ទុកម្រិតមធ្យម (Mean=3.07,SD=1.31) ។ ក្នុងចំណោមនោះចំណេះដឹងវិជ្ជាជីវៈគ្រូបង្រៀនទទួលបានកម្រិតអនុវត្តពិន្ទុខ្ពស់ជាងគេ (Mean=3.42,SD=1.68) ។ ចំពោះសមាសភាគ៣ ទៀតកម្រិតនៃការអនុវត្តគឺមធ្យមដូចគ្នា។ សមាសភាគទី២ ការប្រតិបត្តិវិជ្ជាជីវៈស្ថិតនៅលំដាប់ទី២ (Mean=3.12,SD=1.17) ស្ថិតក្នុងការអនុវត្តកម្រិតមធ្យម ។ សមាសភាគទី៣ ការសិក្សាវិជ្ជាជីវៈ ស្ថិតនៅលំដាប់លេខ៣ (Mean= 2.88, SD=1.53)និងសមាសភាគទី៤កម្រិតនៃការអនុវត្តស្ថិតនៅលំដាប់លេខ៤ (Mean=2.87,SD= 0.88)។

សរុបជាលទ្ធផលមកការអនុវត្តស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន នៅតំបន់ជនបទក៏ទទួលបានកម្រិតពិន្ទុមធ្យម ដែលទាមទារឱ្យគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិត្រូវតែមានការកែលម្អបន្ថែមទៀតដើម្បីឱ្យការអនុវត្តកាន់តែល្អប្រសើរ។

***តារាងទី១១៖ បង្ហាញពីតម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតអនុវត្តស្តង់ដារវិជ្ជាជីវៈរបស់គ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ នៅតំបន់ជនបទ***

| ល.រ | ខ្លឹមសារអថេរគោល | Mean | SD | កម្រិតអនុវត្ត | លំដាប់ |
|---|---|---|---|---|---|
| ១ | .ចំណេះដឹងវិជ្ជាជីវៈ | 3.42 | 1.68 | ខ្ពស់ | 1 |
| ២ | .ការប្រតិបត្តិវិជ្ជាជីវៈ | 3.12 | 1.17 | មធ្យម | 3 |
| ៣ | .ការសិក្សាវិជ្ជាជីវៈ | 2.88 | 1.53 | មធ្យម | 2 |

| | | | | | |
|---|---|---|---|---|---|
| ៤ | .សីលធម៌វិជ្ជាជីវៈ | 2.87 | 0.88 | មធ្យម | 4 |
| សរុប | | 3.07 | 1.31 | មធ្យម | |

## គ.តំបន់ដាច់ស្រយាល

តារាងទី១២ បង្ហាញពីកម្រិតពិន្ទុសរុបនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងតំបន់ដាច់ស្រយាល គិតតាមតម្លៃមធ្យម និងគម្លាតស្តង់ដា។ សរុបជារួមគឺទទួលបានកម្រិតនៃការអនុវត្តមធ្យម (Mean=3.31,SD=1.15) ។ ក្នុងចំណោមសមាសភាគទាំង៤ សមាសភាគទី១គឺចំណេះដឹងវិជ្ជាជីវៈ ទទួលបានកម្រិតអនុវត្ត ខ្ពស់ជាងគេ (Mean=3.62,SD=1.59) ។ សមាសភាគទី៣ គឺការសិក្សាវិជ្ជាជីវៈទទួលបានកម្រិតអនុវត្តលំដាប់ ទី២ (Mean=3.12,SD=1.17) សមាសភាគទី២ គឺការប្រតិបត្តិវិជ្ជាជីវៈ ទទួលបានកម្រិតអនុវត្តលំដាប់លេខ៣ (Mean= 3.25,SD=0.95 )និងសមាសភាគទី៤ គឺសីលធម៌វិជ្ជាជីវៈ ទទួលបានកម្រិតអនុវត្តនៅលំដាប់លេខ៤ (Mean=2.84,SD=0.64)។

សរុបជាលទ្ធផលមកការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន នៅតំបន់ជនបទ ក៏ទទួលបានកម្រិតអនុវត្តមធ្យមដែរដែលទាមទារឱ្យ គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវត្រូវតែមានការកែលម្អបន្ថែមទៀត ដើម្បីឱ្យការអនុវត្តកាន់តែល្អប្រសើរ។

***តារាងទី១២៖ បង្ហាញពីតម្លៃមធ្យម គម្លាតស្តង់ដា និងកម្រិតអនុវត្តស្តង់ដាវិជ្ជាជីវៈរបស់គ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ នៅតំបន់ដាច់ស្រយាល***

| ល.រ | ខ្លឹមសារអថេរគោល | Mean | SD | កម្រិតអនុវត្ត | លំដាប់ |
|---|---|---|---|---|---|
| ១ | .ចំណេះដឹងវិជ្ជាជីវៈ | 3.62 | 1.59 | ខ្ពស់ | 1 |
| ២ | .ការប្រតិបត្តិវិជ្ជាជីវៈ | 3.25 | 0.95 | មធ្យម | 3 |
| ៣ | .ការសិក្សាវិជ្ជាជីវៈ | 3.54 | 1.42 | ខ្ពស់ | 2 |

| | | | | | |
|---|---|---|---|---|---|
| ៤ | .សីលធម៌វិជ្ជាជីវៈ | 2.84 | 0.64 | មធ្យម | 4 |
| សរុប | | 3.31 | 1.15 | មធ្យម | |

### ៤.១.៤. បញ្ហាប្រឈមមួយចំនួនរបស់គ្រូបង្រៀន ក្នុងការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

តាមរយៈលទ្ធផលខាងលើបានបង្ហាញថាការអនុវត្តមិនទាន់បានល្អប្រសើរស្មើរតែគ្រប់ចំណុច ដូចនេះបញ្ហាប្រឈមក៏មានច្រើនដែរ តាមតារាងទី៦ លទ្ធផលនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនទៅលើសមាសភាគទាំង៤ ឃើញថាកម្រិតល្អគឺមានតែចំណេះដឹងវិជ្ជាជីវៈគ្រូបង្រៀនតែប៉ុណ្ណោះ ចំណែកឯសមាសភាគ៣ទៀត មានការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ ស្ថិតនៅក្នុងកម្រិតមធ្យមនៅឡើយ ដែលនេះជាបញ្ហាប្រឈម។ ម្យ៉ាងវិញទៀត ក្នុងសមាសភាគនីមួយៗមានសូចនាករជាច្រើនទៀតដែលយើងអាចទាញរកបញ្ហាប្រឈមនៃការអនុវត្តនោះបានកាន់តែច្បាស់។ ជាក់ស្តែង នៅក្នុងសមាសភាគទី២ ការប្រតិបត្តិវិជ្ជាជីវៈ លោកគ្រូ-អ្នកគ្រូភាគច្រើនបានពិន្ទុតិចទៅលើការរៀបចំសម្ភារឧបទេស ដែលនៅមិនទាន់សម្បូរបែបនៅឡើយ មានន័យថាលោកគ្រូ អ្នកគ្រូមិនសូវមានពេលចំណាយទៅលើការបង្កើតសម្ភារឧបទេសទេ ភាគច្រើនគាត់បង្រៀនដោយប្រើទ្រឹស្តីតាមសៀវភៅ។ លោកគ្រូ-អ្នកគ្រូមិនបានផ្តល់សៀវភៅតាមដានការសិក្សាទៅអាណាព្យាបាលរបស់សិស្សបានជាប់លាប់ ឬអត់បានជូនសោះតែម្តង។ នៅក្នុងការសិក្សាវិជ្ជាជីវៈ ពួកគាត់ជួបបញ្ហាប្រឈមខ្លាំងជាងគេគឺពួកគាត់ភាគច្រើនពុំមានចំណេះដឹងផ្នែកភាសា និងកុំព្យូទ័រសម្រាប់ការស្វែងរកឯកសារតាមរយៈអ៊ិនធ័រណែត ខណៈពេលឯកសារសរសេរជាភាសាខ្មែរពុំសូវសម្បូរបែបសម្រាប់ការស្រាវជ្រាវបន្ថែម។ គ្រូបង្រៀនភាគច្រើនមានចំណេះដឹងមូលដ្ឋានទាបត្រឹមកម្រិតវិទ្យាល័យ និងមានគ្រូតិចតួចបំផុត ដែលបានបន្តយកសញ្ញាបត្របរិញ្ញាបត្រនៅមហាវិទ្យាល័យ។ បញ្ហានេះ បញ្ជាក់ថាចំណេះដឹងមូលដ្ឋានរបស់ពួកគាត់នៅមានកម្រិតទាប ដែលនាំឱ្យពួកគាត់ពិបាកក្នុងការសិក្សាស្រាវជ្រាវបន្ថែម។

## ៤.២ ការពិភាក្សា

យោងតាមការរំឭកទ្រឹស្តី និងលទ្ធផលនៃការស្រាវជ្រាវដែលបានលើកឡើងក្នុងជំពូកខាងលើគេឃើញថា មានបញ្ហាពាក់ព័ន្ធមួយចំនួនក្នុងការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។

ក្នុងសំណួរទី១ ដែលផ្តោតទៅលើការអនុវត្តផ្ទាល់របស់គ្រូបង្រៀនធៀបទៅនឹងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ដែលមានស្រាប់បានបង្ហាញថាសមាសភាគសីលធម៌វិជ្ជាជីវៈទទួលបានពិន្ទុទាបជាងគេ ក្នុងចំណោមសមាសភាគទាំងបួន។ ពិន្ទុទាបបន្ទាប់គឺការប្រតិបត្តិវិជ្ជាជីវៈ និងទីបីគឺការសិក្សាវិជ្ជាជីវៈ ខណៈពេលដែលគ្រូភាគច្រើនយល់ថាពួកគាត់មានចំណេះដឹងវិជ្ជាជីវៈល្អ និងក្នុងសមាសភាគនេះទទួលបានពិន្ទុខ្ពស់ជាងគេដែរ។ សីលធម៌វិជ្ជាជីវៈពិតជាមានសារៈសំខាន់ណាស់ក្នុងការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ព្រោះក្រៅពីត្រូវបង្ហាញនូវអាកប្បកិរិយាជាគ្រូបង្រៀនដ៏ល្អ និងស្រឡាញ់ការងារអាជីពជាគ្រូបង្រៀន ពួកគាត់ត្រូវមានអារម្មណ៍ជក់ចិត្តក្នុងការបង្រៀន ហើយចំពោះការផ្តួចផ្តើមគំនិតរាល់សកម្មភាពបង្រៀន និងរៀន គឺភាគច្រើនពួកគាត់គិតគូរមិនបានដិតដល់ទេ ដូចជាល្បែងសិក្សា បង្កើតសម្ភារឧបទេស ដឹកនាំសិស្សធ្វើទស្សនៈកិច្ចសិក្សា....។ ដោយសាររាល់ការផលិត និងរៀបចំអ្វីៗភាគច្រើនត្រូវការចំណាយថវិកា ខណៈពេលប្រាក់ខែរបស់ពួកគាត់មិនទាន់អាចផ្គត់ផ្គង់ជីវភាពបានទាំងស្រុងផង។ ម្យ៉ាងវិញទៀតគ្រូ បង្រៀនត្រូវចេះផ្តល់ពេលវេលាសម្រាប់សិស្ស និងការយកចិត្តទុកដាក់ស្មើៗគ្នា ដោយមិនប្រកាន់ភេទ សញ្ជាតិ អ្នកក្រ ឬអ្នកមានឡើយ។

ក្នុងសមាសភាគការប្រតិបត្តិវិជ្ជាជីវៈ បានបង្ហាញថាពួកគាត់មិនទាន់បានប្រើប្រាស់នូវបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(ICT) ក្នុងការបង្រៀន និងរៀនទេ ទោះបីកត្តាទាំងនេះមានសារៈប្រយោជន៍ និងទាក់ទាញសិស្សឱ្យរៀនសូត្រក៏ដោយ ដោយសារពួកគាត់ភាគច្រើនពុំចេះ ICT និងកត្តាសាលារៀន ពុំបានបំពាក់ឧបករណ៍ទាំងនេះសម្រាប់ឱ្យគ្រូបង្រៀនប្រើប្រាស់។ ម្យ៉ាងវិញទៀតយើងអាចរកឃើញបញ្ហាមួយទៀតគឺពួកគាត់ពិតជាបានយកចិត្តទុកដាក់លើការបង្រៀនសិស្ស ដោយបានរៀបចំមេរៀន សម្រាប់សិស្ស ផ្តល់កិច្ចការសម្រាប់សិស្សជាប្រចាំ ហើយបានកែកិច្ចការទាំងនោះ ប៉ុន្តែការផ្តល់ព័ត៌មានត្រឡប់ទៅ

មាតាបិតា ឬអាណាព្យាបាលសិស្សតាមរយៈរបាយការណ៍ប្រចាំខែមិនទាន់ល្អនៅឡើយ។ ចំណែកឯការសិក្សាវិជ្ជាជីវៈគឺជាកត្តាសំខាន់ក្នុងការលើកកម្ពស់នូវអាជីពជាគ្រូបង្រៀនរបស់ខ្លួន។ យោងតាមលោក Glatthorn (1997) បានអះអាងថា ការយកចិត្តទុកដាក់លើឱកាសអភិវឌ្ឍសមត្ថភាពរបស់គ្រូគឺជាទុនក្នុងការផ្លាស់ប្តូរនូវការបង្រៀន និងសិស្សទទួលបានលទ្ធផលជាវិជ្ជមាន។ ចំណែកឯសមាសភាគការសិក្សាវិជ្ជាជីវៈគឺជាកត្តាសំខាន់បំផុតក្នុងការលើកកម្ពស់នូវអាជីពជាគ្រូបង្រៀនរបស់ខ្លួន។ នៅក្នុងសមាសភាគនេះ ពួកគាត់ជួបបញ្ហាប្រឈមខ្លាំងជាងគេ ភាគច្រើនគឺពុំមានចំណេះដឹងផ្នែកភាសា និងកុំព្យូទ័រសម្រាប់ការស្វែងរកឯកសារតាមរយៈអ៊ិនធ័រណែត ខណៈពេលឯកសារសរសេរជាភាសាខ្មែរពុំសូវសម្បូរបែបសម្រាប់ការស្រាវជ្រាវបន្ថែម។ ប៉ុន្តែទោះបីជាយ៉ាងណាពួកគាត់ក៏បានសិក្សាស្រាវជ្រាវបន្ថែមខ្លះៗដែរតាមរយៈឯកសារភាសាខ្មែរមួយចំនួន ដូចជាសៀវភៅសិក្សាគោល ឬអត្ថបទខ្លីៗ។ ម្យ៉ាងទៀត ការសិក្សារបស់ពួកគាត់មិនទាន់គ្រប់គ្រាន់សម្រាប់គ្រូបង្រៀន ពីព្រោះពួកគាត់មួយចំនួនទើបក្លាយជាគ្រូបង្រៀនថ្មីពុំទាន់មានចំណេះដឹងពេញលេញនោះទេ តែពួកគាត់អាចរកឱកាសសិក្សាបន្ថែម និងបង្កើននូវទំនាក់ទំនងជាមួយអ្នកមានអាជីពដូចគ្នា (Murphy,1998)។ ផ្ទុយទៅវិញបញ្ហាប្រឈមលើផ្នែកបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) និងភាសា គ្រូបង្រៀនភាគច្រើនពុំមានវគ្គសិក្សាទៅលើផ្នែកកុំព្យូទ័រ និងភាសាទេ ដោយសារការបណ្តុះបណ្តាលសម័យមុនមិនទាន់បានបញ្ចូលលើមុខវិជ្ជានេះនៅឡើយ ហើយរហូតមកដល់សព្វថ្ងៃក៏ពុំមានការបំប៉នលើផ្នែកទាំងនេះដែរ។ លើសពីនេះទៅទៀត ការលំបាកក្នុងការធ្វើស្វ័យសិក្សាគឺដោយសារតែគ្រូបង្រៀនភាគច្រើនមានចំណេះដឹងមូលដ្ឋានទាបត្រឹមកម្រិតវិទ្យាល័យ និងមានគ្រូតិចតួចបំផុតដែលបានបន្តយកសញ្ញាបត្របរិញ្ញាបត្រនៅមហាវិទ្យាល័យ។ បញ្ហានេះបញ្ជាក់ថាចំណេះដឹងមូលដ្ឋានរបស់ពួកគាត់នៅមានកម្រិតទាបដែលនាំឱ្យពួកគាត់ ពិបាកក្នុងការសិក្សាស្រាវជ្រាវបន្ថែម ហើយបើយើងធ្វើការប្រៀបធៀបកម្រិតសញ្ញាបត្រគ្រូនៅកម្ពុជា ទៅនឹងគ្រូបង្រៀននៅប្រទេសមួយចំនួនដែលបានសិក្សាខាងលើ បង្ហាញថាកម្រិតសិក្សារបស់គ្រូបង្រៀន នៃបណ្តាប្រទេសទាំងនោះ ទាបបំផុតក៏ត្រឹមកម្រិតបរិញ្ញាបត្រដែរ ដែលធ្វើឱ្យពួកគេមានទុន ចំណេះដឹងខ្ពស់ និងងាយស្រួលក្នុងការពង្រឹងសមត្ថភាពតាមរយៈស្វ័យសិក្សាបន្ថែម។

ក្នុងសមាសភាគចំណេះដឹងវិជ្ជាជីវៈ ទោះបីទទួលបានពិន្ទុខ្ពស់ជាងគេក៏នៅមានបញ្ហាប្រឈមមួយចំនួនដែរ។ ដោយគ្រូបង្រៀនភាគច្រើនយល់ថា ការសិក្សា ដោយផ្ដោតទៅលើឯកសារសៀវភៅសិក្សាគោលរបស់គ្រូ និងសិស្ស ហើយពួកគាត់មិនបានសិក្សាឱ្យស៊ីជម្រៅទៅលើខ្លឹមសារផ្សេងៗ ដូចជាបញ្ហាយេនឌ័រ ជនជាតិ ឬសង្គមដែលមានទំនាក់ទំនងជាមួយការងារបង្រៀននិងរៀន និងឥទ្ធិពលនៃកត្តា ទាំងនេះ មកលើលទ្ធផលសិក្សារបស់សិស្សក៏ដោយក៏ ពួកគាត់បានជ្រួតជ្រាបនិងដឹងឮខ្លះៗដែរតាម រយៈការប្រជុំណែនាំរបស់នាយកសាលា។ គ្រូបង្រៀនភាគច្រើន បានឱ្យតម្លៃលើអាជីពការងារបង្រៀនរបស់គាត់ដោយសម្អាងទៅលើបទពិសោធន៍យូរឆ្នាំនិងការបង្រៀនថ្នាក់ដដែលៗធ្វើឱ្យពួកគាត់អាចយល់បាននូវសមត្ថភាពសិក្សារបស់សិស្សធៀបនឹងខ្លឹមសារមេរៀន ហើយគាត់ចេះលៃលកកំណត់ខ្លឹមសារមេរៀន និងបង្រៀនយ៉ាងណាធ្វើឱ្យសិស្សចេះដោយមិនផ្ដោតខ្លាំងពេកទៅលើកម្មវិធីសិក្សាទាំងស្រុងនោះទេ។

ឆ្លើយតបនឹងសំណួរទី២ អំពីបញ្ហាប្រឈមរបស់ពួកគាត់ក្នុងការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូ បង្រៀនបានរកឃើញថា កត្តាប្រាក់ខែរបស់គ្រូបង្រៀនគឺមិនអាចធ្វើឱ្យគ្រូបង្រៀនរស់បានសមរម្យទេ កត្តាទាំងនេះធ្វើឱ្យគ្រូបង្រៀនឆ្លៀតពេលប្រកបមុខរបរផ្សេងៗទៀត ដើម្បីបំពេញកង្វះខាតជីវភាពប្រចាំថ្ងៃ ដែលនាំឱ្យគ្រូបង្រៀនឃ្លាតពីការសិក្សាវិជ្ជាជីវៈរបស់ខ្លួនបន្ថែម។ ស្របជាមួយនឹងបញ្ហាប្រឈម នេះដែរ ការសិក្សាស្រាវជ្រាវរបស់អង្គការ UNESCO បានរកឃើញអំពីផលវិបាកមួយសំខាន់បំផុត ដែលទាក់ទងនឹងការផ្ដល់ប្រាក់ខែទាបនៅតំបន់អាស៊ីកណ្ដាល បានធ្វើឱ្យកើនឡើងនូវចំនួនគ្រូបង្រៀនជា ច្រើនចេញរកមុខរបរទីពីរដើម្បីជួយបំពេញនូវតម្រូវការជីវភាពប្រចាំថ្ងៃ (UNESCO,2008)។ ជីវភាព គ្រួសារគឺជាកត្តារារាំងពួកគាត់មិនឱ្យធ្វើការសិក្សាបន្ថែម និងចំណាយពេលរៀបចំការបង្រៀនឱ្យមាន ប្រសិទ្ធភាព និងមិនបានឆ្លើយតបនឹងការអនុវត្តបាននូវកម្មវិធីសិក្សាឱ្យមានការយល់ដឹងស៊ីជម្រៅនូវផ្នែក វិធីសាស្ត្របង្រៀន និងបច្ចេកវិទ្យាទំនើបៗគឺ"គ្រូបង្រៀនត្រូវធ្វើស្វ័យសិក្សា និងស្រាវជ្រាវសម្រិតសម្រាំង បង្កើនចំណេះដឹងរបស់ខ្លួន និងចូលរួមគ្រប់សកម្មភាពបណ្ដុះបណ្ដាល និងបំប៉នឱ្យបានជាប្រចាំ" (MoEYS,2008,p.6)

ដោយសារខ្វះការលើកទឹកចិត្តដល់គ្រូបង្រៀនទាំងកត្តាថវិកា និងការគាំទ្រ ដែលធ្វើឱ្យមនុស្សភាគច្រើនមិនបានផ្ដល់តម្លៃឱ្យគ្រូបង្រៀន និងការអប់រំ ដោយពុំសូវមានការចូលរួមក្នុង កិច្ចការសាលារៀនពីអ្នក

ពាក់ព័ន្ធដូចជាសហគមន៍ មាតាបិតាសិស្ស.....។ លើសពីនេះទៅទៀត អ្នកស្រាវ ជ្រាវជាច្រើនបានធ្វើការសិក្សាស្រាវជ្រាវក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនបានរកឃើញថា គ្រូបង្រៀនក្នុងតំបន់ នោះភាគច្រើនពុំមានការពេញចិត្តចំពោះមុខរបរអាជីពជាគ្រូបង្រៀនទេ ពីព្រោះមុខរបរនេះ ពុំទទួលបានការលើកទឹកចិត្តឱ្យបានសមរម្យដល់គ្រូបង្រៀនឡើយ (UNESCO,2008)។ ចំណែកលោក Rousseau (2012) បានបញ្ជាក់ថា ភាពមិនពេញចិត្តរបស់គ្រូចំពោះការងាររបស់គាត់ គឺជាព័ត៌មានដ៏ អាក្រក់សម្រាប់សិស្សានុសិស្ស ក្នុងការជំរុញឱ្យពួកគេទាំងនោះមានចំណង់ចំណូលចិត្តក្នុងការសិក្សា។បញ្ហាលំបាករបស់គ្រូក្នុងការបង្រៀនដូចជាសិស្សមានចំនួនច្រើន ចំណេះដឹងពីឋមសិក្សាមិនទាន់ចេះអាន ច្បាស់លាស់បណ្តាលឱ្យសិស្សពិបាករៀន និងកត្តាសិស្សមិនសូវយកចិត្តទុកដាក់ ជាពិសេសកម្រិតបឋម ភូមិជាវ័យដែលពួកគេវក់នឹងហ្គេមច្រើនផងដែរ ដែលធ្វើឱ្យគ្រូបង្រៀនមានការលំបាកក្នុងការបង្រៀនឱ្យ ទាន់កម្មវិធីសិក្សា ខណៈពេលដែលពួកគាត់ភាគច្រើនជាប់រវល់នឹងមុខរបរ និងកិច្ចការរកស៊ីផ្សេងៗទៀត។ របាយការណ៍សង្ខេបរបស់ក្រសួងអប់រំ យុវជន និងកីឡាបានរកឃើញថានៅតំបន់ជនបទ និងតំបន់ខ្ពង់រាបក្នុងប្រទេសកម្ពុជាកំពុងប្រឈមមុខនឹងបញ្ហាខ្វះគ្រូបង្រៀន និងបណ្ណាល័យ ទន្ទឹមនឹងការបង្រៀនរបស់គ្រូភាគច្រើនពិសេសចំនួនម៉ោងបង្រៀនមិនបានដល់និយាមដែលក្រសួងកំណត់ដែលមានចំនួនពី៨០០ ទៅ ១០០០ ម៉ោងក្នុងមួយឆ្នាំសិក្សា (MoEYS,2014b)។

បញ្ហាប្រឈមទៅលើចំណេះដឹង និងវិធីសាស្ត្របង្រៀនរបស់ពួកគាត់ធ្វើឱ្យគ្រូមួយចំនួនយល់ថាមានការលំបាកក្នុងការគ្រប់គ្រងសិស្ស។ ការសិក្សាបានបង្ហាញថា គ្រូភាគច្រើនបានទទួលការបណ្តុះបណ្តាលតែរយៈពេលពីរឆ្នាំប៉ុណ្ណោះ ហើយពួកគាត់រំពឹងថាការលើកកម្ពស់សមត្ថភាពគ្រូបង្រៀន គឺជាតួនាទីរបស់ថ្នាក់លើតាមរយៈការបំប៉នបន្ថែម។ ធនាគារពិភពលោកបានរកឃើញថា ការអភិវឌ្ឍសមត្ថភាពបន្ថែមគឺពឹងផ្អែកទាំងស្រុងលើការបណ្តុះបណ្តាលបន្ត ខណៈពេលដែលការបណ្តុះបណ្តាលបន្តទាំងនោះបានដល់គ្រូបង្រៀនប្រហែលតែ១៥ភាគរយប៉ុណ្ណោះ ក្នុងឆ្នាំសិក្សា២០០៥-២០០៦ គឺមានន័យថា ការបណ្តុះបណ្តាលបន្តនេះពុំគ្រប់គ្រាន់សម្រាប់ពួកគាត់ជាគ្រូបង្រៀនឡើយ (WB,2008) ។

ម្យ៉ាងវិញទៀត ក្នុងការសិក្សាស្រាវជ្រាវនេះ បានបង្ហាញថា គ្រូបង្រៀនភាគច្រើននៅពុំស្គាល់ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននោះទេ មានន័យថាទោះបីក្រសួងបានបោះពុម្ពឯកសារស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននេះរហូតដល់ពីរលើក គឺលើកទីមួយនៅឆ្នាំ២០១០ និងលើកទីពីរនៅឆ្នាំ២០១១ ហើយបានផ្សព្វផ្សាយឱ្យប្រើប្រាស់តាំងពីពេលនោះមកក៏ដោយ ឃើញថាស្តង់ដាមួយនេះ មានគ្រូបង្រៀនប្រហែលតែពាក់កណ្តាល តែប៉ុណ្ណោះដែលបានសិក្សា ប៉ុន្តែពុំធ្លាប់បានទទួលការណែនាំឱ្យប្រើប្រាស់ និងមានការពិនិត្យតាមដាននូវការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននេះដែរ ដែលជាហេតុធ្វើឱ្យគ្រូបង្រៀនពុំសូវយកចិត្តទុកដាក់អនុវត្តតាម និងចាប់អារម្មណ៍លើស្តង់ដាមួយនេះ ខណៈគ្រូបង្រៀនភាគច្រើនកំពុងជួបនូវបញ្ហា ប្រឈមជាច្រើន ពិសេសលើជីវភាពរស់នៅ។ បញ្ហាប្រឈមក្នុងវិធីសាស្ត្របង្រៀន គឺពុំមានការបំប៉នដែលមានលក្ខណៈជាប្រព័ន្ធ និងទទួលបានវិញ្ញាបនបត្របញ្ជាក់ការសិក្សាទេ គឺពួកគាត់កម្របានចូលរួមវគ្គបំប៉នសមត្ថភាពណាស់ ដែលការបំប៉នភាគច្រើនជូនចំពោះតែគណៈគ្រប់គ្រងសាលាប៉ុណ្ណោះ។

សរុបមកក្នុងការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ដែលក្នុងផ្នែកនៃសមាសភាគទាំងបីគឺសីលធម៌វិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ និងការសិក្សាវិជ្ជាជីវៈ គឺស្ថិតក្នុងកម្រិតមធ្យមដែលធ្វើឱ្យការអនុវត្តស្តង់ដាមួយនេះ មិនទាន់មានភាពល្អប្រសើរ ដែលក្នុងនោះគ្រូបង្រៀនត្រូវមានសីលធម៌ល្អចំពោះសិស្ស ឬអ្នកជុំវិញខ្លួនឱ្យបានល្អ និងព្យាយាមស្វែងរកវិធីបង្រៀនប្លែកៗដើម្បីយកមកប្រើប្រាស់នៅក្នុងការបង្រៀន។ ចំពោះសមាសភាគការប្រតិបត្តិវិជ្ជាជីវៈ គ្រូបង្រៀនគួរតែផលិតសម្ភារឧបទេសឱ្យបានគ្រប់គ្រាន់ និងផ្តល់ព័ត៌មានត្រឡប់ឱ្យអាណាព្យាបាលសិស្សបានជាប់លាប់ទើបធ្វើឱ្យការសិក្សារបស់សិស្សទទួលបានគុណភាព។ ម្យ៉ាងទៀតចំណុចសំខាន់មួយទៀតគឺការសិក្សាវិជ្ជាជីវៈ កាលណាគ្រូបង្រៀនពុំមានពេលសិក្សាស្រាវជ្រាវបន្ថែមធ្វើឱ្យចំណេះដឹងវិជ្ជាជីវៈរបស់ពួកគាត់ក៏ពុំមានការរីកចម្រើនទៅមុខដែរ គឺថាចំណេះដឹងទាំងនោះអាចនឹងភ្លេចទៅវិញមួយចំនួន ហើយបើប្រៀបធៀបនឹងគ្រូក្មេងៗ ឃើញថាមានកម្រិតទាបជាង និងការប្រតិបត្តិវិជ្ជាជីវៈរបស់ពួកគាត់ក៏ដូចគ្នាដែរ គឺនាំឱ្យឈានដល់ការធ្លាក់ចុះនូវសីលធម៌វិជ្ជាជីវៈថែមទៀត កាលណាពួកគាត់មិនបានរៀបចំសកម្មភាពនៃការបង្រៀននិងរៀនឱ្យមានគុណភាព។ មានន័យថា ពួក

គាត់ពុំបានបំពេញនូវភារកិច្ច និងកាតព្វកិច្ចរបស់ខ្លួនជាគ្រូបង្រៀនដ៏ល្អឡើយ ហើយគ្រូបង្រៀនត្រូវបានវាយតម្លៃពីមជ្ឈដ្ឋានខាងក្រៅ នៅពេលបង្រៀនកូនគេមិនបានល្អ។

## ៤.៣ ដំណោះស្រាយ

ដោយសាររកឃើញនូវបញ្ហាប្រឈមមួយចំនួនខាងលើដើម្បីឱ្យការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនបានល្អប្រសើរ យើងបានរកឃើញនូវដំណោះស្រាយមួយចំនួនផងដែរដូចជា៖

- ❖ នាយកសាលាគួរតែជំរុញលោកគ្រូ-អ្នកគ្រូឱ្យព្យាយាមសិក្សាស្រាវជ្រាវបន្ថែម ដើម្បីជាទុន ក្នុងការយល់ដឹងបន្ថែមទៀត ក៏ដូចជាពង្រីកចំណេះដឹងឱ្យកាន់តែទូលំទូលាយ
- ❖ លោកគ្រូ-អ្នកគ្រូ ត្រូវយកចិត្តទុកដាក់លើសៀវភៅតាមដានការសិក្សារបស់សិស្ស និងផ្តល់សៀវភៅតាមដានការសិក្សាដល់អាណាព្យាបាលសិស្សជាប្រចាំដើម្បីឱ្យឪពុកម្តាយសិស្សបានតាមដានការសិក្សារបស់កូនគាត់ ក៏ដូចជាបង្កើនទំនាក់ទំនងបានល្អជាមួយឪពុកម្តាយសិស្សផងដែរ
- ❖ នាយកសាលាគួរតែលើកទឹកចិត្តលោកគ្រូ-អ្នកគ្រូឱ្យប្រើប្រាស់វិធីបង្រៀនប្លែកៗឱ្យបានច្រើនដើម្បីឱ្យឆាប់យល់ ងាយចាប់បាន ជៀសវាងការផ្តោតតែទៅលើសិស្សពូកែ
- ❖ នាយកសាលាត្រូវចូលរួមបំផុសឱ្យលោកគ្រូ-អ្នកគ្រូផលិតសម្ភារឧបទេសសម្រាប់ការបង្រៀនឱ្យបានច្រើន ដើម្បីឱ្យសិស្សទទួលបានការសិក្សាប្រកបដោយប្រសិទ្ធភាព និងគុណភាព
- ❖ ក្រសួងអប់រំ យុវជន និងកីឡាត្រូវបង្កើតសិក្ខាសាលាទាក់ទងនឹងប្រធានបទ ឬចំណេះដឹងថ្មីដើម្បីឱ្យលោកគ្រូ- អ្នកគ្រូ បានយល់ដឹង និងទទួលបានចំណេះដឹងថ្មី ដើម្បីយកមកចែកជូនសិស្សបន្តទៀត
- ❖ ក្រសួងអប់រំ យុវជន និងកីឡាគួរតែផ្តល់គ្រូICT ម្នាក់ សម្រាប់សាលាបង្រៀនដល់លោកគ្រូ-អ្នកគ្រូដែលមិនចេះមុខវិជ្ជា ICT
- ❖ លោកគ្រូ-អ្នកគ្រូគួរតែចូលរួមរកវិធីសាស្ត្រសិក្សាប្លែកៗ ក៏ដូចជាជំរុញសិស្សខ្សោយឱ្យមានការស្រឡាញ់ និងពេញចិត្តការសិក្សា ជៀងវាងការបំបាក់ទឹកចិត្ត ស្តីឱ្យដែលនាំឱ្យសិស្សមិនមានទឹកចិត្តក្នុងការសិក្សាបន្ត។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និង សំណូមពរ

# ជំពូកទី៥៖ សេចក្ដីសន្និដ្ឋាន និងសំណូមពរ

ក្នុងជំពូកនេះអ្នកស្រាវជ្រាវធ្វើការបូកសរុបលទ្ធផលរួចមកទាញសេចក្ដីសន្និដ្ឋានចំពោះការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងបញ្ហាប្រឈមដែលទាញចេញពីលទ្ធផលនៃការស្រាវជ្រាវ ទៅលើការអនុវត្តស្តង់ដាវិជ្ជាជីវៈនេះ។ បន្ទាប់មកអ្នកស្រាវជ្រាវផ្ដល់ជាសំណូមពរមួយចំនួនដល់ស្ថាប័នពាក់ព័ន្ធ និងសម្រាប់អ្នកស្រាវជ្រាវបន្ត។

## ៥.១ សេចក្ដីសន្និដ្ឋាន

ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ជាឧបករណ៍សម្រាប់កំណត់នូវគុណភាព និងប្រសិទ្ធភាពនៃការបង្រៀនរបស់គ្រូ ដើម្បីឆ្លើយតបទៅនឹងចំណុចដៅរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការអនុវត្តកន្លងមកបង្ហាញឱ្យឃើញថា ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននេះពុំបានផ្សព្វផ្សាយឱ្យដល់មូលដ្ឋានសាលារៀន និងដល់គ្រូបង្រៀនបានដឹងឮគ្រប់ៗគ្នាសម្រាប់ជាត្រីវិស័យ និងជាគម្រូក្នុងការអនុវត្តឱ្យបានទូលំទូលាយ និងសម្រេចបានតាមលក្ខខណ្ឌតម្រូវនោះទេ។ ចំពោះការបោះពុម្ពវិញឃើញថា ឯកសារនេះបានបោះពុម្ពជាច្រើនឆ្នាំមកហើយ តែពុំមានការកែលម្អ ឬធ្វើការវាយតម្លៃឱ្យបានច្បាស់ពីឯកសារស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ហើយសៀវភៅស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននេះ ក្នុងបរិបទប្រទេសកម្ពុជា ឃើញថាពុំសូវទទួលបានការចាប់អារម្មណ៍ពីសំណាក់គ្រូបង្រៀនឡើយ គឺថាក្រោយពីបោះពុម្ពដាក់ចុះឱ្យប្រើប្រាស់ដោយក្រសួងអប់រំ យុវជន និងកីឡា យើងសង្ឃឹមថាលោកគ្រូ-អ្នកគ្រូបានអនុវត្តតាម ប៉ុន្តែវាហាក់បីដូចជាលោកគ្រូ អ្នកគ្រូមិនសូវបានស្គាល់ បានអាន បើនិយាយពីបានអនុវត្តកាន់តែអត់ទៅទៀត។

ឆ្លងតាមការប្រមូលទិន្នន័យ និងលទ្ធផលនៃការសិក្សា ធ្វើឱ្យអ្នកស្រាវជ្រាវឈានទៅរកសេចក្ដីសន្និដ្ឋាន អំពីការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ គឺស្ថិតក្នុងកម្រិតមធ្យម។ ក្នុងការអនុវត្តស្តង់ដានេះគឺប្រើសម្រាប់គ្រូទូទៅមិនថាគ្រូបឋម គ្រូកម្រិតមូលដ្ឋាន គ្រូកម្រិតឧត្តម ឬគ្រូឧទ្ទេសសាលាគរុកោសល្យនោះទេ ប៉ុន្តែសម្រាប់គ្រូកម្រិតមូលដ្ឋានក៏នៅតែមានការពិបាកក្នុងការអនុវត្ត ដោយសារគ្រូមួយចំនួនគ្មានចំណេះដឹង ICT ភាសា គ្រូមួយចំនួនទៀតបង្រៀនខុសឯកទេសដោយសារ

បញ្ហាខ្វះគ្រូ ដែលធ្វើឱ្យការផ្ទេរចំណេះដឹងទៅសិស្សអត់បានល្អដូចលោកគ្រូ-អ្នកគ្រូដែលគាត់បង្រៀនត្រូវឯកទេស និងធ្វើឱ្យគាត់មិនមានពេលវេលាសម្រាប់ការសិក្សាស្រាវជ្រាវបន្តផងដែរ។

ក្នុងការអនុវត្តជាក់ស្តែង យើងឃើញថាមានបញ្ហាប្រឈមខ្លាំងក្នុងការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន គឺពុំទាន់មានសមាសភាគណាមួយ ដែលគ្រូបង្រៀនបានអនុវត្តសម្រេចដូចការរំពឹងទុករបស់ក្រសួងឡើយ។ តាមទិន្នន័យបានបង្ហាញថា សីលធម៌វិជ្ជាជីវៈនៅមានកម្រិតទាបជាងគេ ហើយបន្ទាប់មកគឺការប្រតិបត្តិវិជ្ជាជីវៈ និងការសិក្សាវិជ្ជាជីវៈ គឺបង្ហាញថាការអនុវត្តរបស់ពួកគាត់បានប្រហែលត្រឹម៥០% ទៅ៦០% តែប៉ុណ្ណោះ ដោយពួកគាត់ពុំអាចចំណាយពេលទាំងស្រុងទៅលើការសិក្សាស្រាវជ្រាវបន្ថែម ខណៈដែល ពួកគាត់ត្រូវធ្វើកិច្ចតែងការមេរៀនសម្រាប់សិស្ស និងកិច្ចការងាររដ្ឋបាលផ្សេងៗទៀតច្រើនផងដែរ។

លើសពីនេះទៅទៀត ទាក់ទងនឹងចំណេះដឹងវិជ្ជាជីវៈរបស់ពួកគាត់ ទៅលើការអប់រំនៅមានកម្រិតដោយសារលោកគ្រូ អ្នកគ្រូមួយចំនួនគាត់មិនបានយល់ដឹងពីគោលនយោបាយអប់រំ និងគោលដៅអប់រំជាតិដែលធ្វើឱ្យការផ្ទេរចំណេះដឹងទៅសិស្សក៏មិនទាន់បានល្អប្រសើរ ដោយហេតុថាគោលនយោបាយអប់រំមានទិសដៅអប់រំ និងគោលបំណងច្បាស់លាស់ ក្នុងការជួយឱ្យសម្រេចនូវលទ្ធផលសិក្សារបស់សិស្ស និងធ្វើឱ្យការអប់រំកាន់តែមានភាពប្រសើរឡើង។ ដូចនេះគ្រូបង្រៀនទាមទារការអភិវឌ្ឍសមត្ថភាពជាប្រចាំដើម្បីបម្រើការអប់រំ ក៏ដូចជាផ្ទេរចំណេះដឹងទៅឱ្យសិស្សបានលទ្ធផលល្អ។ ការយកចិត្តទុកដាក់ទៅលើសិស្សក៏ជាកត្តាសំខាន់ ប៉ុន្តែលោកគ្រូអ្នក-អ្នកគ្រូ នៅមិនទាន់សូវផ្តោតបានពេញលេញ ដោយសារភាគច្រើនគាត់យកចិត្តទុកដាក់តែទៅលើការបង្រៀនសិស្សទូទៅរួម ប៉ុន្តែគាត់មិនសូវបានផ្តោតលើសិស្សខ្សោយដែលគាត់ត្រូវយកចិត្តទុកដាក់ឱ្យបានច្រើន ដាក់កិច្ចការឱ្យគាត់ធ្វើឱ្យបានច្រើន និងមានវិធីសាស្ត្របង្រៀនប្លែកៗដើម្បីឱ្យគាត់ងាយនឹងចាប់បាន យល់បាន ជាពិសេសគឺការលើកទឹកចិត្តគាត់ឱ្យខិតខំរៀនសូត្របន្ថែមឱ្យបានច្រើន ។

ចំពោះបញ្ហាប្រឈមយើងរកឃើញថា លោកគ្រូ-អ្នកគ្រូពិតជាមិនទាន់បានយល់ច្បាស់នូវស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅឡើយ ដោយសារពួកគាត់មិនបានទទួលការផ្សព្វផ្សាយពេញលេញពីក្រសួងឱ្យគាត់ត្រូវ

